# ប្រស្នាត្រៃគុណ

ពី

លោកអាចារ្យ ឈឹម.ទូច ធម្មបញ្ញោ

វត្តលង្កា

ប្រែនិងរៀបរៀង

ក្សៀរសេនាបតិ ជាមេគុណ្ណាកហើយ

សម្តេចសង្ឃនាយកតាំងពីការណៈរបស់ក្រុម

ភ្នំពេញ

រោងពុម្ពពាណិជ្ជបុតាំ ផ្លូវអូកញ៉ាមេន លេខ ៩

ព. ស. ២៤៨២ គ. ស. ១៩៤០

Websites: WatKhemaraRatanaram.org or WatKhmers.org


# ប្រស្នាត្រៃគុណ

## នមត្ថុ រតនត្តយស្ស

### បរិយាយដើម

សូមពណ៌នា សរសើរគុណព្រះរតនត្រ័យ ជាពាក្យបុច្ឆាវិសជ្ជនា ដើម្បីញ៉ាំងទឹកចិត្តពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង នឹងបានបែរមុខឈមទៅរកគុណ ព្រះរតនត្រ័យទាំងនោះ នឹងដើម្បីជម្រុលចិត្ត ពួកជនដែលធ្លាប់ជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរិតតែជ្រះថ្លាក្រៃលែងឡើងទៀត ដោយហេតុដែលបានមើល បានស្តាប់ឬ បានគិតរំពឹងពិចារណា តាមដំណើរសេចក្តីនេះ ។

### កែពាក្យ " រតនត្រ័យ "

បុ. ពាក្យថា " រតនត្រ័យ " មានសេចក្តីអធិប្បាយយ៉ាងណា ?

វិ. មានសេចក្តីអធិប្បាយថា: វត្ថុ ៣ ប្រការគឺ ព្រពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១ ឈ្មោះថា: រតនៈ ព្រោះជារបស់ប្រសើរវិសេសជាងវិញ្ញាណករតនៈ និងអវិញ្ញាណករតនៈ ដែលមាន

នៅក្នុងលោកទាំងបី[1] នឹងជារបស់អាចធ្វើសេចក្ដីត្រេកអរសោមនស្សឲ្យកើតឡើងដល់ពួកសត្វនិករក្នុងត្រៃភព[២]។

ពណ៌នាអំពីពុទ្ធរតនៈ

បុ. ព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គទ្រង់កើតក្នុងតំបន់ណា? ជាជាតិអ្វី? គោត្រអ្វី? ទ្រង់ព្រះនាមដូចម្ដេច? ជាបុត្ររបស់លោកណា ? មានភរិយាដែរឬទេ?

វិ. ព្រះអង្គទ្រង់កើតក្នុងមជ្ឈិមប្រទេស, ដែនសក្កៈ ក្រុងកបិលពស្ដុក្នុង សក្យត្រកូល ឬពួកអរិយជន, ជាខត្តិយជាតិជាគោតមគោត្រ, ទ្រង់ព្រះនាមថាព្រះសិទ្ធត្ថ ជាបុត្ររបស់ព្រះចៅសិរីសុទ្ធោទននឹងព្រះនាងមហាមាយាទេវី ទ្រង់បានទទួលរាជ្យដំណវង្សអំពីព្រះបិតា មានព្រះនាងពិម្ពាយសោធរាជាឯកអគ្គមហេសី, រាហុលរាជកុមារជាព្រះរាជឱរស ។

បុ. ព្រះអង្គទ្រង់បានសោយរាជសម្បត្តិមានទាំងព្រះអគ្គមហេសី និងព្រះរាជឱរស គួរណាស់តែសព្វព្រះទ័យនឹងនៅសម្ងំសោយសុខក្នុងកាមឲ្យស្កប់ស្កល់ទាល់តែអស់ព្រះជន្ម ចុះហេតុ

១- កាមលោក១ រូបលោក១ អរូបលោក១ ។ ២- កាមភព១ រូបភព១ អរូបភព១ ។

អ្វីក៏ព្រះអង្គចេញទៅទ្រង់ព្រះផ្នួស? ព្រះអង្គមិនទ្រង់អាឡោះអាល័យសោះទេឬ ?

វិ. បានជាព្រះអង្គចេញទៅទ្រង់ព្រះផ្នួស ព្រោះព្រះអង្គមានព្រះទ័យតក់ស្លុតនឹងខន្ធទាំង ៥ ដោយបានទតឃើញទេវទូតទាំង៤គឺមនុស្សជរា ព្យាធិ មរណៈ និងភេទបព្វជិត ទ្រង់ឈ្វេងយល់ថាៈ ជរា ព្យាធិ និងមរណៈ នេះដូចជាភ្លើងដ៏សន្ធោរសន្ធៅរន្ទាលច្រាលឆ្អៅ ឆេះរោលរាលមកលើពួកសត្វនិងអត្តភាពរបស់ព្រះអង្គៗ នឹងតាំងព្រះទ័យ តោះតើយទៅមិនកើត ព្រោះទ្រង់ព្រះយោបល់ថា ធម៌ទាំងនេះជាភ័យ ធំពន្លឹកគួរឲ្យស្ញើបរំភើបពេកណាស់ បើអាត្មាអញសម្ងំនៅក្នុងទីនេះ ច្រឡូកច្រឡំដោយបុត្រភរិយា មុខជានឹងគេចចេញពីកណ្តាប់ដៃ ជរា, ព្យាធិ, មរណៈ, នេះមិនរួចឡើយ បើដូច្នេះគួរអាត្មាអញភៀសខ្លួនចេញទៅបួសស្វះស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខចុះ កាលបើធ្វើយ៉ាងនេះ សមអាត្មាអញនឹងបានពើបពះប្រទះនឹងសេចក្តីសុខមិនខាន ព្រោះបព្វជ្ជា ជាភេទឧត្តមថ្លៃថ្លា ឥតមានជំពាក់ទាក់ទាមដោយទ្រព្យសម្បត្តិបុត្រភរិយាអ្វីឡើយ មើលទៅឃើញតែភេទនេះហើយទើបបានសេចក្តីសុខ ។ លុះព្រះអង្គទ្រង់ឈ្វេងយល់

Websites: WatKhemaraRatanaram.org or WatKhmers.org


យ៉ាងនេះហើយ ទើបទ្រង់ចេញទៅសាងព្រះផ្នួស ។ ទ្រង់មានព្រះទ័យអាល័យរាជសម្បត្តិនិងបុត្រភរិយាដែរ តែទ្រង់ខំប្រឹងលាកលះដោយកាត់ព្រះទ័យជំនះចេញទៅ, ពេលទៀបទ្រង់ព្រះរាជដំណើរទៅនោះ ទ្រង់មានព្រះទ័យជាប់ជំពាក់នឹងរាហុលកុមារយ៉ាងមាំ អត់ទ្រាំពុំបានទើប ទ្រង់ស្ដេចចូលទៅកាន់បន្ទប់ព្រះនាងទេវី ប្រាថ្នានឹងចាប់បីព្រះឱរស ទទួលពេលនោះ ព្រះនាងទេវីកំពុងផ្ទំលក់ដាក់ព្រះហស្ដគង់លើព្រះឱរស ទ្រង់ក៏ស្ដេចថយចេញមកវិញ ក្រែងព្រះនាងតើនឡើងទាន់ នាំអុកឡុកស្កុនព្រះរាជដំណើរ ម្លោះហើយស៊ូកាត់ព្រះទ័យថា: ណ្ហើយចុះ! ចាំគ្រាក្រោយសឹមអាត្មាអញមកឃើញមុខកូនវិញ ។

នៅមានន័យមួយកន្លែងទៀតថា: កាលដែលព្រះអង្គទ្រង់បានត្រាស់រួចហើយ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន ទ្រង់បានដំណាលរឿងនេះចំពោះព្រះអានន្ទថា: អានន្ទអើយ, កាលតថាគតកំពុងធ្វើទុក្ករកិរិយានៅក្នុងព្រៃជាទីរហោស្ថាន ( ស្ថានស្ងាត់ ) តែម្នាក់ឯង រមែងនឹកមមៃដល់កាមគុណទាំង ៥ ប្រការ ដល់រាជសម្បត្តិបុត្រភរិយា ទីទៃទនសយនា ក្រឡាព្រះបន្ទំ ដែលតថាគតធ្លាប់អភិរម្យអាស្រ័យនៅជារឿយ ៗ មក ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ហេតុនេះឃើញថា ព្រះអង្គគង់មានព្រះទ័យអាល័យដែរ តែបើទុកជាដូច្នោះ ក៏ទ្រង់ចេះតែខំលះកាត់ព្រះទ័យប្រឹងព្យាយាមបន្ទុំ ព្រះបារមីទាល់តែបានសម្រេចសម្មាសម្ពោធិញ្ញាណ ជាព្រះសព្វញ្ញុពុទ្ធឡើងក្នុងលោក ។

បុ. ចុះព្រះពុទ្ធនោះតើ ទ្រង់មានគុណដូចម្តេចខ្លះ ?

វិ. ទ្រង់មានគុណច្រើនលើសលប់នឹងរាប់មិនបាន សូម្បីតួអង្គព្រះពុទ្ធផងគ្នា បើទុកជាតាំងពីបានត្រាស់ឡើងកាលណា មិនសម្តែងធម៌អ្វីសោះ សម្តែងតែអំពីគុណព្រះពុទ្ធផងគ្នា ដរាបអស់មួយកប្បក៏មិនអស់គុណនោះដែរ ។ ឯគុណទាំងនោះបើពោលរួបរួមកាត់ឲ្យខ្លីចុះមក នៅត្រឹមតែ ៣ យ៉ាងគឺ បញ្ញាគុណ១ វិសុទ្ធិគុណ១ ករុណាគុណ១ ព្រោះគុណទាំង ៣ នេះ ជាប្រធានលើគុណទាំងពួងៗ សុទ្ធតែប្រជុំចុះក្នុងគុណទាំង ៣ នេះឬសុទ្ធតែផ្សាយចេញទៅអំពីគុណទាំង៣នេះឯង ។

បុ. បណ្តាគុណទាំង ៣ ប្រការនេះ ដូចរាប់រួចមកហើយដែលហៅថា "បញ្ញាគុណ" នោះតើដូចម្តេច?

វិ. ដែលហៅថា " បញ្ញាគុណ " នោះសំដៅយកការត្រាស់ដឹងនូវមគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និង

ញាណដ៏វិសេស មានចតុវេសារជ្ជញ្ញាណ ទសពលញ្ញាណ និងអណាវរណញ្ញាណជាដើម ដែលកើតអំពីមគ្គញ្ញាណដូចគ្នា ដែលជាហេតុឲ្យសម្រេចគុណដល់សព្វសត្វ ព្រោះជ្រាបច្បាស់ថាៈ អំពើនេះជាប្រយោជន៍ដល់សត្វ នេះមិនមែនជាប្រយោជន៍ដល់សត្វ អំពើណាដែលជាប្រយោជន៍ ព្រះអង្គរកឧបាយឲ្យសត្វសន្សំ អំពើណាមិនជាប្រយោជន៍ ព្រះអង្គរកឧបាយឲ្យសត្វលះបង់ ដោយអនុសាសនីទេសនា យ៉ាងនេះឯងហៅថា " បញ្ញាគុណ " ។

បុ. ចុះវិសុទ្ធិគុណដូចម្តេច?

វិ. វិសុទ្ធិគុណសំដៅយកត្រង់សេចក្តីបរិសុទ្ធិ របស់ព្រះអង្គបានដល់ការលះបង់កិលេសព្រមទាំងវាសនាដាច់ស្រឡះ ទោះបីលោកធម៌ទាំង ៨ ប្រការកើតឡើងចំពោះព្រះភក្ត្រក៏ទឹកព្រះទ័យរបស់ព្រះអង្គមិនមានរំភើប យ៉ាងនេះហៅថា " វិសុទ្ធិគុណ " ។

បុ. ចុះករុណាគុណដូចម្តេច?

វិ. ករុណាគុណ បានដល់សេចក្តីប្រណីអាណិតដល់ពួកសត្វដែលកំពុងក្តៅក្រហាល់ក្រហាយ អន្ទះអន្ទែងដោយភ្លើងទុក្ខ ភ្លើងកិលេសនឹងជ្រមុចឈ្លក់នៅក្នុងសង្សារសមុទ្រ រងទុក្ខវេទនា

រកទីបំផុតមិនបាន ទ្រង់ក៏មានព្រះទ័យប្រាថ្នានឹងស្រោចស្រង់លើកស្ទួយពួកសត្វទាំនោះ ឲ្យរួចផុតអំពីទុក្ខវេទនានោះឡើង យ៉ាងនេះហៅថា " ករុណាគុណ " ។

គុណទាំង ៣ នេះស្ទេះទុកប៉ុណ្ណេះ តអំពីនេះនឹងសម្តែងអំពីគុណ ដែលជាកិត្តិសព្ទឮល្បីសុះសាយទៅក្នុងលោកទាំង ១០ ប្រការ ( ឬ ៩ ប្រការ ) មាន " អរហំ " ជាដើម មាន " ភគវា " ជាបរិយោសាន ដើម្បីជាទីរឭកនឹងជាទីជ្រះថ្លាដល់អ្នកកាន់ព្រះពុទ្ធសាសនាទាំងពួងតទៅ ។

## កែបទ " អរហំ "

បុ. ព្រោះហេតុអ្វី បានជាព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា " អរហំ "?

វិ. ព្រោះព្រះអង្គជាអ្នកឆ្ងាយ, ជាអ្នកបំបាក់បង់ ជាអ្នកគួរ ជាអ្នកមិនមានទីកំបាំង ។

ក) បុ. ពាក្យថា " ព្រះអង្គជាអ្នកឆ្ងាយ " អធិប្បាយដូចម្តេច?

វិ. អធិប្បាយថា ព្រះអង្គជាអ្នកឆ្ងាយស្រឡះអំពីកិលេស ( គ្រឿងមន្ទិល ) ៣ គឺ រាគៈ១ ទោសៈ១ មោហៈ១ , អាសវៈ ៣ គឺ កាមាសវៈ១ ទិដ្ឋាសវៈ១ អវិជ្ជាសវៈ១, វិបល្លាស៣

គឺ សញ្ញាវិបល្លាស ១ ចិត្តវិបល្លាស ១ ទិដ្ឋិវិបល្លាស ១, អនុសយៈ ៣ គឺ កាមរាគានុសយៈ ១ ទិដ្ឋានុសយៈ ១ អវិជ្ជានុសយៈ ១, អគតិ ៤គឺ ឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១, គន្ថៈ ៤គឺ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយ-គន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេស-កាយគន្ថៈ ១, ឱឃ ៤ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១, ឧបាទាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១, អត្តវាទុបាទាន ១, មច្ឆរិយៈ៥គឺ អាសវ-មច្ឆរិយៈ១ កុលមច្ឆរិយៈ១ វណ្ណមច្ឆរិយៈ១ លាភមច្ឆរិយៈ១ ធម្ម-មច្ឆរិយៈ១, អនុសយៈ ៧គឺ កាមរាគានុសយៈ១ ភវរាគានុសយៈ១ បដិឃានុសយៈ១ មានានុសយៈ១ ទិដ្ឋានុសយៈ១ វិចិកិច្ឆា-នុសយៈ១ អវិជ្ជានុសយៈ១, លោកធម៌ ៨, មន្ទិល ៩, អកុសលកម្មបថ១០, សំយោជន១០, កិលេស១០, មិច្ឆត្តធម៌១០, អកុសលចិត្តុប្បាទ ១២, តណ្ហា១០៨, កិលេស ១៥០០ ។ កិលេសទាំងអម្បាលនេះ មិនបានជិតជាប់ ឬដក់នៅក្នុងខន្ធសន្តានរបស់ព្រះអង្គតិចតួចឡើយ ព្រះអង្គទ្រង់លះបង់បានជា

សមុច្ឆេទប្បហាន គឺទ្រង់លះបង់ដោយអរិយមគ្គ, ជាបដិបស្សទ្ធិប្បហាន គឺទ្រង់លះបង់ដោយអរិយផល, ជានិស្សរណប្បហាន គឺទ្រង់លះបង់ដោយនិរោធនិព្វាន ។ ដែលព្រះអង្គទ្រង់ឆ្ងាយចាក កិលេសទាំងនោះ នឹងថាកិលេសទាំងនោះរត់គេចចេញអំពីព្រះ អង្គក៏មិនមែន ឬនឹងថាព្រះអង្គរត់គេចចេញអំពីកិលេសទាំងនោះ ក៏មិនមែន ព្រោះកិលេសជាអរូបធម៌ មិនមានរូបសណ្ឋាន ទ្រង់ទ្រាយឡើយ គឺព្រះអង្គគ្រាន់តែដុសខាត់ព្រះទ័យឲ្យស្អាត ប៉ុណ្ណោះ កិលេសទាំងនោះក៏សូន្យបាត់ទៅឯងៗ ដូចជាទីងងឹត ត្រូវនឹងពន្លឺប្រទីប ។

កិរិយាដែលព្រះអង្គទ្រង់លះកិលេស ជាសឹកសត្រូវនោះមាន ន័យ លោកប្រៀបថាដូចអាការរបស់ជាងធ្វើព្រួញ, ធម្មតាជាង ធ្វើព្រួញមុនដំបូងគេនាំយកឈើមួយកំណាត់អំពីព្រៃ មកហើយ សិទ្ធសំបកចេញ លាបប្រេង រោលកំដៅលើអម្បែងរងើកភ្លើង រួចស៊កទៅក្នុងឈើឃ្នាបគាបឲ្យត្រង់ ឲ្យគួរដល់ការបាញ់ចុងរោម ទ្រាយបាន, លុះធ្វើរួចហើយ ទើបចូលទៅសម្តែងសិល្បសាស្រ្ត ថ្វាយស្តេចនិងពួករាជអាមាត្យ ក៏រមែងបានសក្ការៈនិងការ និយមរាប់អានជាច្រើន, អាការនេះយ៉ាងណាមិញ, កិរិយាដែល

ព្រះពុទ្ធជាម្ចាស់ទ្រង់លះកិលេសក៏យ៉ាងនោះដែរ, គឺមុនដំបូងព្រះអង្គសកព្រះទ័យ ដែលមានសភាពញាប់ញ័រជាដើមឲ្យអស់សម្បកចេញ គឺឲ្យអស់កិលេសគ្រោតគ្រាតចេញ ដោយអំណាចនៃការរក្សាធុតង្គនៅក្នុងព្រៃ ទ្រង់លាបដោយជ័រគឺសទ្ធាទ្រង់ជុតរោល ដោយព្យាយាមផ្លូវកាយនិងព្យាយាមផ្លូវចិត្ត ទ្រង់ពត់ដោយឈ្នាបគឺ សមថនិងវិបស្សនា ហើយធ្វើព្រះទ័យនោះឲ្យត្រង់ឲ្យអស់ពុតកំណាចចេញ, លុះធ្វើបានយ៉ាងនេះហើយ ទ្រង់ក៏ពិចារណាឲ្យស្គាល់ពីកំណើតសង្ខារ ទំលាយបង់នូវគំនរអវិជ្ជាយ៉ាងធំ, ធ្វើវិជ្ជា ៣ អភិញ្ញា ៦ និងលោកុត្តរធម៌៩ ឲ្យតាំងនៅក្នុងកណ្តាប់ព្រះហស្ត ទ្រង់បានជាទក្ខិណេយ្យបុគ្គលឡើងក្នុងលោក ព្រោះទ្រង់លះកិលេសទាំងនោះបានមិនឲ្យមានសេសសល់ក្នុងខន្ធសន្តាន ។

ក៏ឯពាក្យថា " កិលេសៗ " នោះ បានដល់គ្រឿងធ្វើចិត្តឲ្យសៅហ្មង បើពោលដោយបរិយាយដូចបានរៀបរាប់ពីខាងដើមរួចមកហើយ, តែបើពោលសំដៅយកតែកិលេសដែលជាប្រធាន

មេគេ មានត្រឹមតែពគឺ លោភោ[1] សភាពញុំាងចិត្តឲ្យជាប់ជំពាក់ក្នុងអារម្មណ៍១, ទោសោ[២] សភាពញុំាងចិត្តឲ្យប្រទូស្តអន់អាក់ក្នុងអារម្មណ៍១, មោហោ[៣] សភាពញុំាងចិត្តឲ្យភាន់ក្នុងអារម្មណ៍ ១, កិលេសទាំង ៣ នេះជាឫសគល់នៃកិលេសទាំងអស់ កិលេសក្រៅពីនេះទាំងប៉ុន្មាន កើតចេញទៅតែអំពីកិលេសទាំង ៣ នោះឯង, ឧបមាដូចជា ដើមឈើធំ ៣ ដើម ជាប្រធាននៃមែកតូចនិងមែកធំទាំងពួង ។

ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ ព្រះអង្គមិនគ្រាន់តែឆ្ងាយចាកកិលេសទាំងនោះប៉ុណ្ណោះឡើយ ទ្រង់ឆ្ងាយចាកទាំងវាសនា គឺស្នាមគំនូស ដែលធ្លាប់ប្រព្រឹត្តពីបុព្វជាតិមកទាំង ២ ប្រការផង

---

១-២-៣ កិលេសទាំង ៣ នេះ មានទោសខុសគ្នាដូច្នេះ លោភ: មានទោសស្រាល តែកម្រលះបាន (នេះចំពោះតែលោភ: ដែលមិនប្រកបដោយសស្សតទិដ្ឋិ) ទោស:មានទោសធ្ងន់ តែងាយលះបាន, មោហ: មានទោសធ្ងន់ផង កម្រលះបានផង ។ លោភ: លះដោយសមាធិក្ខន្ធ ទោស: លះដោយសីលក្ខន្ធ មោហ: លះដោយបញ្ញាខន្ធ ។ លោភ: ច្រើននាំសត្វទៅកាន់បេតវិស័យ ទោស: ច្រើននាំទៅនរក មោហ: ច្រើននាំសត្វទៅកាន់តិរច្ឆាន ។ លោភ: បាំងអនិច្ចំ ទោស: បាំងទុក្ខំ មោហ: បាំងអនត្តា ។ លោភ: ញុំាងសត្វមិនឲ្យបានភោគ:សម្បត្តិ ទោស: ញុំាងសត្វមិនឲ្យបានមិត្តសម្បត្តិ មោហ: ញុំាងសត្វមិនឲ្យតម្កល់ខ្លួនត្រូវ ។ លោភ: ធ្វើសត្វមិនឲ្យបានសួគ៌ ទោស: ធ្វើសត្វមិនឲ្យបានព្រហ្ម មោហ: ធ្វើសត្វមិនបាននិព្វាន ។

ទៀត គឺ កាយបយោគ ទម្លាប់កាយ ឬ ក្រមាច់កាយ១ វចីបយោគ ទម្លាប់វាចា ឬ ក្រមាច់វាចា១ ។

ព្រោះហេតុនោះបានជាទ្រង់ព្រះនាមថា " អរហំ " ប្រែថា " ព្រះអង្គជាអ្នកឆ្ងាយ " គឺឆ្ងាយចាកកិលេសនិងវាសនាដូចបានអធិប្បាយមកហើយនេះឯង ។

ខ)បុ. ពាក្យថា "ព្រះអង្គជាអ្នកបំបាក់បង់" អធិប្បាយដូចម្តេច?

វិ. អធិប្បាយថា: ព្រះអង្គជាអ្នកបំបាក់បង់នូវសំសារចក្រដែលជាគ្រឿងនាំសត្វឲ្យវិលទៅក្នុងវដ្តៈ ។ សំសារចក្រនោះលោកប្រកបដូច្នេះគឺ អាសវៈ៤ ទុកជាភ្លៅ, អវិជ្ជា ទុកជាដុំ, សង្ខារទាំង ៣ មានបុញ្ញាភិសង្ខាជាដើមទុកជាកាំ, ជរា និង មរណៈទុកជាខ្នងកង់, ចេតនា ២៩ គឺ អកុសលចេតនា ១២ មហាកុសល៨, រូបាវចរកុសល ៥, អរូបាវចរកុសល៤ ទុកជាជន្លួញកាំដែលបញ្ចុះទៅក្នុងដុំ រួមបានជាកង់ យកទៅប្រកបនឹងតួរថគឺភពទាំង ៣ សម្រាប់ផ្ទុកសត្វវិលចុះឡើងនៅតែក្នុងវដ្តសំសារ, បានជាហៅថា សំសារចក្ក ។

ភព ៣ លោកទុកជាតួរថ ព្រោះជាទីសម្រាប់សត្វកើតនិងសត្វនៅ អាសវ ៤ ទុកជាភ្លៅ ព្រោះជាមេនាំសត្វឲ្យកើត, អវិជ្ជា

ទុកជាដុំ ព្រោះជាមូលហេតុដើម ជរា មរណៈ ទុកជាខ្នងកង់ ព្រោះជាបរិយោសាន, សង្ខារទាំង ៣ ទុកជាកាំ ព្រោះមាន អវិជ្ជា និងជរា មរណៈ នៅព័ទ្ធជុំវិញ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ស្ថិតលើផែនប្រឹបពី គឺសីល ដោយព្រះបាទទាំងគូ គឺវិរិយៈ យកព្រះហស្តគឺសទ្ធា ចាប់ព្រះខាន់ថ្លា គឺបញ្ញា កាប់ក្របែល នូវសំសារចក្កឲ្យខ្ទាត់ខ្ទាយរាត់រាយអស់រលីងទៅ, ទើបបាន ទ្រង់ព្រះនាមថា " អរហំ " ប្រែថា " អ្នកបំបាក់ " គឺបំបាក់នូវសំសារចក្កនោះឯង។

គ) បុ. ពាក្យថា " ព្រះអង្គអ្នកគួរ " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះអង្គមានគុណគួរទេវតានិងមនុស្សទាំងឡាយ បូជា ឬថាព្រះអង្គគួរទទួលនូវគ្រឿងបូជារបស់មនុស្ស និងទេវតាទាំងឡាយ ព្រោះការបូជាដែលសត្វឲ្យប្រព្រឹត្តទៅក្នុង ព្រះអង្គ ទោះបីបន្តិចបន្តួចក៏គង់មានផលវិសេសវិសាល, ដូច កាលនាយសុមនមាលាការបានបូជាផ្កាម្លិះ និងចូឡេកសាដក ព្រាហ្មណ៍បានបូជាសំពត់សាដកចំពោះព្រះអង្គជាដើម, មាន

សេចក្ដីសរសើរថា: គ្រឿងសក្ការបូជាដែលសត្វនាំយកទៅបូជាព្រះអង្គ ហើយមានផលច្រើននោះ មិនចំពោះតែក្នុងកាលដែលព្រះអង្គគង់ធរមាននៅឡើយនោះទេ, ទោះបីក្នុងកាលដែលព្រះអង្គចូលកាន់ព្រះបរមនិព្វានទៅហើយ ឲ្យតែបុគ្គលមានចិត្តជ្រះថ្លា ក៏គង់មានផលច្រើនដូចគ្នា, ដូចន័យដែលមានមកក្នុងមង្គលត្ថទីបនីថា "តិដ្ឋន្តេ និព្វុតេ ចាបិ សមេ ចិត្តេ សមំ ផលំ" កាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ធរមាននៅក្ដី កាលដែលព្រះអង្គទ្រង់ចូលព្រះបរមនិព្វានទៅហើយក្ដី បើចិត្តរបស់ទាយកអ្នកបូជាជ្រះថ្លាស្មើគ្នា ក៏គង់មានផលស្មើគ្នា ។

ម្យ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ ព្រះអង្គគួរដើម្បីសម្ដែងនឹងបញ្ញត្តិធម៌ វិន័យដល់ពួកបរិស័ទ ព្រោះព្រះអង្គជាអ្នកឆ្ងាយចាកកិលេសហើយ ធម៌វិន័យដែលព្រះអង្គទ្រង់សម្ដែងនិងបញ្ញត្តិនោះជាការពិតឥតមានល្អៀង ព្រោះព្រះអង្គទ្រង់សម្ដែងនិងបញ្ញត្តិមិនមានលំអៀងដោយអគតិ[1] ទាំង ៤ ណាមួយឡើយ ។

---

១ គឺមិនមែនបញ្ញត្តដោយលំអៀងព្រោះស្រលាញ់, ព្រោះស្អប់, ព្រោះល្ងង់, ព្រោះខ្លាចឡើយ ។

ម្យ៉ាងទៀត បុគ្គលដែលគួរទទួលគ្រឿងសក្ការបូជារបស់មនុស្ស និងទេវតានោះ មិនចំពោះតែតួអង្គព្រះពុទ្ធទេ, ទោះបីព្រះខីណាស្រពឯទៀតដែលអស់កិលេសហើយ ក៏គួរទាំងអស់ ទាំងលោកដែលនៅជាសេក្ខបុគ្គល មិនទាន់អស់កិលេសនៅឡើយ ក៏គង់គួរដែរ, ដោយហោចទៅ សូម្បីតែបុថុជ្ជនអ្នកមានសីល ក៏គង់រាប់បញ្ចូលថាគួរផងបាន, តែទុកណាជាដូច្នោះ ក៏មិនមែនគួរយ៉ាងវិសេសដូចជាព្រះពុទ្ធឡើយ ព្រោះហេតុនោះទើបទ្រង់ព្រះនាមថា " អរហំ " ប្រែថា " ព្រះអង្គជាអ្នកគួរ " គឺគួរទទួលនូវគ្រឿងសក្ការបូជារបស់មនុស្សនិងទេវតាជាដើម វិសេសជាងបុគ្គលឯទៀតទាំងអស់ ។

ឃ) បុ. ពាក្យថា " ព្រះអង្គជាអ្នកមិនមានទីកំបាំង " អធិប្បាយដូចម្ដេច?

វិ. អធិប្បាយថា: ព្រះអង្គមិនមានឱកាសស្ងាត់កំបាំង នឹងធ្វើបាប គឺថាព្រះអង្គមិនពួនសម្ងំធ្វើបាបក្នុងទីកំបាំង ។

បុ. បើក្នុងទីកំបាំងព្រះអង្គមិនធ្វើបាប ចុះដល់មកចំពោះមុខគេព្រះអង្គទ្រង់ធ្វើបាបឬអ្វី ?

វិ. ក្នុងទីស្ងាត់កំបាំងព្រះអង្គមិនធ្វើទៅហើយ ចាំនិយាយថ្វីដល់ទៅក្នុងទីចំពោះមុខគេ ។ ព្រះអង្គមិនដូចជាមនុស្សសាមញ្ញទេ, ធម្មតាមនុស្សសមញ្ញពួកខ្លះ ក្នុងទីចំពោះមុខគេមិនហ៊ានធ្វើបាប តែដល់កំបាំងពីមុខគេលបសម្ងំធ្វើបាបឥតមានញញើត ។ ហេតុនោះ ព្រះអង្គ ទើបទ្រង់ព្រះនាមថា " អរហំ " ប្រែថា " ព្រះអង្គមិនជាអ្នកមានទីស្ងាត់ កំបាំង គឺព្រះអង្គមិនដែលលបធ្វើបាបក្នុងទីកំបាំងឡើយ ។

ចប់ព្រះនាម " អរហំ " ដោយសង្ខេប

កែបទ " សម្មាសម្ពុទ្ធោ "

បុ. សម្ដេចព្រះសព្វញ្ញូជាម្ចាស់ ហេតុអ្វីបានជាទ្រង់ព្រះនាមថា " សម្មាសម្ពុទ្ធោ " ?

វិ. បានជាទ្រង់ព្រះនាមថា " សម្មាសម្ពុទ្ធោ " ព្រោះព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ។

សូមស្រង់សំដីដែលវិសជ្ជនាមកនុ៎ះ ធ្វើជាពាក្យ ៣ មាត់ គឺត្រាស់ដឹង១ម៉ាត់, ដោយប្រពៃ១ម៉ាត់, ចំពោះព្រះអង្គឯង១ម៉ាត់, ដើម្បីធ្វើជា(ខ)បុច្ឆាតទៅ ។

ក) បុ. ពាក្យថា " ព្រះអង្គត្រាស់ដឹង " នោះតើត្រាស់ដឹងនូវធម៌អ្វីខ្លះ ?

វិ. " ចត្តារិ សច្ចានិ សម្មាសម្ពុទ្ធោ " ព្រះអង្គត្រាស់ដឹងនូវធម៌ពិត ៤ ប្រការគឺៈ ទុក្ខៈ១, សមុទយៈ១, និរោធៈ១, មគ្គៈ១, ដែលហៅថា " អរិយសច្ច " ប្រែថា " ធម៌ពិតរបស់ព្រះអរិយ, ធម៌ពិតនាំឲ្យឆ្ងាយចាកសឹកសត្រូវ, ធម៌ពិតញ៉ាំងភាពជាព្រះអរិយៈឲ្យសម្រេច, ធម៌ពិតដ៏ប្រសើរ "។

ដែលប្រែថា " ធម៌ពិតនាំឲ្យឆ្ងាយចាកសឹកសត្រូវ " អធិប្បាយថាៈ កិលេសធម៌ដ៏លាមកទាំងពួង ឈ្មោះថាសឹកសត្រូវ, លោកដែលត្រាស់ដឹងនូវអរិយសច្ចទាំង ៤ នេះហើយ,

សឹកសត្រូវទាំងនោះ មិនមានក្នុងសន្តានរបស់លោកឡើយ, លោកក៏បានឃ្លាតឆ្ងាយចាកសឹកសត្រូវទាំងនោះ ។

ដែលប្រែថា " ធម៌ពិតញ៉ាំងភាពជាព្រះអរិយៈ ឲ្យសម្រេច " អធិប្បាយថា: ធម៌ពិតទាំង៤ប្រការនេះ បើលោកណាដឹងច្បាស់ដោយបញ្ញាថា " នេះទុក្ខ, នេះហេតុនាំឲ្យកើតទុក្ខ, នេះសេចក្ដីរំលត់ទុក្ខ, នេះផ្លូវប្រតិបត្តិដើម្បីរំលត់ទុក្ខ " ដូច្នេះ ព្រមដោយបរិវដ្ដ ៣, អាការ ១២ ហើយ ក៏អាចធ្វើលោកនោះ ឲ្យសម្រេចជាព្រះអរិយៈបាន ។

ដែលប្រែថា " ធម៌ពិតដ៏ប្រសើរ " អធិប្បាយថា: ធម៌ទាំង ៤ នេះជាធម៌ពិតមែន គឺទុក្ខ ពិតជាទុក្ខមែន សមុទយៈ ហេតុនាំឲ្យកើតទុក្ខ ពិតជាហេតុនាំឲ្យកើតទុក្ខមែន, និរោធៈ សេចក្ដីរំលត់ទុក្ខ ពិតជារំលត់ទុក្ខមែន, មគ្គៈ សេចក្ដីប្រតិបត្តិដើម្បីរំលត់ទុក្ខ ពិតជារំលត់ទុក្ខបានមែន ដូច្នេះបានជាហៅថា " ធម៌ពិតដ៏ប្រសើរ " ។

ក៏ពាក្យថា " ទុក្ខ " នេះបើពោលរួបរួមមក ប្រជុំនៅតែត្រឹម ខន្ធ ៥ តាមបាលីថា: សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ខន្ធ ៥ ដែលជាគំនួចរបស់ឧបាទាន ហៅថា " ទុក្ខ " ដោយបំព្រួញ ។

ពាក្យថា " សមុទយ: " សំដៅយកតណ្ហា១ ចែកចេញជា ៣ យ៉ាងគឺ កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ។ តណ្ហាទាំង ៣ ប្រការនេះ ជាហេតុនាំឲ្យកើតទុក្ខ កាលបើតណ្ហាដែលជាមេបណ្តាលឲ្យកើតទុក្ខរលត់ហើយ, ទុក្ខក៏រលត់បាត់ទៅផង ។

ពាក្យថា " និរោធ: " សំដៅយកព្រះនិព្វាន, ព្រះនិព្វាននេះជាទីរលត់ទៅនៃទុក្ខទាំងអស់, ទុក្ខទាំងប៉ុន្មានទៅរលត់ស្ងប់ត្រឹមព្រះនិព្វាននេះឯង ។

ពាក្យថា " មគ្គ " សំដៅយកអដ្ឋង្គិកមគ្គ គឺផ្លូវប្រតិបត្តិដែលប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ដែលជាផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វាន ជាគ្រឿងសម្លាប់តណ្ហាបាន ។ មគ្គនេះបើពោល ដោយការសង្គ្រោះ នៅត្រឹមតែ ៣ ប្រការគឺ សង្គ្រោះដោយសីល[1] ១ សមាធិ១ បញ្ញា១ ។

" និព្វានំ សម្មាសម្ពុទ្ធោ " សម្តេចព្រះលោកនាថជាម្ចាស់ព្រះអង្គត្រាស់ដឹងនូវព្រះនិព្វាន ៣ ប្រការគឺ កិលេសនិព្វាន១ ខន្ធនិព្វាន១ ធាតុនិព្វាន១ ។

---

១ សម្មាទិដ្ឋិ សម្មាសង្កប្បោ ពីរនេះលោកសង្គ្រោះដោយបញ្ញា ។ សម្មាវាចា សម្មាកម្មន្តោ សម្មាវាយាមោ បីនេះលោកសង្គ្រោះដោយសីល ។ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ បីនេះលោកសង្គ្រោះដោយសមាធិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


កិលេសនិព្វាន បានដល់កិរិយារំលងស្ងួតកិលេស តួយ៉ាងដូចកាលព្រះអង្គទ្រង់គង់លើរតនបល្ល័ង្កក្បែរពោធិព្រឹក្ស ទ្រង់ផ្ចាញ់មារាធិរាជព្រមទាំងពួកពលឲ្យបរាជ័យ បាក់បបខ្លបខ្លាចចុះចាញ់ព្រះអង្គ ហើយទ្រង់រំពឹងដល់ពុទ្ធប្បវេណី ដោយឈានសមាបត្តិលះបង់នូវ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ព្រមទាំងកិលេស ១៥០០, តណ្ហា១០៨ ឲ្យឃ្លាតពីសន្តានព្រះអង្គដូចដំណក់ទឹកដែលជ្រុះចុះចាកស្លឹកឈូក, យ៉ាងនេះហៅថា " កិលេសនិព្វាន " ពេលដែលព្រះអង្គទ្រង់បានកិលេសនិព្វាននោះ ព្រះអង្គទ្រង់បន្លឺនូវឧបាទានវាចាថា:

អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ
គហាការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហាការក ទុដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ[1]

---

១ ព្រះពុទ្ធដីកានេះ ហៅថា " បឋមពុទ្ធវចនៈ "

អធិប្បាយតាមលំអាន ព្រះពុទ្ធដីកានេះថា:

កាលដែលតថាគតកំពុងស្វែងរកជាងឈើគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាពរបស់តថាគត កាលដែលមិនទាន់បានជួបប្រទះនៅឡើយ តថាគតតែងតែអន្ទោលទៅកាន់សំសារវដ្ត រាប់ជាតិជាអនេក ( ម្លោះហើយ ) ជាតិក៏តែងនាំសេចក្ដីទុក្ខមកឲ្យតថាគតរឿយៗ ឥតស្រាកស្រាន្តឡើយ, នែ! ជាងផ្ទះ ឥឡូវតថាគតរកអ្នកឃើញហើយណា៎: ពីនេះទៅអ្នកឯងអស់ធ្វើផ្ទះគឺអត្តភាពឲ្យតថាគតបានទៀតហើយ បង្កង់គឺ កិលេសដ៏វិសេសទាំងឡាយរបស់អ្នកឯង តថាគតកាច់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជា ដែលអ្នកឯងធ្វើរួចហើយ (នោះ) តថាគតក៏បានកំចាត់បង់ហើយ ឥឡូវនេះ ចិត្តរបស់តថាគតបានដល់ព្រះនិព្វាន ដែលប្រាស់ចាកសង្ខារហើយ តថាគតបានត្រាស់ដឹងនូវព្រះអរហត្តដែលជាធម៌ក្ស័យតណ្ហាទាំងឡាយហើយ ។

ឯខន្ធនិព្វាននោះ តួយ៉ាងដូចម្ដេចព្រះសព្ពញ្ញុពុទ្ធអង្គទ្រង់បានដល់នូវព្រះសព្វញ្ញុតញ្ញាណ ហើយទ្រង់គង់នៅប្រោសសត្វ

បានចំនួន ៥៥ ព្រះវស្សា ហើយស្ដេចយាងទៅផ្ទំលើទែនសិលាសនៈ ក្រោមលង្វែកមែករាំងទាំងគូរក្បែរនគរកុសិនារា ស្ដេចចូលកាន់ឈានសមាបត្តិហើយ លះបង់ព្រះជន្មាយុសង្ខារ ទ្រង់ព្រះដំណើរចូលទៅកាន់ព្រះនិព្វានរំលត់រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ឥតមានវិបាកក្ខន្ធនិងកម្មជរូប សេសសល់តិចតួចឡើយ, យ៉ាងនេះហៅថា ខន្ធនិព្វាន គឺរលត់សូន្យទៅនៃបញ្ចក្ខន្ធ ។

ឯធាតុនិព្វាននោះ កំណត់ត្រឹមព្រះពុទ្ធសាសនាគ្រប់ ៥០០០ ព្រះវស្សាហើយ ព្រះបរមធាតុសម្ដេចព្រះមុនីនាថជាម្ចាស់ទាំងប៉ុន្មានដែល ទៅប្រតិស្ឋាននៅក្នុងតំបន់ផ្សេងៗ ក៏អណ្ដែតត្រសែតមកប្រជុំសមោធានជាអង្គព្រះសម្មាសម្ពុទ្ធ ដូចជាមានព្រះជន្មាយុទ្រង់នៅដូចដើម ហើយទ្រង់គង់ផ្គត់ព្រះភ្នែនលើរតនបល្ល័ង្កត្រង់កន្លែងមហាពោធិព្រឹក្ស ទ្រង់ព្រះមហាបុរិសលក្ខណៈ ៣២, អនុព្យញ្ជនៈ ៨០, ព្រះឆព្វណ្ណរង្សី ៦ ប្រការ, ទ្រង់សម្ដែងព្រះបាដិហារ្យអស់ ៧ ទិវា ពួកទេវតា ឥន្ទ្រ ព្រហ្ម ទាំងឡាយសឹងមានដៃកាន់ទៅនូវភ្លួងបុប្ផា កម្រងមាលា សក្ការគ្រប់ប្រការចុះចាកចេញពីស្ថានវិមានរបស់ខ្លួន នាំគ្នាគឹកកងមក ថ្វាយបង្គំប្រណម្យ

នមស្សការបូជា បានសម្រេចធម៌វិសេសជាន់ខ្ពស់តាំងពីសោតាបត្តិផលដល់ព្រះអរហាត្តរាប់ចំនួនបាន ២៤អង្ស្នៃយ្យ ៦លាន ៦សែន ៧ពាន់ ៨០កោដិ ។ ដល់គ្រប់កំណត់ ៧ថ្ងៃហើយ តេជោធាតុ ក៏តាំងឡើងប្រល័យអង្គព្រះពុទ្ធរូបព្រះបរមធាតុឲ្យសុះសូន្យអស់ទៅ, យ៉ាងនេះ ហៅថា ធាតុនិព្វាន គឺសូន្យទៅនៃព្រះធាតុ ។

" អភិញ្ញេយ្យំ ធម្មំ សម្មាសម្ពុទ្ធោ " ព្រះលោកនាថសាស្តាចារ្យ ទ្រង់ជ្រាបនូវញេយ្យធម៌គឺ ទុក្ខសច្ច ដែលមានលក្ខណៈ ១២ គឺជាតិទុក្ខ សេចក្តីទុក្ខមានជាតិជាបច្ច័យ រាប់ចាប់ដើមតាំងតែអំពីចូលមកចាប់បដិសន្ធិក្នុងផ្ទៃមាតា បានសេចក្តីក្តៅក្រហាយជានិរន្តរ៍ឥតស្រាកស្រាន្ត១, ជរាទុក្ខ ទុក្ខមានការចាស់គ្រាំគ្រាជាបច្ច័យ រាប់តាំងពីប្រសូត្រចេញ ចាកគភ៌មាតារៀងមក ដោយសាររូបរាងកាយនេះចេះតែទ្រុឌទ្រោមគ្រាំគ្រាទៅ១, ព្យាធិទុក្ខ ទុក្ខមានរោគដែលឃាឃីបៀតបៀនឲ្យឈឺចាប់ជាបច្ច័យ១, មរណទុក្ខ ទុក្ខមានសេចក្តីស្លាប់ជាបច្ច័យ ព្រោះថាកាលបើព្យាធិចូលមកលុកលុយរូបកាយហើយ មរណៈក៏ទន្ទ្រាន

ចូលមកជិត ម្លោះហើយ សត្វក៏កើតទុក្ខព្រួយជាពន្លឹកព្រោះយើញមរណៈនៅស្នាក់រាំងពីមុខ១, សោកទុក្ខ ទុក្ខបណ្តាលឲ្យស្តាយស្រណោះចំពោះសត្វ និង សង្ខារជាទីស្រលាញ់ដែលព្រាត់ប្រាស់ទៅ១, បរិទេវទុក្ខ ទុក្ខបណ្តាលឲ្យតំអូញរៀបរាប់ពីការកម្សត់កម្រផ្សេងៗ ចំពោះសត្វនិងសង្ខារដែលព្រាត់ទៅ១, ទុក្ខទុក្ខ ទុក្ខលំបាកតែចំណែកផ្លូវកាយដោយការនឿយហាត់ផ្សេងៗ១, ទោមនស្សទុក្ខ ទុក្ខព្រោះសេចក្តីអាក់អន់តូចចិត្តចំពោះអារម្មណ៍ដែលឃើសឃ្នាងដល់ចិត្ត១, ឧបាយាសទុក្ខ ទុក្ខបណ្តាលឲ្យអួលអាក់ក្នុងចិត្ត ព្រោះនឹកឃើញដល់សត្វនិងសង្ខារ ជាទីស្រលាញ់ដែលព្រាត់ប្រាសទៅយូរហើយ១, អប្បិយេហិសម្បយោគទុក្ខ ទុក្ខព្រោះជួបប្រសព្វសត្វនិងសង្ខារដែលមិនត្រូវចិត្ត១, បិយេហិវិប្បយោគទុក្ខ ទុក្ខព្រោះព្រាត់ប្រាសនិរាសចាកសត្វនិងសង្ខារដែលខ្លួនពេញចិត្ត១, យម្បិច្ឆំន លភតិ តម្បិ ទុក្ខំ ទុក្ខកើតមកអំពីប្រាថ្នាមិនបានដូចបំណងចង់បានរបស់ណា មិនបានរបស់នោះ១, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ទុក្ខទាំងអស់ប្រមូលមកមានតែឧបាទានក្ខន្ធទាំង ៥ ជាមេទុក្ខ ។ ទុក្ខទាំង ១២ ប្រការនេះឈ្មោះថាអភិញ្ញេយ្យធម៌ ។

“ បរិញ្ញេយ្យេ ធម្មេ សម្មាសម្ពុទ្ធោ ” សម្តេចព្រះជនេន្ទ្រសាស្តាទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរកំណត់ដឹង គឺទុក្ខសច្ច មានអង្គ ១២ ដូចបាន អធិប្បាយរួចមកហើយ ។

“ បហាតព្វេ ធម្មេ សម្មាសម្ពុទ្ធោ ” សម្តេចព្រះសព្វជ្ញទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរលះបង់ គឺសមុទយសច្ច បានដល់តណ្ហាទាំង ៣ ដោយសង្ខេបឬតណ្ហាទាំង១០៨ដោយពិស្តារ ។

“ សច្ឆិកាតព្វេ ធម្មេ សម្មាសម្ពុទ្ធោ ” សម្តេចព្រះសព្វជ្ញទ្រង់ត្រាស់ ដឹងនូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គឺនិរោធសច្ច បានដល់ព្រះនិព្វាន ដែលអ្នកប្រាជ្ញទាំងឡាយគួរធ្វើឲ្យជាក់ច្បាស់ដោយមគ្គញ្ញាណទាំង៤។

“ ភាវេតព្វេ ធម្មេ សម្មាសម្ពុទ្ធោ ” សម្តេចព្រះសព្វជ្ញទ្រង់ត្រាស់ដឹងនូវធម៌ដែលគួរចម្រើន គឺមគ្គសច្ច បានដល់អរិយមគ្គដែលប្រដាប់ដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ។

អធិប្បាយកែប្រស្នាថា " ព្រះអង្គត្រាស់ដឹងនូវធម៌អ្វី អស់សេចក្ដីដោយសង្ខេបតែប៉ុណ្ណោះ ។ តែសូមជ្រាបថា: ធម៌ដែលព្រះអង្គទ្រង់ត្រាស់ដឹងនោះមិនត្រឹមតែប៉ុណ្ណោះឡើយ, ច្រើនពេកណាស់, តែបើ និយាយឲ្យឆាប់ចប់វិញថា ព្រះអង្គត្រាស់ដឹងសព្វគ្មានចន្លោះ ។

ខ)បុ. ពាក្យថា " ព្រះអង្គត្រាស់ដឹង " នោះគួរសន្និដ្ឋានបានហើយ ចុះពាក្យថា " ដោយប្រពៃ " នោះអធិប្បាយដូចម្ដេច ?

វិ. អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងនូវធម៌ឯណា ឬធម៌ឯណាដែលព្រះអង្គត្រាស់ដឹងហើយ ធម៌នោះៗ មិនវិបរិត ប្រែប្រួល គឺមិនមានល្អៀងឃ្លាតចាកការដឹងរបស់ព្រះអង្គ ព្រោះព្រះអង្គជ្រាបដោយការជាក់លាក់ មិនបានស្មាន ឬមិនបានត្រិះរិះប្រកបយកឡើយ ។

គ)បុ. ចុះពាក្យថា " ចំពោះព្រះអង្គ " តើបានសេចក្ដីយ៉ាងណា ?

វិ. បានសេចក្តីថា: ព្រះបរមសាស្តាទ្រង់ត្រាស់ដឹងធម៌ទាំងពួងគ្មានចន្លោះ ចំពោះព្រះអង្គយ៉ាងនេះ មិនមែនត្រាស់ដឹងដោយសារបុគ្គលណាប្រៀនប្រដៅ ឬណែនាំពន្យល់ឲ្យព្រះអង្គត្រាស់ដឹងឡើយ គឺទ្រង់ត្រាស់ដឹងតែដោយកម្លាំងប្រាជ្ញាញាណរបស់ព្រះអង្គឯង ហេតុនោះទើបទ្រង់ព្រះនាមថា " សម្មា-សម្ពុទ្ធោ " ប្រែថា " ព្រះអង្គត្រាស់ដឹង ដោយប្រពៃចំពោះព្រះអង្គ " ។

ចប់បទ " សម្មាសម្ពុទ្ធោ " ដោយសង្ខេប

កែបទ " វិជ្ជាចរណសម្បន្នោ "

បុ. ចុះហេតុអ្វីបានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា " វិជ្ជាចរណសម្បន្នោ " ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា និង ចរណៈ ។

បុ. អ្វីហៅថា " វិជ្ជា " វិជ្ជាមានប៉ុន្មានយ៉ាង ?

វិ. ចំណេះ ការចេះដឹងហៅថា " វិជ្ជា " មាន ៣ក៏មាន, ៨ក៏មាន ។

បុ. វិជ្ជា ៣ តើអ្វីខ្លះ ? អធិប្បាយដូចម្តេច ?

វិ. បុព្វេនិវាសានុស្សតិវិជ្ជា១ ចុតូបបាតវិជ្ជា១ អាសវក្ខយវិជ្ជា១ ។

បុព្វេនិវាសានុស្សតិវិជ្ជា អធិប្បាយថាៈ ព្រះសាស្តាទ្រង់រឭកខន្ធរបស់ព្រះអង្គនិងខន្ធរបស់អ្នកដទៃ ដែលធ្លាប់អាស្រ័យនៅពីក្នុងកាលមុនជាអនេកជាតិ រាប់តាំងពី ១ជាតិ ២ជាតិឡើងទៅរហូតដល់អស់ សំវដ្តកប្ប វិវដ្តកប្ប សំវដ្តវិវដ្តកប្ប ជាអនេក គឺទ្រង់រឭកឃើញថាៈ កាលពីជាតិនោះកើតក្នុងភពឯណោះ មាននាមយ៉ាងនេះ គោត្រយ៉ាងនេះ ពណ៌សម្បុរយ៉ាងនេះ អាហារចិញ្ចឹមជីវិតយ៉ាងនេះ អាយុប៉ុណ្ណេះ លុះច្យុតចាកអត្តភាព

នោះមក ក៏បានទៅកើតក្នុងភពឯណោះៗ ទៀត ជាលំដាប់ ។ យ៉ាងនេះហៅថា បុព្វេនិវាសានុស្សតិវិជ្ជា ជាវិជ្ជាទី១ ដែលព្រះតថាគតបានត្រាស់ដឹងក្នុងបឋមយាមនៃរាត្រី ។

ចុតូបបាតវិជ្ជា អធិប្បាយថា: ព្រះភគវន្ត កាលបើព្រះអង្គទ្រង់ពិចារណាមើលពួកសត្វដែលទៀតច្យុត និងទើបចាប់បដិសន្ធិដោយចក្ខុទិព្វដ៏បរិសុទ្ធិក្រៃលែង ចក្ខុរបស់មនុស្សជាសាមញ្ញក៏ទ្រង់ទតឃើញ ច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា: អើហ្ន៎! សត្វពួកណា ប្រព្រឹត្តអាក្រក់ដោយ កាយ វាចា ចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវអំពើជាមិច្ឆាទិដ្ឋិ ពោលតិះដៀលព្រះអរិយ: សត្វពួកនោះ លុះដល់រំលាងខន្ធខាងមុខអំពីមរណ:ទៅក៏ចូលទៅកើតក្នុង អបាយ[1], ទុគ្គតិ[២], វិនិបាត[៣], នរក[៤], អើហ្ន៎! សត្វពួកណាប្រព្រឹត្តល្អដោយ កាយ វាចា ចិត្តជាសម្មាទិដ្ឋិ ប្រកាន់មាំនូវអំពើជាសម្មាទិដ្ឋិ មិនតិះដៀលព្រះអរិយ: សត្វពួកនោះ លុះរំលាងខន្ធខាងមុខអំពីមរណ:ទៅក៏ចូលទៅកាន់ស្ថានសុគតិ[៥] សួគ៌[៦] ។ យ៉ាងនេះហៅថា ចុតូបបាតវិជ្ជា ជាវិជ្ជាទី២

---

១ កំណើតសត្វតិរច្ឆាន ។ ២ ប្រេតវិស័យ ។ ៣ អសុរកាយ ដែលមានមហិទ្ធិរិទ្ធិដូចជារាហុអសុរិន្ទជាដើម ។ ៤ លោកដែលគ្មានសេចក្ដីចម្រើន មានប្រការច្រើនមានអវចីនរកជាដើម ។ ៥ សង្គ្រោះយកគតិរបស់មនុស្ស ។ ៦ ចំពោះយកគតិរបស់ទេវតា ។

ដែលព្រះតថាគតបានត្រាស់ដឹងក្នុងមជ្ឈិមយាមនៃរាត្រី ។

អាសវក្ខយវិជ្ជា អធិប្បាយថា: ព្រះលោកនាថទ្រង់ត្រាស់ដឹងតាមពិតថា: នេះទុក្ខ, នេះហេតុបណ្តាលឲ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះឧបាយនាំឲ្យបានរលត់ទុក្ខ, ធម៌ប៉ុណ្ណេះហៅថា អាសវៈ ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ នេះជាសេចក្តីរំលត់នៃអាសវៈ នេះជាឧបាយនាំឲ្យរលត់អាសវៈ ។ យ៉ាងនេះហៅថា អាសវក្ខយវិជ្ជា ជាវិជ្ជាទី៣ ដែលព្រះតថាគតទ្រង់បានត្រាស់ដឹងក្នុងបច្ឆិមយាមនៃរាត្រី ។

បុ. ចុះវិជ្ជា ៨ អ្វីខ្លះ ?

វិ. វិបស្សនាវិជ្ជា១ មនោមយិវិជ្ជា១ ឥទ្ធិវិធិវិជ្ជា១ ទិព្វសោតវិជ្ជា១ ចេតោបរិវិជ្ជា១ រួមនិងវិជ្ជា ៣ ខាងដើម ត្រូវជា ៨ ប្រការ ។

បុ. ដូចម្តេចហៅថា វិបស្សនាវិជ្ជា ?

វិ. អនិច្ចាទីវសេន នាមរូបំ វិបស្សតិ ឧបបរក្ខិយតីតិ វិបស្សនា បញ្ញាដែលពិចារណាឃើញជាក់ច្បាស់នូវនាម[1] និងរូប[២] ដែលលុះដោយអំណាចនៃព្រះត្រៃលក្ខណ៍មានអនិច្ច-

១ បានដល់អរូបក្ខន្ធ ៤ គឺ វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, ។ ២ បានដល់រូប ២៨ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


លក្ខណៈជាដើមហៅថា " វិបស្សនា[1] " ។ វិបស្សនានេះឯងចាត់ជាវិជ្ជា១ ដែលព្រះសាស្តាទ្រង់មានមុនវិជ្ជាទាំង ៧ ព្រោះវិជ្ជានេះ ជាគ្រឿងឈ្វេងយល់នូវព្រះត្រៃលក្ខណ៍ថាៈ នាមនិងរូបមិនទៀងទាត់មិនឋិតថេរចិរកាលយូរលង់ តែងដឹកជញ្ជូនបង្វែរមក

---

១ មាន ១០ យ៉ាងគឺ:

១- សមសនញ្ញាណ បញ្ញាពិចារណាឃើញសង្ខារដោយអនិច្ចាទិលក្ខណៈ ។

២- ឧទយព្វយញ្ញាណ បញ្ញាពិចារណានូវសភាពកើតឡើងនិងរលត់សូន្យទៅនៃសង្ខារ ។

៣- ភង្គញ្ញាណ បញ្ញាពិចារណានូវកិរិយាបែកធ្លាយនៃសង្ខារគឺឃើញថាជាឧប្បាទ, វេតិភង្គ, ឧប្បាទ, ជាជាតិទុក្ខ, ឋិតិ ជាជរាទុក្ខ, ភង្គ ជាមរណទុក្ខ ។

៤- ភយញ្ញាណ បញ្ញាពិចារណាឃើញសង្ខារថាជាធម្មជាតិគួរខ្លាច ដូចជាខ្លាចសត្វសាហាវមានរាជសីជាដើម ។

៥- អាទីនវញ្ញាណ បញ្ញាពិចារណាឃើញទោសរបស់សង្ខារមិនគួរឲ្យស្ម័គ្រចិត្ត ដូចគេឃើញផ្ទះដែលភ្លើងឆេះហើយភៀស ខ្លួនចេញពីផ្ទះនោះ ។

៦- និព្វិទាញាណ បញ្ញាពិចារណាឃើញទោសក្នុងសង្ខារហើយធុញទ្រាន់នឿយណាយ ។

៧- មុញ្ចិតុកាម្យតាញាណ បញ្ញាពិចារណាចង់ដោះខ្លួនឲ្យរួចពីខន្ធ ៥ ប្រៀបដូចជាត្រីចង់រួចចាកពីគោក ឬដូចជាមនុស្ស ទោសចង់រួចពីគុកច្រវាក់ខ្នោះឃ្នាង ។

៨- បដិសង្ខារញ្ញាណ បញ្ញាពិចារណារកឧបាយដែលនឹងឲ្យដោះខ្លួនរួចពីខន្ធ ៥ ។

៩- សង្ខារុបេក្ខាញាណ បញ្ញាតាំងឧបេក្ខាគឺតោះតើយមិនសោមនស្ស មិនទាស់ចិត្តដូចបុរសដែលព្រងើយកន្តើយនឹង ប្រពន្ធដែលលែងលះគ្នាស្រឡះហើយ ។

១០- អនុលោមញ្ញាណ បញ្ញាដែលអនុលោមតាមព្រះអរិយមគ្គ ទាំងខាងក្នុងខាងក្រៅ ។

នូវកងទុក្ខ នឹងមិនមែនជាខ្លួនប្រាណមិនលុះតាមបង្គាប់ ជាធម្មជាតិឃាត់មិនបាន ។ លុះឈ្វេងយល់យ៉ាងនេះហើយ ទើបឃើញអរិយសច្ចទាំង ៤ ។ ព្រះជាគ្រូទ្រង់ផ្ចាញ់មារាធិរាជព្រមទាំងសេនាឲ្យបរាជ័យដោយបារមីទាំង ១០ ហើយស្តេចចូលកាន់សមាបត្តិ, ដល់ចេញចាកសមាបត្តិមកវិញ ទើបស្តេចកាន់យកវិបស្សនា បញ្ញាចាក់ធ្លុះមើលសង្ខារតាមប្រពៃណីព្រះពុទ្ធអំពីបុរាណឃើញថាជា អនិច្ចំ ទុក្ខំ អនត្តា ហើយទើបចាក់ធ្លុះអរិយសច្ចទាំង៤ ប្រការថា: ទុក្ខសច្ចមានខន្ធ ៥ជាមេទុក្ខគួរឲ្យខ្លាច ប្រៀបដូចជាមេខ្មាំង ៥ នាក់តាមពាធាឃាឃីជា ធម្មតា, សមុទយសច្ច តណ្ហាទាំង៣ ប្រការដូចជាអ្នកបង្ហាញផ្លូវខ្មាំងឲ្យចូលមក និរោធសច្ច ព្រះនិព្វានជាគ្រឿងបិទស្ទះដំណើរខ្មាំង, មគ្គសច្ច អដ្ឋង្គិកមគ្គទាំង ៨ ជាឧបាយនឹងសម្លាប់ពួកខ្មាំង ។

លុះរកកំណើតសេចក្តីទុក្ខឃើញ ដោយវិបស្សនាបញ្ញាយ៉ាងនេះហើយ ទើបទ្រង់លះសំយោជនៈ ៣ គឺសក្កាយទិដ្ឋិ, វិចិ-

កិច្ចា, សីលព្វតុបរាមាសៈ, ដោយកម្លាំងសោតាបត្តិមគ្គញ្ញាណ, លះកាមរាគ, ព្យាបាទ យ៉ាងគ្រោតគ្រាតដោយសកទាគាមិមគ្គ-ញ្ញាណ, លះកាមរាគ ព្យាបាទ យ៉ាងល្អិតដោយអនាគាមិមគ្គ-ញ្ញាណ, លះសំយោជនៈ៥ គឺរូបរាគៈ, អរូបរាគៈ, មានៈ, ឧទ្ធច្ចៈ, អវិជ្ជា , ដោយអរហាត្តមគ្គញ្ញាណ ។ គ្រានោះ សន្តានរបស់ព្រះអង្គបរិសុទ្ធិក្រៃលែង, អរហត្តផលក៏កើតឡើង វិជ្ជាទាំង ៧ ក្រៅពីនេះទើបកើតមកជាខាងក្រោយ ។ ហេតុនោះទើបចាត់ថាវិបស្សនាវិជ្ជាកើតមុនវិជ្ជាទាំងពួង ឬនឹងជាព្រះសាស្តាទ្រង់បានវិជ្ជានេះ តាំងពីកាលនៅគ្រប់គ្រងរាជសម្បត្តិនៅឡើយក៏សឹងបាន ក្នុងគ្រាដែលទ្រង់ទតឃើញទេវទូតទាំង ៣ ខាងដើមគឺមនុស្សជរា មនុស្សឈឺ មនុស្សស្លាប់ ព្រោះដោយសារតែរឿងនេះហើយ ទើបទ្រង់ព្រះសង្វេគជាខ្លាំងទ្រាំនៅពុំបានដល់ថ្នាក់ចេញចោលរាជសម្បត្តិទៅទ្រង់ព្រះផ្នួស ។

មនោមយិទ្ធិវិជ្ជា គឺវិជ្ជាដែលចេះថ្លែងរិទ្ធិធ្វើចិត្តឲ្យទៅជារូបបាន អធិប្បាយថាៈ ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គមានវិជ្ជាអាច

នឹងនិមិត្តចិត្ត ខាងក្នុងឲ្យទៅជារូបកាយផ្សេងចេញពីកាយនេះ មកបានប្រាកដ ដូចជាទាញហ្វតបណ្ដូលស្មៅយាប្លងចេញពីដើម ។

ឥទ្ធិវិធិវិជ្ជា គឺវិជ្ជាដែលចេះសម្ដែងរិទ្ធិបាន ដោយប្លែងឬអធិដ្ឋាន, អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់មានអាចនឹងប្លែងឬអធិដ្ឋានមនុស្ស ម្នាក់ឲ្យទៅជាច្រើននាក់បាន, ច្រើននាក់ឲ្យរួមមកនៅតែម្នាក់ក៏បាន ឬប្លែងរបស់នេះឲ្យទៅជារបស់នោះៗ ឲ្យមកជារបស់នេះក៏បានឥតទើសទាក់ ។

ទិព្វសោតវិជ្ជា គឺវិជ្ជាដែលអាចស្ដាប់សូរសព្ទសំឡេងបានដូចជាទិព្វសោត, អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់មានវិជ្ជាអាចស្ដាប់សូរសំលេងមនុស្ស និង ទេវតា ដែលស្ថិតនៅក្នុងទីជិតឆ្ងាយយ៉ាងណាក៏បានទាំងអស់ ។

ចេតោបរិយវិជ្ជា គឺវិជ្ជាអាចកំណត់ដឹងចិត្តអ្នកដទៃបាន, អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបទឹកចិត្តសត្វដទៃបានប្រាកដថា: ចិត្តនេះជាបុណ្យ នេះជាបាប នេះអស់រាគៈ

ហើយ នេះមានរាគៈ នៅឡើយជាដើម ។ រួបរួមវិជ្ជាទាំង ៥ នេះផ្សំនិងវិជ្ជា ៣ខាងដើមត្រូវជាវជ្ជា[1]៨ ។

បុ. អ្វីហៅថា " ចរណៈ " ? មានប៉ុន្មានយ៉ាង ?

វិ. ក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ឬសេចក្តីប្រព្រឹត្តដែលជាដំណើរទៅកាន់អមតមហានិព្វានហៅថា " ចរណៈ " មាន ១៥ យ៉ាងគឺ សីលសំវរៈ សង្រួមរក្សាបាតិមោក្ខសំវរសីលម៉ត់ចត់១, ឥន្ទ្រិយសំវរៈ សង្រួមឥន្ទ្រិយទាំង៦ គឺចក្ខុន្ទ្រីយ៍ សោតិន្ទ្រីយ៍ ឃានិន្ទ្រីយ៍ ជិវ្ហិន្ទ្រីយ៍ កាយិន្ទ្រីយ៍ មនិន្ទ្រីយ៍ បិទផ្លូវមិនឲ្យបាបធម៌គឺ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ចូលមកក្នុងសន្តានបាន១ ភោជនេមត្តញ្ញុតា, ភាពជាអ្នកដឹងប្រមាណក្នុងភោជន១ ជាគរិយានុយោគៈ ប្រកបកិរិយាភ្ញាក់រឭកជានិច្ចគឺប្រាស់ចាក ថីនមិទ្ធ១ សទ្ធា ចិត្តថ្លាស្អាតបរិសុទ្ធិប្រាសចាកបាបធម៌ទាំងពួង១ សតិ សេចក្តីរឭកដឹងខ្លួនជានិច្ច១ ហិរិ សេចក្តី

---

១- ន័យខ្លះរាប់យកវិបស្សនាវិជ្ជា ១ មនោមយិទ្ធិវិជ្ជា១ ឥទ្ធិវិធីវិជ្ជា១ ជាវិជ្ជា ៣ ។ វិជ្ជា ៨ រាប់យកអភិញ្ញា ៥ គឺ ទិព្វចក្ខុវិជ្ជា១ ទិព្វសោតវិជ្ជា១ បរចិត្តវិជ្ជា១ បុព្វេនិវាសវិជ្ជា១ អាសវក្ខយវិជ្ជា១ ជា ៥ ផ្សំនឹងវិជ្ជា ៣ ខាងដើមជាវិជ្ជា ៨ ។

ខ្ចាស់បាប១ ឱតប្បៈ សេចក្តីក្តៅក្រហាយឬស្ញើបនឹងបាប១ ពាហុសច្ចៈ សេចក្តីចេះចាំច្រើន១ ឧបក្កមៈ សេចក្តីប្រឹងប្រែង ប្រកបដោយសម្មប្បធានវីរិយ១ មតិ យល់ប្រកបដោយបញ្ញាធិប្បាយដ៏ច្រើន១ អបរិហីនរូបាវចរជ្ឈានំ រូបាវចរជ្ឈាន៤ ដែលមិនបានសាបសូន្យរាប់ជា៤ ផ្សំគ្នាជាចរណៈ១៥ ។

សម្តេចព្រះមហាករុណាបរិបូណ៌ដោយវិជ្ជា ៣ វិជ្ជា ៨ ចរណៈ ១៥ ដូចពណ៌នាមកនេះ ទើបទ្រង់ព្រះនាមថា " វិជ្ជាចរណសម្បន្នោ " ។

ចប់បទ " វិជ្ជាចរណសម្បន្នោ " ដោយសង្ខេប

## កែបទ " សុគតោ "

បុ. ព្រះជាគ្រូ ហេតុដូចម្តេច បានជាទ្រង់ព្រះនាមថា " សុគតោ " ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គមានព្រះដំណើរល្អផង ព្រោះព្រះអង្គមានព្រះបន្ទូលពីរោះផង ។

បុ. ដែលថា " ព្រះអង្គមានព្រះដំណើរល្អ " នោះតើល្អយ៉ាងដូចម្តេច?

វិ. ព្រះអង្គមានព្រះដំណើរល្អគួរឲ្យសត្វលោកភ្លូកភ្លឹក, មានព្រះដំណើរល្អទៅកាន់ទីស្អាត, មានព្រះដំណើរល្អគួរឲ្យកើតសេចក្តីជ្រះថ្លាដល់មហាជន, មានព្រះដំណើរល្អយាងទៅកាន់អមតមហានិព្វាន ។

ក) ដែលថា " មានព្រះដំណើរល្អគួរឲ្យសត្វលោកភ្លូកភ្លឹក " អធិប្បាយថា: ព្រះអង្គទ្រង់មានព្រះដំណើរយាងយាសសមសោភាឥតឆ្គង មុខគួរឲ្យសត្វផងពិតពិលរមិលមើល ដូចគ្រាដែលទ្រង់ទើបបានត្រាស់ជាដំបូង ស្តេចចេញចាកពោធិមណ្ឌល យាងតាមមាគ៌ាដោយព្រះបាទាដ៏ប្រកបដោយលាយ

លក្ខណ៍កង់ចក្រ មានឆព្វណ្ណរង្សីឆ្លុះព្រោងព្រាយ ឆ្ពោះព្រះភក្ត្រទៅកាន់ឥសិបតនមិគទាយវ័ន ។ គ្រានោះ កើតរំជួលដល់ពួកទេពនិករ នាំគ្នាហោះចាកទីស្ថានមកហែរហាមអមដំណើរព្រះអង្គ, មិនត្រឹមតែពួកទេពនិកាយប៉ុណ្ណោះ, សូម្បីពួកម្រឹគីម្រឹគាក៏នាំគ្នាមកឈររហាង់ក្បែរអង្គព្រះជិនស្រី ទាំងពួកបក្សាបក្សីក៏នាំគ្នាបោះពួយឆ្វៀលឆ្វាត់មកសំកាំងស្លាបនៅនាទី ដែលព្រះអង្គស្ដេចយាងទៅ, ទាំងនេះក៏មកតែពីព្រះអង្គមានព្រះខន្ធសន្ដានស្អាតបរិសុទ្ធិ ទើបមានព្រះដំណើរឥតឆ្គងគួរឲ្យសត្វផងពិតពិលរមិលមើល ។ មិនតែគ្រាមួយនេះទេ តមកវេលាដែលព្រះអង្គទ្រង់យាងចូលទៅកាន់ទីសមាគមណាៗ ក៏តែងមានពួកទេវនិករ និង មនុស្សនិករភ្លូកភ្លឹកគឹកកងមកគយគន់មើលព្រះដំ-ណើរយាងយាសរបស់ព្រះអង្គ ។ ហេតុនេះទើបបានវិសជ្ជនាថា: " ព្រះអង្គមានព្រះដំណើរល្អគួរឲ្យសត្វលោកភ្លូកភ្លឹក " ។

ខ) ដែលថា " ព្រះអង្គមានព្រះដំណើរល្អទៅកាន់ទីស្អាត " អធិប្បាយថា: ព្រះពិជិតមារកាលបើទ្រង់យាងទៅកាន់ទីណាទីនោះទោះជាទីស្មោគគ្រោកយ៉ាងណាក្ដី ក៏គង់នឹងប្រែក្លាយទៅ

ជាទីស្អាតបរិសុទ្ធិវិញ ដូចគ្រាដែលក្រុងវេសាលីកើតមានភ័យអំពីអហិវាតរោគ នឹងមានពួកអមនុស្សបៀតបៀនជាច្រើន និងទុរ្ភិក្សអំណត់អត់ឃ្លាន អ្នកស្រុកស្លាប់ដេរដាសសព្វអន្លើម្លោះហើយព្រះនគរទាំងមូលទៅជាមិនស្អាត ពាសពេញទៅដោយសាកអសុភ ។ ពួកស្តេចលិច្ឆវីជាម្ចាស់ព្រះនគរ មកអារាធនាព្រះសម្ពុទ្ធឲ្យស្តេចទ្រង់យាងទៅ, ព្រះអង្គស្តេចមិនទាន់យាងទៅដល់ផង ក៏ពួកទេវតាបណ្តាលភ្លៀងយ៉ាងធំធ្លាក់ចុះមកបន្សាត់សាកអសុភទាំងនោះតាមស្ទឹង ឲ្យចូលទៅកាន់មហាសមុទ្រទាំងអស់ មិនឲ្យមានសេសសល់ នគរនោះទៅជាស្អាតបរិសុទ្ធិគួរដល់ព្រះពុទ្ធដំណើរស្តេចយាងមក ។ ហេតុនេះបានជាវិសជ្ជនាថា " ព្រះអង្គមានព្រះដំណើរល្អយាងទៅកាន់ទីស្អាត " ។

គ) ដែលថាៈ " ព្រះអង្គមានព្រះដំណើរល្អគួរឲ្យកើតសេចក្តីជ្រះថ្លាដល់មហាជន " អធិប្បាយថាៈ ព្រះលោកនាថជាម្ចាស់ ទ្រង់មានព្រះគុណគួរឲ្យសត្វជ្រះថ្លា ៤ ប្រការដែលហៅថា " បមាណ " គឺៈ

Websites: WatKhemaraRatanaram.org or WatKhmers.org


១- រូបប្បមាណៈ ទ្រង់មានព្រះរូបសក្តិសមល្អប្រកបដោយមហាបុរិសលក្ខណៈ៣២និងអនុព្យញ្ជនៈ ៨០ ល្អរកមនុស្សទេព្តាណាផ្ទឹមគ្មាន ។

២- ឃោសប្បមាណៈ ទ្រង់មានព្រះសូរសៀងដ៏ពីរោះក្រៃលែង ប្រៀបដូចសម្លេងព្រហ្ម ឬសម្លេងសត្វករវីក ។

៣- ធម្មប្បមាណៈ ទ្រង់ជ្រាបធម៌ជ្រៅជ្រះលើសលប់អ្នកប្រាជ្ញទាំងពួង ។

៤- លូខប្បមាណៈ ទ្រង់មានអធ្យាស្រ័យល្អ មិនចេះរើសថាៈ របស់នេះសៅហ្មង នេះថោកទាប នេះអន់ណាស់ ដូច្នេះឡើយ ។ បើសត្វពួកណាត្រូវការខាងរូប, សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយរូប ព្រោះព្រះអង្គទ្រង់មានរូបល្អ, បើសត្វពួកណាត្រូវការខាងសម្លេង សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយសម្លេង ព្រោះព្រះអង្គមានព្រះសូរសៀងពីរោះ រកសំឡេងរបស់មនុស្សពួកណាមួយនឹងយកមកប្រៀបផ្ទឹមពុំបាន, បើសត្វពួកណាត្រូវការតែខាងធម៌ សត្វពួកនោះនឹងជ្រះថ្លាក្នុងព្រះអង្គដោយធម៌ព្រោះព្រះអង្គឈ្លាសវៃក្នុងការសម្តែងធម៌ លើសលែង

អ្នកប្រាជ្ញទាំងពួងក្នុងត្រៃលោក, បើសត្វពួកណាជាអ្នកកំសត់ទុគ៌តប្រាថ្នានឹងថ្វាយបច្ច័យណាមួយដល់ព្រះអង្គ ទោះរបស់នោះថោកទាបយ៉ាងណាក្តី ទ្រង់ក៏អាចទទួលប្រើប្រាស់បានដោយយ៉ាងស្និទ្ធឥតមានច្បិចច្បើម ។ ទំនងនេះហើយដែលនាំឲ្យព្រះអង្គបានជាទីជ្រះថ្លាដល់មហាជន ។ កាលបើយ៉ាងនេះទោះបីព្រះអង្គទ្រង់ពុទ្ធដំណើរទៅកាន់ទីណាក្តី ក៏ឥតមានរលកអង្គំ, សត្វពួកណាដែលមិនទាន់ជ្រះថ្លានៅឡើយ ក៏កើតជ្រះថ្លាឡើង សត្វពួកណាដែលជ្រះថ្លាស្រាប់ ក៏រឹងរិតតែជ្រះថ្លាជាភិយ្យោភាពឡើង ។ ហេតុនេះបានជាវិសជ្ជនាថា " ព្រះអង្គទ្រង់មានពុទ្ធដំណើរល្អគួរឲ្យកើតសេចក្តីជ្រះថ្លាដល់មហាជន " ។

ឃ) ដែលថា " ព្រះអង្គមានដំណើរល្អយាងទៅកាន់អមតមហានិព្វាន " អធិប្បាយថា: ព្រះអង្គស្តេចទ្រង់មានពុទ្ធដំណើរទៅកាន់ទីដែលមិនធ្លាប់ទៅគឺព្រះនិព្វាន មិនមានញញើតរុញរាពីព្រោះទ្រង់មាន ខន្ធសន្តានស្អាតបរិសុទ្ធិ ឥតមានជិតដាមដោយកិលេសៗ ណាដែលទ្រង់លះបានហើយ កិលេសនោះលែងត្រឡប់មករកព្រះអង្គវិញ, ព្រះអង្គក៏លែងត្រឡប់ទៅរកកិលេសទាំងនោះវិញដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ទំនងដែលព្រះអង្គលះកិលេសនោះដូច្នេះគឺ ទ្រង់លះសក្កាយ-ទិដ្ឋិ, វិចិកិច្ឆា, សីលព្វតូបរាមាស, ទិដ្ឋានុសយៈ និងវិចិកិច្ឆានុសយ ដោយអំណាចសោតាបត្តិមគ្គ, លះកាមរាគសំយោជនៈ បដិឃា-នុសំយោជនៈ, កាមរាគានុសយៈ បដិឃានុសយៈ យ៉ាងគ្រោត គ្រាតដោយអំណាចសកទាគាមិមគ្គ, លះកាមរាគសំយោជនៈ, បដិឃសំយោជនៈ កាមរាគានុសយៈ, បដិឃានុសយៈ យ៉ាងល្អិត ដោយអំណាចអនាគាមិមគ្គ, លះរូបរាគៈ, មានៈ, ឧទ្ធច្ចៈ, អវិជ្ជា, មានានុសយៈ, ភវរាគានុសយៈ, អវិជ្ជានុសយៈ, ដោយ អំណាចអរហត្តមគ្គ ។ កិលេសទាំងឡាយដែលព្រះអង្គទ្រង់ លះបានដោយអរិយមគ្គនោះៗ ហើយ មិនដែលត្រឡប់មក កើតក្នុងសន្តានព្រះអង្គវិញឡើយ ។ ហេតុនេះហើយ ទើប វិសជ្ជនាថា " ព្រះអង្គមានដំណើរយាងទៅកាន់អមតមហា និព្វាន " ។

បុ. ចុះត្រង់ដែលវិសជ្ជនាថា " ព្រះអង្គមានបន្ទូលពីរោះ នោះតើអធិប្បាយដូចម្តេច " ?

វិ. អធិប្បាយាថាៈ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជ្រាបច្បាស់នូវ ពាក្យពិតនិងមិនពិត, មានប្រយោជន៍និងឥតប្រយោជន៍ ត្រូវ

ចិត្តសត្វនិងមិនត្រូវចិត្តសត្វ ។ បើពាក្យឯណាមិនពិត, ឥត ប្រយោជន៍ និងមិនត្រូវចិត្តនោះ ព្រះអង្គមិនមានព្រះបន្ទូល ឡើយ, ពាក្យឯណាដែលពិត មានប្រយោជន៍ ត្រូវចិត្តសត្វ ទើបព្រះអង្គទ្រង់មានព្រះបន្ទូល ដើម្បីនឹងធ្វើពាក្យនោះឲ្យ សម្រេចប្រយោជន៍ដល់អ្នកស្តាប់, បើពាក្យឯណាមិនពិត ឥត ប្រយោជន៍ ទុកណាជាត្រូវចិត្តសត្វ ក៏ព្រះអង្គមិនទ្រង់មានព្រះ បន្ទូលដែរ, លុះតែពាក្យពិតផង មានប្រយោជន៍ផង ត្រូវចិត្ត សត្វផង ទើបព្រះអង្គមានព្រះបន្ទូល ។ ដូចមានកាល ថ្ងៃមួយ សម្តេចព្រះជិនស្រីទ្រង់មានព្រះពុទ្ធដំណើរទៅក្បែរដើម ឈើមួយ យកព្រះហស្តចាប់ស្លឹកឈើមួយក្តាប់ហើយត្រាស់ សួរទៅអានន្ទថា: អានន្ទ! ស្លឹកឈើដែលនៅក្នុងកណ្តាប់ដៃតថា-គត នេះហើយនឹងស្លឹកឈើដែលនៅសល់លើផែនដីណាច្រើនជាង ណា ព្រះអានន្ទក្រាបទូលស្នងព្រះពុទ្ធដីកាថា: បពិត្រព្រះអង្គ ដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ស្លឹកឈើដែលស្ថិតនៅក្នុង ព្រះហស្តព្រះអង្គតិចណាស់ ស្លឹកឈើក្រៅពីនោះច្រើនពន់ពេក ។ ព្រះអង្គទ្រង់ត្រាស់ផ្ទួនសេចក្តីនោះឲ្យប្រាកដឡើងថា អើអានន្ទ! ធម៌វិន័យដែលតថាគតបានត្រាស់ដឹងច្រើនពេកណាស់ តែធម៌

ដែលតថាគតបានសម្ដែងទុកជាឱវាទ ដល់អ្នករាល់គ្នានោះតិចតួចទេ ដូចជាស្លឹកឈើដែលនៅក្នុងកណ្ដាប់ដៃតថាគត, ធម៌ដែលសល់នៅតថាគតមិនបានសម្ដែង នោះច្រើនពេកណាស់ ដូចជាស្លឹកឈើដែលនៅលើផែនដីទាំងប៉ុន្មាន, ព្រោះហេតុអ្វី ? ព្រោះតថាគតសម្ដែងតែធម៌ណាពិត ហើយមានប្រយោជន៍ច្រើនដល់សត្វអ្នកប្រតិបត្តិ ។

ពិតមែនវិន័យរបស់ព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គទ្រង់បានត្រាស់សម្ដែងទុក តាំងអំពីទ្រង់បានត្រាស់ដឹងឡើង ដរាបដល់ចូលកាន់ព្រះបរមនិព្វាន ក៏សុទ្ធតែធម៌ពិតវិន័យពិត ប្រព្រឹត្តទៅមួយអន្លើដោយប្រយោជន៍ អាចឲ្យសម្រេចសេចក្ដីសុខគ្រប់ប្រការដល់សត្វអ្នកប្រតិបត្តិតាម ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់មានព្រះនាមថា " សុគតោ " ប្រែថា " ព្រះអង្គទ្រង់មានព្រះបន្ទូលដ៏ពីរោះ " ដូច្នេះ ។

ចប់បទ " សុគតោ " ដោយសង្ខេប

កែបទ " លោកវិទូ "

បុ. ព្រះមុនិន្ទសាស្តាចារ្យជាម្ចាស់ ហេតុអ្វីបានជាទ្រង់ព្រះនាមថា " លោកវិទូ " ?

វិ. បានជាទ្រង់ព្រះនាមដូច្នេះ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក។

បុ. សភាពដូចម្តេចដែលហៅថា " លោក " មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. សភាពដែលតែងតែវិនាសបាត់បង់សូន្យទៅហៅថា " លោក " លោកនេះមាន៣ យ៉ាងគឺ សង្ខារលោក[1]១ សត្តលោក១ ឱកាសលោក១ ។

បុ. ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបច្បាស់នូវសង្ខារលោកដូចម្តេចខ្លះ ?

វិ. " អាហារសង្ខារលោកំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក១ គឺ កវឡិង្ការាហារ បានដល់អាហារដែលជាពុំនូត១ សម្រាប់ចិញ្ចឹមជីវិតសត្វ ។

---

១ ន័យខ្លះថាបានដល់ខន្ធទាំង ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២

" នាមរូបសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក២គឺ នាម(1) រូប(២) ។

" តិវិធវេទនាសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក៣ គឺ វេទនាទាំង៣ សុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខវេទនា១ ។

" ចតុរាហារសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៤ គឺអាហារ ៤ កវឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។ កវឡិង្ការាហារ នាំមកនូវរូប ៨ គឺៈ បថវី ១ អាបោ ១ តេជោ ១ វាយោ ១ វណ្ណោ ១ គន្ធោ ១ រសោ ១ ឱជា ១ ។ ផស្សាហារ នាំមកនូវវេទនា ៣ គឺ សុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខវេទនា១ ។ មនោសញ្ចេតនាហារ នាំមកនូវបដិសន្ធិក្នុងភពទាំង ៣ គឺ កាមភព១ រូបភព១ អរូបភព១ ។ វិញ្ញាណាហារ នាំមកនូវនាម និង រូបក្នុងបដិសន្ធិខណៈ ។

---

១ ចិត្ត ៨១ ដួងនិងចេតសិក ៥២ ហៅថា " នាម " ។ ២ រូប ២៨ គឺមហាភូតរូប ៤ ឧបាទាយរូប ២៤ ហៅថា " រូប " ។ ក៏ឯនាមនិងរូបនេះលុះតែអាស្រ័យនូវគ្នានិងគ្នាទៅវិញទៅមកទើបប្រព្រឹត្តទៅបាន ឧបមាដូចជានាវានឹងអ្នកកាន់ចង្កូត, មួយទៀតឧបមាដូចជាមនុស្ស ២ នាក់ ១ខ្វាក់ ១ ខ្វិន មនុស្សខ្វាក់បានជើង មនុស្សខ្វិនបានភ្នែក អាស្រ័យគ្នានិងគ្នាទៅបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org


" បញ្ចុបាទានក្ខន្ធសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៥ គឺ ឧបាទានក្ខន្ធ ៥ រូបូបាទានក្ខន្ធ១ វេទនូបាទានក្ខន្ធ១ សញ្ញូបាទានក្ខន្ធ១ សង្ខារូបាទានក្ខន្ធ១ វិញ្ញាណូបាទានក្ខន្ធ១ ។

" ឆអជ្ឈត្តិកាយនសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៦ គឺ អាយតនៈខាងក្នុង៦ ចក្ខ្វាយតនៈ១ សោតាយតនៈ១ ឃានាយតនៈ១ ជិវ្ហាយតនៈ១ កាយាយតនៈ១ មនាយតនៈ១ ។

" សត្តវិញ្ញាណដ្ឋិតិសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៧ គឺ វិញ្ញាណដ្ឋិតិ ៧ នានត្តកាយា នានត្តសញ្ញី សត្វមានកាយផ្សេងគ្នាមានសញ្ញាក៏ផ្សេងគ្នា១ នានត្តកាយា ឯកត្តសញ្ញី សត្វមានកាយផ្សេងគ្នាមានសញ្ញាត្រូវគ្នា១ ឯកត្តកាយា នានត្តសញ្ញី សត្វមានកាយត្រូវគ្នាមានសញ្ញាផ្សេងគ្នា១ ឯកត្តកាយា ឯកត្តសញ្ញី សត្វមានកាយត្រូវគ្នាមានសញ្ញាក៏ត្រូវគ្នា១ អាកាសានញ្ចាយតនៈ១ វិញ្ញាណញ្ចាយតនៈ១ អកិញ្ចញ្ញាយតនៈ១ ។ ពួកទេវតានិងវិនិបាតិកប្រេត មានរូបកាយផ្សេងគ្នា មានបដិសន្ធិផ្សេងគ្នា ពួកមនុស្សមានរូបកាយផ្សេងគ្នា មាន

បដិសន្ធិក៏ផ្សេងគ្នា ខ្លះជាអហេតុកៈ ខ្លះជាទុហេតុកៈ ខ្លះជាត្រៃហេតុកៈ, សត្វពួកនេះឈ្មោះថាមានកាយផ្សេងគ្នា មានសញ្ញាក៏ផ្សេងគ្នា, អបាយិកសត្វគឺ សត្វដែលកើតក្នុងអបាយភូមិមានរូបផ្សេងៗគ្នា ខ្លះខ្ពស់ ខ្លះទាប ខ្លះតូច ខ្លះធំជាដើម ដូចពួកឃោដបិដ្ឋប្រេត មានកំពស់តាំងពី ១យោជន៍រហូតដល់ ១០យោជន៍ក៏មាន តែបដិសន្ធិដូចគ្នា គឺឧបេក្ខាសន្តីរណៈខាងអកុសលវិបាកអហេតុកៈដូចគ្នា ។ ពួកព្រហ្មក្នុងបឋមជ្ឈានភូមិ ៣គឺ ព្រហ្មបារិសជ្ជា១ ព្រហ្មបរោហិតា១ មហាព្រហ្មា១ ព្រហ្មទាំង៣ ពួកនេះមានរូបផ្សេងៗគ្នា, មហាព្រហ្មរូបរាងធំនិងវិសេសជាងព្រហ្មបរោហិតា១ មានរូបរាងធំនិងវិសេសជាងព្រហ្មបារិសជ្ជា តែតួបដិសន្ធិ ជាមួយគ្នា គឺបឋមជ្ឈានវិបាកដូចគ្នាទាំង៣ភូមិ សត្វពួកនោះឈ្មោះថា មានកាយផ្សេងគ្នាមានសញ្ញាដូចគ្នា ។ ពួកព្រហ្មក្នុងទុតិយជ្ឈានភូមិ៣គឺៈ បរិត្តាភា១ អប្បមាណាភា១ អាភស្សរា១ មានរូបរាងធំប្រហែលគ្នា តែតួបដិសន្ធិផ្សេងគ្នា ខ្លះតួបដិសន្ធិជាទុតិយជ្ឈានវិបាក ខ្លះជាតតិយជ្ឈានវិបាក, ដូច្នេះឈ្មោះថាមានកាយដូចគ្នាមានសញ្ញាផ្សេងគ្នា១ ពួកព្រហ្មក្នុងតតិយជ្ឈានភូមិ៣ គឺៈ

បរិត្តសុភា១ អប្បមាណសុភា១ សុភកិណ្ហា១ មានរូបរាងប្រហែល ៗ គ្នា តួបដិសន្ធិក៏ប្រហែលគ្នាតែតតិយជ្ឈានវិបាកដូចគ្នា, សត្វពួកនេះឈ្មោះថាមានកាយដូចគ្នា មានសញ្ញាក៏ដូចគ្នា ។ ពួកព្រហ្មក្នុងជាន់សុទ្ធាវាសភូមិ ៥ គឺ អវិហា១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋកា ១[1] មានរូបកាយ ប្រហែលៗ គ្នា ទាំងតួបដិសន្ធិក៏ដូចគ្នា, សត្វពួកនេះឈ្មោះថា មានកាយដូចគ្នាមានសញ្ញាក៏ដូចគ្នា ។ ឯសង្ខារធម៌របស់អសញ្ញីសត្វ មិនបានរាប់បញ្ចូលក្នុងវិញ្ញាណដ្ឋិតិ ណាមួយទេ ពីព្រោះសត្វពួកនេះបដិសន្ធិដោយរូប ។ សង្ខារធម៌របស់អរូបព្រហ្មក្នុងជាន់អាកាសានញ្ចាយតនៈ១ វិញ្ញាណញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ ចាត់ជាវិញ្ញាណដ្ឋិតិមួយៗ ឈ្មោះថា ឯកត្តសញ្ញី មានសញ្ញាដូចគ្នាតាមជាន់របស់ខ្លួន ព្រោះពួកព្រហ្មក្នុងជាន់អាកាសានញ្ចាយតនៈ បដិសន្ធិដោយ

---

១ សុទ្ធាវាសភូមិ ៥ ជាន់នេះ ជាទីលំនៅនៃព្រះអនាគាមិនិងព្រះអរហន្ត ។ អាយុព្រហ្មក្នុងសុទ្ធាវាសភូមិទាំង ៥ ជាន់ មួយម៉ឺនប្រាំមួយពាន់មហាកប្ប បើដល់កំណត់មួយម៉ឺនប្រាំមួយពាន់មហាកប្បនោះហើយ មិនមានព្រះពុទ្ធជាម្ចាស់បានត្រាស់ថ្មីទៀត សុទ្ធាវាសភូមិនោះក៏សាបសូន្យ មិនមានវិញ្ញាណដ្ឋិតិ ព្រោះមិនមានសត្វទៅកើត ។

Websites: WatKhemaraRatanaram.org or WatKhmers.org


អាកាសានញ្ចាយតនវិបាក, ជាន់វិញ្ញាណញ្ចាយតនៈ បដិសន្ធិដោយវិញ្ញាណញ្ចាយតនវិបាក, ជាន់អាកិញ្ចញ្ញាយតនៈ បដិសន្ធិដោយអាកិញ្ចញ្ញាយតនវិបាក, តែមិនមាននិយាយអំពីកាយទេ ព្រោះសត្វពួកនេះមិនមានរូប ។ ក្នុងនេវសញ្ញានាសញ្ញាយតនៈ មិនមានវិញ្ញាណដ្ឋិតិទេ ព្រោះសង្ខារធម៌នោះល្អិតសុខុមពេកណាស់ មានកិច្ចរបស់វិញ្ញាណមិនប្រាកដ ។ ទាំងនេះឈ្មោះថា វិញ្ញាណដ្ឋិតិ ។

" អដ្ឋលោកធម្មសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៨គឺ លោកធម៌[1] ៨ ប្រការ លាភោ លាភ១ អលាភោ ឥតលាភ១ យសោ យស១ អយសោ ឥតយស១ និន្ទា តំណិះតំនៀល១ បសំសា សរសើរ១ សុខំ សុខ១ ទុក្ខំ ទុក្ខ១ ។

" នវសត្តាវាសសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ៩គឺ ទីលំនៅរបស់សត្វ៩គឺ បានដល់វិញ្ញាណដ្ឋិតិ ៧ ដូចបានរៀបរាប់មកហើយ និងអសញ្ញីសត្វ១ នេវសញ្ញានាសញ្ញាយតនៈ១ ផ្សំផងគ្នាត្រូវជា ៩ ហៅថា សត្តាវាស ។

---

១ ធម៌សម្រាប់លោក គឺតែងគ្របសង្កត់សត្វលោកទូទៅ ។

" ទសាយតនសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១០គឺ អាយតនៈ ១០ ចក្ខាយតនៈ បសាទរូបដែលជ្រាបសើមទូទៅក្នុងភូតរូប មានសណ្ឋានប្រមាណប៉ុនក្បាលចៃតាំងនៅកណ្តាលប្រស្រីភ្នែកទាំងគូ១ សោតាយតនៈ បសាទរូបដែលជ្រាបសើមទូទៅក្នុងភូតរូបមានសណ្ឋានដូចវង់ចិញ្ចៀន តាំងនៅក្នុងប្រហោងត្រចៀកទាំងគូ១ ឃានាយតនៈ បសាទរូបដែលជ្រាបសើមទូទៅក្នុងភូតរូប មានសណ្ឋានដូចក្រចកជើងពពែតាំងនៅក្នុងក្តោងច្រមុះ១ ជីវ្ហាយតនៈ បសាទរូបដែលជ្រាបសើមទូទៅក្នុងភូតរូបមានសណ្ឋានដូចស្រទាប់ផ្កាឧប្បល តាំងនៅពាក់កណ្តាលអណ្តាត១ កាយាយតនៈ បសាទរូបដែលជ្រាបសើមទូទៅសព្វសព៌ាង្គកាយវៀរលែងតែ សក់ រោម ក្រចក និងធ្មេញដែលដុះផុតចាកកាយ១ រូបាយតនៈ រូបារម្មណ៍ដែលមានពណ៌ខៀវលឿងជាដើម ឬស្រីប្រុសជាដើម១ សទ្ទាយតនៈ សូរសព្ទសំលេងពីរោះ ឬមិនពីរោះដែលកើតប្រកដដល់ចិត្ត១ គន្ធាយតនៈ គន្ធារម្មណ៍គឺក្លិនទាំងពួង១ រសាយតនៈ រសារម្មណ៍

គឺរសរបស់អាហារទាំងពួង១ ផោដ្ឋព្វាយតនៈ សម្ផស្សទាំងពួងដែលសម្រាប់ប៉ះពាល់រាងកាយ១ រួមត្រូវជាអាយតនៈ ១០ ។

" ឯកាទសវិធារម្មណសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១១ បានដល់អារម្មណ៍ដែលជាតួវិបាកចិត្ត ១១ គឺ សោមនស្សញាណសម្បយុត្ត២ សោមនស្សញាណវិប្បយុត្ត ២ ឧបេក្ខាញាណសម្បយុត្ត២ ឧបេក្ខាញាណវិប្បយុត្ត២ ឧបេក្ខាសម្បដិច្ឆន្នៈ១ ឧបេក្ខាសន្តីរណៈ១ សោមនស្សសន្តីរណៈ១ ផ្សំគ្នាជា ១១ ។

" ទ្វាទសាយតនសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក១២ បានដល់អាយតនៈ ១២ គឺ អាយតនៈខាងក្នុង ៦ មានចក្ខាយតនៈ ជាដើម មានធម្មាយតនៈ ជាទីបំផុត និងអាយតនៈខាងក្រៅ ៦ មានរូបាយតនៈជាដើមមានផោដ្ឋព្វាយតនៈជាទីបំផុត ត្រូវជាអាយតនៈ ១២ ។

" តេរសហាសនចិត្តសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១៣ បានដល់ហាសនចិត្ត[1]១៣ គឺលោភសោ-

១ ចិត្តដែលបណ្តាលឲ្យសើចញញឹមទៅបាន ។

មនស្ស ៤ មហាកុសលសោមនស្ស ៤ មហាកិរិយាសោ-មនស្ស ៤ ហសិតុប្បាទ១ ត្រូវជា១៣ ។

" ចុទ្ទសចិត្តុប្បាទសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក ១៤ បានដល់ចិត្តុប្បាទដែលប្រកបដោយអកុសល ១៤ គឺ មោហោ សភាពញ៉ាំងចិត្តឲ្យលង់ក្នុងអារម្មណ៍១ អហិរិកំ ធម្មជាតិមិនខ្មាស់បាប១ អនោត្តប្បំ ធម្មជាតិមិនក្តៅនិងបាប១ ឧទ្ធច្ចំ ធម្មជាតិញ៉ាំងចិត្តឲ្យរវើរវាយ១ លោភោ សភាពធ្វើចិត្តឲ្យជាប់ជំពាក់ក្នុងអារម្មណ៍១ ទិដ្ឋិ សេចក្តីយល់ខុស១ មានោ សេចក្តីស្មានខ្លួន១ ទោសោ សភាពទ្រុស្តក្នុងអារម្មណ៍១ ឥស្សា សេចក្តីច្រណែន១ មច្ឆរិយំ សេចក្តីកំណាញ់១ កុក្កុច្ចំ ធម្មជាតិ ធ្វើចិត្តឲ្យស្ដុងទៅរកការដែលខ្លួនប្រព្រឹត្តខុសកន្លងហើយ១ ថីនំ ធម្មជាតិធ្វើចិត្តឲ្យរួញរាមិនឲ្យខ្វល់ខ្វាយ១ មិទ្ធំ ធម្មជាតិធ្វើចិត្តឲ្យងោកងុយនិងឲ្យប្រព្រឹត្តលក់១ វិចិកិច្ឆា ធម្មជាតិធ្វើចិត្តឲ្យសង្ស័យ១ រួមគ្នាត្រូវជា ១៤ ។

" អដ្ឋារសធាតុសង្ខាតំ " ទ្រង់ជ្រាបច្បាស់នូវសង្ខារលោក១៨ បានដល់ធាតុ ១៨ គឺ ចក្ខុធាតុ ចក្ខុបសាទ១

រូបធាតុ រូបារម្មណ៍១ ចក្ខុវិញ្ញាណធាតុ វិញ្ញាណ[1] ដែលកើតឡើងអាស្រ័យចក្ខុបសាទនិងរូបារម្មណ៍ខ្ទប់គ្នា ១ សោតធាតុ សោតបសាទ១ សទ្ទធាតុ សទ្ទារម្មណ៍១ សោតវិញ្ញាណធាតុ វិញ្ញាណ ដែលកើតឡើងអាស្រ័យសោតបសាទ និងសទ្ទារម្មណ៍ខ្ទប់គ្នា១ ឃានធាតុ ឃានបសាទ១ គន្ធធាតុ គន្ធារម្មណ៍១ ឃានវិញ្ញាណធាតុ វិញ្ញាណដែលកើតឡើងអាស្រ័យឃានបសាទនិងគន្ធារម្មណ៍ខ្ទប់គ្នា១ ជីវ្ហាធាតុ ជីវ្ហាបសាទ១ រសធាតុ រសារម្មណ៍១ ជិវ្ហាវិញ្ញាណធាតុ វិញ្ញាណដែលកើតឡើងអាស្រ័យជីវ្ហាបសាទ និងរសារម្មណ៍ខ្ទប់គ្នា១ កាយធាតុ កាយបសាទ១ ផោដ្ឋព្វធាតុ ផោដ្ឋព្វារម្មណ៍១ កាយវិញ្ញាណធាតុ វិញ្ញាណដែលកើតឡើងអាស្រ័យកាយបសាទនិងផោដ្ឋព្វារម្មណ៍ខ្ទប់គ្នា១ មនោធាតុ ចិត្ត[២]១ ធម្មធាតុ ធម្មារម្មណ៍[៣] មនោវិញ្ញាណធាតុ វិញ្ញាណ[៤] ដែល

---

១- វិញ្ញាណទាំងនេះចែកចេញជា ២ គឺជាកុសលវិបាក ១ អកុសលវិបាក ១ ។ ២- បានដល់ចិត្ត ៣ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ សម្បដិច្ឆន្នចិត្ត ២ ។ ៣- ធម្មារម្មណ៍ មាន ៦ គឺ បសាទរូប ១ សុខុមរូប ១ ចិត្ត ១ ចេតសិក ១ និព្វាន ១ បញ្ញត្តិ ១ ។ ៤- បានដល់ចិត្ត ៧២ គឺ អកុសលចិត្ត ១២ សន្តីរណ ៣ មនោទ្វារាវជ្ជន ១ ហសនចិត្ត ១ ទាំង ៥ នេះរាប់ថា ១ , កាមាវចរសោភណចិត្ត ២៤ រូបាវចរ ១៥ លោកុត្តរ ៨ ត្រូវជាចិត្ត ៧២ ។

កើតឡើងអាស្រ័យចិត្តនិងធម្មារម្មណ៍ខ្ទប់គ្នា១ " ឥតិ សង្ខារលោកំ ជានាតីតិ លោកវិទូ " សម្ដេចព្រះសព្វញ្ញូទ្រង់ត្រាស់ដឹងនូវសង្ខារលោកដូចពណ៌នាមកនេះទើបបានទ្រង់ព្រះនាមថា " លោកវិទូ " ។

បុ. ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជ្រាបនូវសត្វលោកដូចម្ដេចខ្លះ ?

វិ. " សព្វសត្តានំ អាសយំ " ព្រះអង្គជ្រាបច្បាស់នូវទឹកចិត្តរបស់សព្វសត្វ ដែលមានធម៌អាស្រ័យនៅក្នុងខន្ធសន្ដានយ៉ាងណា១ គឺជ្រាបថាធម៌ ២ ប្រការគឺ សស្សតទិដ្ឋិ១ ឧច្ឆេទទិដ្ឋិ១ តែងអាស្រ័យនូវក្នុងខន្ធសន្ដានរបស់បុថុជ្ជន អនុលោមខន្តី គឺវិបស្សនាញាណទាំង ១០ និងយថាភូតញ្ញាណ តែងអាស្រ័យនៅក្នុងសន្ដានរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

" អនុសយំ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវបាបធម៌ដែលដេកត្រាំនៅក្នុងសន្ដានចិត្តរបស់សត្វ រង់ចាំឱកាសនឹងកើតភ្លាឡើងបានដល់ពួកកិលេសមានរាគនិងព្យាបាទជាដើម ។

" ចរិតំ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវចរិតគឺលំនាំប្រព្រឹត្តជាប្រក្រតី របស់សត្វទាំង ៦ ប្រការគឺ រាគចរិត លំនាំសត្វដែលច្រើនដោយតម្រេក១ ទោសចរិត លំនាំសត្វដែលច្រើនដោយសេចក្ដីប្រទូស្ដ១ មោហចរិត លំនាំសត្វដែលច្រើនដោយសេចក្ដីវង្វេង១ សទ្ធាចរិត លំនាំសត្វដែលច្រើនដោយសេចក្ដីជឿ១ ពុទ្ធិចរិត លំនាំសត្វដែលច្រើនដោយការចេះដឹង១ វិត្តកចរិត លំនាំសត្វដែលច្រើនដោយសេចក្ដីត្រិះរិះ១ ។

" អធិមុត្តឹ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវអធ្យាស្រ័យសេចក្ដីចំណូលធម៌របស់សត្វដែលក្លៀវក្លានិងទន់ទាប ឬដែលជាបុណ្យនិងបាប។

" អប្បរជ្ជក្ខេ មហារជ្ជក្ខេ សត្តេ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានធូលីគឺ រាគាទិកិលេសក្នុងភ្នែកតិចនិងមានធូលីគឺរាគាទិកិលេសក្នុងភ្នែកច្រើន ។

" តិក្ខិន្ទ្រិយេ សត្តេ មុទិន្ទ្រិយេ សត្តេ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានឥន្ទ្រីយ៍ក្លៀវក្លា និងពួកសត្វដែល

Websites: WatKhemaraRatanaram.org or WatKhmers.org


មានឥន្ទ្រិយទន់ ។ ឥន្ទ្រិយនោះមាន ៥គឺ សទ្ធិន្ទ្រិយ សេចក្តីជឿធំ១ វិរិយិន្ទ្រិយ សេចក្តីព្យាយាមជាធំ១ សតិន្ទ្រិយ សេចក្តីរឭកចងចាំមិនភ្លេចជាធំ១ សមាធិន្ទ្រិយ សេចក្តីតាំងចិត្តមាំជាធំ១ បញ្ញិន្ទ្រិយ បញ្ញាជាធំ១ ។

" ស្វាការេ សត្តេ ទ្វាការេ សត្តេ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានអាការល្អវៀរចាកអំពើទុច្ចរិត និងពួកសត្វដែលមានអាការអាក្រក់ប្រព្រឹត្តធ្វើតែអំពើទុច្ចរិត ។

" សុវិញ្ញាបយេ សត្តេ ទុវិញ្ញាបយេ សត្តេ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វ ដែលមានប្រាជ្ញាងាយពន្យល់ឲ្យចេះដឹងបាន និងពួកសត្វដែលអប្បឥតប្រាជ្ញាក្រនឹងដឹកនាំឲ្យចេះដឹងបាន ។

" ភព្វាភព្វេ សត្តេ " ព្រះអង្គទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានភ័ព្វ គឺសត្វដែលគួរត្រាស់ដឹងមគ្គផលនិងសត្វដែលឥតភ័ព្វមិនគួរត្រាស់ដឹងមគ្គផល ។ សត្វពួកណាប្រកបដោយអាវរណធម៌ គឺធម៌ជាគ្រឿងរាំង ៣ ប្រការគឺ កាមាវរណៈ ១ កិលេសាវរណៈ១ វិបាកាវរណៈ១ ។ កាមាវរណៈ បានដល់

តណ្ហា ៥ យ៉ាងគឺ រូបតណ្ហា ប្រាថ្នារូប១ សទ្ទតណ្ហា ប្រាថ្នាសំឡេង១ គន្ធតណ្ហា ប្រាថ្នាក្លិន១ រសតណ្ហា ប្រាថ្នារស១ ផោដ្ឋព្វតណ្ហា ប្រាថ្នាសព្វគ្រឿងកម្រាលដេកអង្គុយជាដើម១ ។ កិលេសាវរណៈ បានដល់កិលេស ១០ ប្រការគឺ កាមរាគ សេចក្តីត្រេកអរក្នុងកាម១ ភវរាគ សេចក្តីត្រេកអរក្នុងភព១ រូបរាគ សេចក្តីត្រេកអរក្នុងរូបភព១ អរូបរាគ សេចក្តីត្រេកអរក្នុងអរូបភព១ លោភ សេចក្តីជំពាក់ចិត្ត១ ទោសៈ សេចក្តីប្រទូស្ត១ មោហៈ សេចក្តីភាន់ច្រឡំ១ មានៈ សេចក្តីស្មានខ្លួន១ ទិដ្ឋិ សេចក្តីយល់ខុស១ វិចិកិច្ឆា សេចក្តីសង្ស័យ១ ។ វិបាកាវរណៈ បានដល់ទិដ្ឋិ ៣ យ៉ាងគឺ អហេតុកទិដ្ឋិ សេចក្តីយល់ថាសត្វដែលសៅហ្មងឬបរិសុទ្ធិឥតមានហេតុបច្ច័យ ល្អក៏ល្អឯង អាក្រក់ក៏អាក្រក់ឯង ឥតមានកុសលាកុសលមកឧបត្ថម្ភ១ អកិរិយទិដ្ឋិ សេចក្តីយល់ថា ធ្វើបាបខ្លួនឯងក្តីឬញុំាងអ្នកដទៃឲ្យធ្វើក្តីឥតបានបាប១ នត្ថិកទិដ្ឋិ សេចក្តីយល់ថា ឲ្យទានមិនមានផល ធ្វើការបូជាក៏មិនមានផល ប្រតិបត្តិមាតាបិតាក៏មិនមានផល១ ។ សត្វដែលប្រកបដោយធម៌ទាំងនុ៎ះ ឈ្មោះថាជាសត្វអភ័ព្វមិនគួរបានត្រាស់ដឹងមគ្គផលឡើយ ។

មួយទៀត សត្វពួកណាធ្វើបញ្ចានន្តរិយកម្មទាំង ៥គឺ មាតុឃាត ពិឃាតមាតាឯង១ បិតុឃាត ពិឃាតបិតាឯង១ អរហន្តឃាត ពិឃាតព្រះអរហន្ត១ ពុទ្ធលោហិតុប្បាទ ញុាំងព្រះលោហិតព្រះពុទ្ធឲ្យពុរពងឡើង១ សង្ឃភេទ បំបែកសង្ឃដែលកំពុងស្មោះសររកគ្នានៅក្នុងសីមាជាមួយឲ្យបែកចាកគ្នា១ និងពួកសត្វដែលធ្វើភិក្ខុនីទូសកកម្មប្រទូស្តនាងភិក្ខុនី ជាព្រះខីណាស្រពដោយអសទ្ធម្ម១ ។ សត្វពួកនេះក៏ទុកជាសត្វអភ័ព្វមិនគួរត្រាស់ដឹងមគ្គផលដែរ ។

សត្វពួកណាប្រាសចាកអាវរណៈ ៣ប្រការមិនប្រកាន់មិច្ឆាទិដ្ឋិទាំង ៣ មិនធ្វើបញ្ចានន្តរិយកម្មនិងភិក្ខុនីទូសកម្ម ជាអ្នកឧស្សាហ៍បំពេញទានរក្សាសីល ចម្រើនមេត្តាភាវនាស្តាប់ព្រះសទ្ធម្មវិសេសទេសនាផ្គត់ផ្គង់បម្រើមាតាបិតា សត្វពួកនោះឈ្មោះថាសត្វមានភ័ព្វគួរត្រាស់ដឹងមគ្គផលបាន បើទុកជាមិនបានមគ្គផលក្នុងបច្ចុប្បន្នជាតិនេះ ក៏គង់បានជាបច្ច័យនៃមនុស្សសម្បត្តិនិងសគ្គសម្បត្តិដែរ ដល់វេលាមានបារមីចាស់ក្លា គង់នឹងបានទទួលផលក្នុងខាងក្រោយមិនខាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org


" ឥតិ សត្តលោកំ ជានាតីតិ លោកវិទូ " សម្តេចព្រះអនាវរណញ្ញាណ ទ្រង់ជ្រាបច្បាស់នូវសត្វលោកដូចរៀបរាប់មកនេះ ទើបទ្រង់ព្រះនាមថា " លោកវិទូ " ។

បុ. ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវឱកាសលោកដូចម្តេចខ្លះ ?

វិ. ទ្រង់ជ្រាបច្បាស់នូវភាជនលោកទាំងមូលឥតចន្លោះទើសទាក់ ។ ហេតុដែលហៅឱកាសលោកថា " ភាជនលោក " ពីព្រោះ ឱកាសលោកទាំងមូលដូចជាភាជនៈសម្រាប់រងសម្រាប់ដាក់ទ្រូតៗ តៗ គ្នាគឺខ្យល់រងទឹកៗ រងផែនដីៗ រងភ្នំត្រីកូដៗ រងភ្នំព្រះសុមេរុៗ រងឆកាមាវចរសួគ៌ដូច្នេះទើបហៅថា ភាជនលោកគឺសំដៅយកផ្ទៃចក្រវាឡទាំងមូល ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវលោកទាំង ៣ ដូចពណ៌នាមកនេះ បានជាទ្រង់ព្រះនាមថា " លោកវិទូ " ប្រែថា " ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក " ។

ចប់បទ " លោកវិទូ " ដោយសង្ខេប

## កែបទ " អនុត្តរោ "

បុ. ហេតុអ្វីបានជាព្រះជាគ្រូទ្រង់ព្រះនាមថា " អនុត្តរោ " ?

វិ. បានជាទ្រង់ព្រះនាមថា " អនុត្តរោ " ព្រោះព្រះអង្គប្រសើរវិសេសរកបុគ្គលណាប្រសើរជាងគ្មាន ។

បុ. ព្រះអង្គប្រសើរដោយគុណអ្វី ដែលរកគេប្រៀបផ្ទឹមស្មើគ្មាននោះ ?

វិ. ព្រះអង្គប្រសើរដោយគុណសព្វគ្រប់ដូចសម្តែងតទៅនេះ " រូបកាយេសុ អនុត្តរោ " ព្រះអង្គប្រសើរលើសដោយរូបកាយ គឺរូបកាយរបស់ព្រះអង្គមិនប្រកបដោយទោសទាំងពួង មានមិនវិកលវិការខ្វាក់ស្រលៀងជាដើម ទ្រង់មានព្រះឥរិយាបថស្រគត់ស្រគំសមសោភា ទោះទ្រង់ផ្ទំក្តី ទ្រង់យាងក្តី ទ្រង់ស្ថិតក្តី ទ្រង់គង់ក្តី ក៏សមឥតឆ្គង ព្រោះព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនិងអនុព្យញ្ជនៈ ៨០ មានរស្មីផ្សាយចេញពីតួអង្គ រកមនុស្សនិងទេវតាណាមួយមកផ្ទឹមស្មើគ្មាន ។

" សីលេសុ អនុត្តរោ " ព្រះអង្គប្រសើរដោយសីល ២យ៉ាងគឺ លោកកិយសីល១ លោកុត្តរសីល១ ។ លោកិយសីលបានដល់ សីល ៥ សីល ៨ សីល ១០ និងសីល ៤ ដែលព្រះអង្គធ្លាប់ រក្សាក្នុងកាលដែលកំពុងត្រេចរង្គាត់ក្នុងវដ្តសង្សារនៅឡើយ អស់ ៤អសង្ខេយ្យ កម្រៃ១ សែនកប្ប ជាសីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដរាបមកទល់និងកាលដែលបានត្រាស់សព្វ-ញ្ញុតញ្ញាណ ឥតមានមោះហ្មង ជាសីលស្អាតបរិសុទ្ធិប្រពៃពិត ។ ឯលោកុត្តរសីលនោះបានដល់វិរតិ ៣គឺ សម្មាវាចា១ សម្មា-កម្មន្តោ១ សម្មាអាជីវោ១ ដែលកើតមួយអន្លើដោយអរិយមគ្គ លះកាត់បាបធម៌បានដោយសមុច្ឆេទប្បហាន ។

" សមាធិម្ហិ អនុត្តរោ " ព្រះអង្គប្រសើរដោយសមាធិ ២ ប្រការ គឺ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ។ ឧបចារសមាធិ បានដល់ ឯកគ្គតាចិត្តដែលមានក្នុងមហាកិរិយាញាណសម្ប-យុត្ត ជាឧបចារជ្ឈានសមាបត្តិ ។ ឯអប្បនាសមាធិចែកជា ២ ប្រការទៀតគឺ លោកិយអប្បនា ១ លោកុត្តរអប្បនា ១ ។ លោកិយអប្បនា បានដល់សមាធិដែលមានក្នុងសមាបត្តិ ៨ គឺ

រូបាវចរកិរិយាសមាបត្តិ ៩ អរូបាវចរកិរិយា សមាបត្តិ ៩ ។ លោកុត្តរអប្បនា ចាត់ជារូបាវចរ ៩ អរូបាវចរ ៩ ដោយ អំណាចឈាន ។

" បញ្ញាសុ អនុត្តរោ " ព្រះអង្គប្រសើរលើសដោយបញ្ញា គឺ មហាបញ្ញោ ទ្រង់មានព្រះបញ្ញាច្រើនជាងទេវតា និង មនុស្សទាំងឡាយ បុថុប្បញ្ញោ មានបញ្ញាក្រាស់ដូចមហាប្រឹថពី ហាសប្បញ្ញោ មានព្រះបញ្ញាអាចញុំាងចិត្តសត្វឲ្យរីករាយដោយធម្មទេសនា ជវនប្បញ្ញោ មានព្រះបញ្ញាវាងវៃឈ្វេងយល់ឆាប់ តិក្ខនប្បញ្ញោ មានព្រះបញ្ញាក្លៀវក្លាមុះមុត និព្វេធិកប្បញ្ញោ មានព្រះបញ្ញាមិនជាប់ជំពាក់មិនទើសទាក់ក្នុងការសម្តែងធម៌ ។ មិនតែពេលដែលបានត្រាស់ហើយនោះទេ សូម្បីកាលដែលទ្រង់សាងព្រះសម្ភារ គ្រាសោយព្រះជាតិជាមហោសថក្តី ជាព្រះវិធូរក្តី ក៏មានប្រាជ្ញាច្រើនអាចគ្របសង្កត់នូវប្រាជ្ញាអ្នកដទៃបាន ។

" បុរិសសីលបមាចារេសុ " ព្រះអង្គមានសីលាចារជាបុរសមែនពិតព្រោះឥរិយាបថ ៩ នៃព្រះអង្គក៏ពេញជាបុរសឥតខ្ចោះត្រង់ណាឡើយ ហើយទាំងចេះសិល្បសាស្ត្រវិសេសជាងបុរសទាំងពួង អ្នកផងតែងកោតសិល្បសាស្ត្រព្រះអង្គគ្រប់ៗ

Websites: WatKhemaraRatanaram.org or WatKhmers.org


គ្នា ដូចជាគ្រាកាលពួកសក្យៈ ជាព្រះញាតិវង្សានុវង្សរបស់ព្រះអង្គបន្ទុះបង្អាប់ថា ព្រះសិទ្ធត្ថសក្យបុត្រនេះ ល្អតែរូបទេ សិល្បសាស្រ្តមិនចេះទេ បើជួនជាមានអាសន្នអន់ក្រដោយស្តេចអរិន្ទរាជដែលជាសត្រូវខ្លាំង គេលើកទ័ពមកច្បាំងដណ្តើមយកនគរ ឬក៏មានសឹកសង្គ្រាមពីណាមក ធ្វើម្តេចនឹងតតាំងច្បាំងនិងគេបាន បើដូច្នេះយើងមិនគួរឲ្យធីតាទេ ។ គ្រានោះព្រះពោធិសត្វទ្រង់សម្តែងចេស្តា កណ្តាលជំនុំពួកសក្យៈ លើកសហស្សថាមធន្ទឡើង លាន់ឮសព្ទសម្លេងកក្រើករំជួលទូទៅ ពួកសក្យៈ ឮហើយភាន់ភាំងខ្លបខ្លាចថ្វីព្រះហស្តព្រះអង្គទើបនាំគ្នាយកធីតាចំនួន ៨ម៉ឺនមកថ្វាយ ។

" ភវស្ស សម្មាចារេសុ " ព្រះអង្គមានព្រះមារយាទថ្កើងថ្កានជាងអស់សត្វទាំងត្រៃភព ។

" បរបុគ្គលវិមុត្តិញ្ញាណេ " ព្រះអង្គប្រសើរលើសដោយប្រាជ្ញាដែលត្រាស់ដឹងឧបាយដែលនឹងចេញចាកបាប ជាជាងបុគ្គលដទៃ ។

" បុព្វេនិវាសានុស្សតិញ្ញាណេ " ព្រះអង្គប្រសើរដោយប្រាជ្ញាជាគ្រឿងដឹងនូវបុព្វេនិវាស ។

" ទិព្វចក្ខុញ្ញាណ " ព្រះអង្គប្រសើរលើសដោយទិព្វចក្ខុ ។

" កម្មវិបាកញ្ញាណោ " ព្រះអង្គប្រសើរលើសដោយបញ្ញាសម្រាប់ត្រាស់ដឹងនូវកុសលកម្មនិងអកុសលកម្មរបស់សត្វ ។

" យមកប្បាដិហារិយញ្ញាណោ " ព្រះអង្គប្រសើរលើសដោយបញ្ញាឈ្លាសក្នុងការសម្តែងយមកប្បាដិហារ្យ ។

" លោកវិវរណប្បាដិហារិយញ្ញាណោ " ព្រះអង្គប្រសើរដោយប្រាជ្ញាធ្វើបាដិហារ្យ បើកលោកឲ្យសត្វនរកនិងមនុស្សនិងទេវតាមើលឃើញគ្នាទៅវិញទៅមក ដូចកាលដែលព្រះអង្គសម្តែងសត្តប្បករណាភិធម្មចប់ហើយ ស្តេចយាងចុះចាកស្ថានតាវត្តិង្សមកនោះឯង ។

" អាបត្តិកុសលតាយ " ព្រះអង្គប្រសើរលើសដោយភាពជាអ្នកឈ្លាសក្នុងអាបត្តិនិងអនាបត្តិ ។

" អាបត្តិវុដ្ឋានកុសលតាយ " ព្រះអង្គប្រសើរដោយភាពជាអ្នកឈ្លាសក្នុងពុទ្ធប្បញ្ញត្តិ កាលបើកុលបុត្រមានសេចក្តីប្រហែសធ្វេសភ្លេចភ្លាំងស្មារតីត្រូវអាបត្តិ ទ្រង់ព្រះមហាករុណាអនុញ្ញាតឲ្យធ្វើនូវកិច្ចចាកអាបត្តិនោះបាន ។

" ធាតុកុសលតាយ " ព្រះអង្គប្រសើរដោយភាពជាអ្នកឈ្លាសក្នុងឧបាទិន្នកធាតុរបស់សត្វ និងអនុបាទិន្នកធាតុនៃផែនដីភ្នំរុក្ខជាតិ នឹងធាតុនៃសត្វដែលត្រេកអរដោយបថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

" មនសិការកុសលតាយ " ព្រះអង្គប្រសើរដោយការឈ្លាសក្នុងកិរិយាធ្វើទុកក្នុងចិត្ត គឺថាបើព្រះអង្គកំណត់របស់អ្វីទុកក្នុងព្រះទ័យហើយរបស់នោះគឺព្រះអង្គមិនភ្លេចឡើយ ។

" ឋានានកុសលតាយ " ព្រះអង្គប្រសើរលើសដោយភាពជាអ្នកឈ្លាសក្នុងហេតុនិងមិនមែនហេតុ ។ ហេតុនោះសំដៅយកកុសលហេតុ ៣ យ៉ាងគឺ អលោភោ១ អទោសោ១ អមោហោ១ ។

" ទ្វីសុ ឥទ្វីសុ " ព្រះអង្គប្រសើរលើសដោយឫទ្ធិ ២ ប្រការគឺ ចិត្តិទ្ធិ ទ្រង់ថ្លៃងឫទ្ធិដោយព្រះទ័យ១ វិមំសិទ្ធិ ទ្រង់ថ្លៃងឫទ្ធិដោយព្រះបញ្ញា១។

" ទ្វីសុ អនុត្តរិយេសុ " ព្រះអង្គប្រសើរដោយអនុត្តរិយ ២ ប្រការគឺ សីលានុត្តរិយៈ១ បញ្ញានុត្តរិយៈ១ ។

" តីសុ កថាវត្ថូសុ " ព្រះអង្គប្រសើរលើសដោយកថាវត្ថុ ៣ គឺ ទាន ១ សីល ១ ភាវនា ១ ។

" តីសុ សមាធីសុ " ព្រះអង្គប្រសើរដោយសមធិ ៣ គឺ វិតក្កវិចារសមាធិ សមាធិដែលប្រកបដោយវិតក្កវិចារ១ អវិតក្កវិចារសមាធិ សមាធិមានវិតក្កប្រកបដោយវិចារ១ អវិតក្កអវិចារសមាធិ សមាធិមិនមានវិតក្កមិនមានវិចារ ១ ។

" តីសុ បាដិហារិយេសុ " ព្រះអង្គប្រសើរដោយបាដិហារ្យ ៣ យ៉ាងគឺ កាលទ្រង់ឡើងធម្មាសនៈ១ កាលទ្រង់កំពុងសម្តែងធម៌ទេសនា១ កាលទ្រង់ចុះចាកធម្មាសនៈ១ ។

" ចតូសុ សតិបដ្ឋានេសុ " ព្រះអង្គប្រសើរក្នុងសតិបដ្ឋានទាំង ៤ គឺ កាយានុបស្សនាសតិបដ្ឋាន១ វេទនានុបស្សនាសតិបដ្ឋាន១ ចិត្តានុបស្សនាសតិបដ្ឋាន១ ធម្មានុបស្សនាសតិបដ្ឋាន១ ។

" ចតូសុ សម្បទាសុ " ព្រះអង្គប្រសើរក្នុងសម្បទា ៤ គឺ ចេតនា សម្បទា បរិបូណ៌ដោយចេតនាបី[1] ១ បច្ចយសម្បទា

១- បុព្វចេតនា ១ មុញ្ចនចេតនា ១ អបរាបរចេតនា ១

បរិបូណ៌ដោយបច្ច័យ ៤ មានចីវរបច្ច័យជាដើម១ វត្ថុសម្បទា បរិបូណ៌ដោយវត្ថុ១ គុណាតិរេកសម្បទា បរិបូណ៌ដោយគុណ ដែលព្រះអរិយបុគ្គលទើបចេញពីនិរោធសមាបត្តិ[1] ១ ។

" ចតូសុ ឥទ្ធិបាទេសុ " ព្រះអង្គប្រសើរក្នុងឥទ្ធិបាទទាំង ៤ គឺ ឆន្ទិទ្ធិបាទ១ វីរិយិទ្ធិបាទ១ ចិត្តិទ្ធិបាទ១ វិមំសិទ្ធិបាទ១ ។

" ចតូសុ មគ្គេសុ ចតូសុ ផលេសុ " ព្រះអង្គប្រសើរក្នុងមគ្គ ៤ ផល៤ មានសោតាបត្តិមគ្គ និងសោតាបត្តិផលជាដើម ។

" ចតូសុ អរិយវំសេសុ " ព្រះអង្គប្រសើរដោយអរិយវង្ស ៤ គឺ អប្បិច្ឆោ មានសេចក្តីប្រាថ្នាតិច១ សល្លេខោ មានសេចក្តីសន្តោស១ សទ្ធា មានកិរិយាជឿបារមីទាំង ១០ មានទានបារមីជាដើម១ សីលំ រក្សាសីល ៥ សីល ៨ និងចតុបារិសុទ្ធិសីល១ ។

" ចតូសុ វិមុត្តិញ្ញាណេសុ " ព្រះអង្គប្រសើរដោយវិមុត្តិ[២] ៤ គឺបញ្ញាវិមុត្តិ រួចចាកបាបធម៌ទាំងពួងដោយលោកុត្តរបញ្ញា ។ សមុច្ឆេទវិមុត្តិ រួចចាកបាបធម៌ទាំងពួងដោយការលះកាត់ដាច់

---

១- ព្រះអរិយបុគ្គល ២ ពួកគឺព្រះអនាគាមិននិងព្រះអរហន្ត ។ ២- វិមុត្តិ ៤ យ៉ាងទៀតគឺ តទង្គវិមុត្តិ បានដល់កាមាវចរកុសល១ វិក្ខម្ភនវិមុត្តិ បានដល់រូបាវចរកុសល ១ បស្សទ្ធិវិមុត្តិ បានដល់លោកុត្តរកុសល ១ និស្សរណវិមុត្តិ បានដល់ព្រះនិព្វាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ស្រទប់១ វិក្ខម្ភនវិមុត្តិ រួចចាកបាបធម៌ទាំងពួងដោយសង្កត់សង្កិន១ តទង្គវិមុត្តិ រួចចាកបាបធម៌ទាំងពួងបានតែមួយខណៈៗ១ ។

" បញ្ចពលេសុ " ព្រះអង្គប្រសើរដោយពលៈ ៥គឺ សទ្ធា១ សតិ១ វីរិយ១ សមាធិ១ បញ្ញា១ ។

" បញ្ចិន្ទ្រិយេសុ " ព្រះអង្គប្រសើរដោយឥន្ទ្រិយ ៥ គឺ សទ្ធិន្ទ្រីយ៍១ វីរិយិន្ទ្រីយ៍១ សតិន្ទ្រីយ៍១ សមាធិន្ទ្រីយ៍១ បញ្ញិន្ទ្រីយ៍១ ។

" បញ្ចាភិញ្ញាសុ " ព្រះអង្គប្រសើរដោយអភិញ្ញា ៥ គឺ ទិព្វចក្ខុ១ ទិព្វសោត១ ឥទ្ធិវិធៈ១ បរចិត្តវិជ្ជា១ បុព្វេនិវាសានុស្សតិ១ ជា៥[1] ថែមអាសវក្ខយៈ១ទៀតជាអភិញ្ញា ៦ ។

" ឆអសាធារណញ្ញាណេសុ " ព្រះអង្គប្រសើរដោយអសាធារណញ្ញាណ ៦គឺ អាសយានុសយញ្ញាណ ប្រាជ្ញាឈ្វេងយល់នូវអាសយានុសយធម៌របស់សត្វ១ ឥន្ទ្រិយបរោបរិយត្តិញ្ញាណ

---

១- ពួកបុថុជ្ជនតែអភិញ្ញា ៥ ដែលជាលោកិយ ឯព្រះអរិយបុគ្គលជាម្ចាស់មានព្រះពុទ្ធជាដើម ទើបបានអាសវក្ខយវិជ្ជាដែលជាលោកុត្តរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ប្រាជ្ញាឈ្វេងយល់ដល់នូវឥន្ទ្រីយ៍ដ៏ទន់និងក្លៀវក្លារបស់សត្វដទៃ១ យមកប្បាដិហារិយញ្ញាណ ប្រាជ្ញាវាងវៃក្នុងការសម្តែងយមកប្បាដិហារ្យ១ មហាករុណាសមាបត្តិញ្ញាណ ប្រាជ្ញាឈ្លាស់ក្នុងការដោះទុក្ខសត្វក្នុងពេលចេញចាកសមាបត្តិ១ សព្វញ្ញុតញ្ញាណ ប្រាជ្ញាដឹងសព្វគ្មានចន្លោះ១ អនាវរណញ្ញាណប្រាជ្ញាដឹងឥតទើសទាក់១ ។

" សត្តវិសុទ្ធិទេសនាសុ " ព្រះអង្គប្រសើរដោយវិធីទេសនានូវវិសុទ្ធិទាំង ៧គឺ សីលវិសុទ្ធិ បរិសុទ្ធិក្នុងចតុបារិសុទ្ធិសីល១ ចិត្តវិសុទ្ធិ[1] បរិសុទ្ធិចិត្ត១ ទិដ្ឋិវិសុទ្ធិ បរិសុទ្ធិប្រាជ្ញាពិចារណាត្រូវ១ កង្ខាវិតរណវិសុទ្ធិ បរិសុទ្ធិផុតចាកសេចក្តីសង្ស័យ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បរិសុទ្ធិប្រាជ្ញាពិចារណានូវខន្ធ ៥ ស្គាល់ថាជា អតីត បច្ចុប្បន្ន អនាគត ហើយចិត្តយាងចុះកាន់ត្រៃលក្ខណ៍ដឹងជាក់ច្បាស់ថាជាមគ្គឬមិនមែនមគ្គ១ បដិបទាញាណទស្សនវិសុទ្ធិ បរិសុទ្ធិប្រាជ្ញាពិចារណាឃើញមគ្គ៤ ផល៤,១ ញាណទស្សនវិសុទ្ធិ បរិសុទ្ធិដោយលោកុត្តរប្បញ្ញាទាំង ៨

---

១- ចិត្តវិសុទ្ធិ បានដល់សមាធិ ២ យ៉ាងគឺ ឧបចារសមាធិ ១ អប្បនាបាសមាធិ ១ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


មានសោតាបត្តិមគ្គញ្ញាណជាដើម មានអរហត្តផលញ្ញាណជាទីបំផុត១ ។

" សត្តខីណាសវពលេសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវអរិយបុគ្គល៧ ជំពូកមានសោតាបត្តិមគ្គដ្ឋ ជាដើម មានអរហត្តមគ្គដ្ឋ ជាទីបំផុត ថាបុគ្គលជាន់នេះមានកម្លាំងអាចលះបង់អាសវកិលេសបានប៉ុណ្ណេះៗ ។

" នវសត្តាវាសទេសនាសុ " ព្រះអង្គប្រសើរក្នុងការសម្តែងនូវទីលំនៅរបស់សត្វទាំង ៩ ដែលហៅថា " សត្តាវាស " ដូចសម្តែងរួចក្នុងខាងដើមហើយ ។

" ទសកសិណាយតនេសុ " ព្រះអង្គប្រសើរក្នុងកសិណ ១០ គឺ បថវីកសិណ១ អាបោកសិណ១ តេជោកសិណ១ វាយោកសិណ១ នីលកសិណ១ បីតិកសិណ១ លោហិតកសិណ១ ឱទាតកសិណ១ អាកាសកសិណ១ អាលោកកសិណ១ ។

" ឯកាទសមេត្តានិសង្សទេសនាសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវអានិសង្សអ្នកផ្សាយមេត្តាចិត្ត ១១ គឺ សុខំ សុបតិ ដេកលក់ស្រួល១ សុខំ បដពុជ្ឈតិ ភ្ញាក់ឡើងស្រួល១

ន បាបកំ សុបិនំ បស្សតិ មិនយល់សប្តិអាក្រក់១ មនុស្សានំ បិយោ ហោតិ ជាទីស្រលាញ់នៃមនុស្សទាំងឡាយ១ ទេវតា រក្ខន្តិ មានទេវតារក្សា១ នាស្សអគ្គិវា វិសំវា សត្ថំ វា កមតិ ភ្លើងមិនឆេះ អសិរពិសមិនហ៊ានបៀតបៀន និងមិនមានរបួសដោយគ្រឿងសាស្ត្រវុធ១ ចិត្តំ សមាធិយតិ ចិត្តតាំងនៅនឹងនួន១ មុខវណ្ណោ វិប្បសីទតិ សម្បុរមុខជ្រះថ្លា១ អសម្មុឡ្ហោ កាលំ ករោតិ មិនវង្វេងក្នុងពេលធ្វើកាលកិរិយា១ ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ បើមិនបានចាក់ធ្លុះនូវធម៌ជាន់ខ្ពស់ បានតែត្រឹមឈានសមាបត្តិ ពេលដែលច្យុតបានទៅកើតក្នុងព្រហ្មលោក១ រួមជា ១១ ។

" ទ្វាទសាកុសលទេសនាសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវវារៈ ទឹកចិត្តនៃបុគ្គលដែលមានបាបប្រកបដោយអកុសលចិត្ត ១២ គឺ លោភៈ ៨ ទោសៈ ២ មោហៈ ២ ។

" តេរស ធុតង្គគុណេសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវធុតង្គគុណ ១៣ គឺ អារញ្ញិក១ បត្តបិណ្ឌិក ១ បិណ្ឌបាតិក១ តេចីវរិក១ នេសជ្ជិក១ ឯកាសនិក១

សបទានចារិក១ យថាសន្តតិក១ ខលុបច្ឆាភត្តិក១ រុក្ខមូលិក១ អព្ភោកាសិក១ បំសុកូលិក១ សោសានិក១ ជា ១៣ ប្រការ ។

" ចុទ្ទសពុទ្ធញ្ញាណេសុ " ព្រះអង្គប្រសើរដោយពុទ្ធញ្ញាណ ១៤ គឺ ទុក្ខេ ញាណំ ប្រាជ្ញាពិចារណាឃើញទុក្ខសច្ច១ ទុក្ខសមុទយេ ញាណំ ប្រាជ្ញាពិចារណាឃើញសមុទយសច្ច១ ទុក្ខនិរោធេ ញាណំ ប្រាជ្ញាពិចារណាឃើញនិរោធសច្ច១ ទុក្ខនិរោធគាមិនីបដិបទាយ ញាណំ ប្រាជ្ញាពិចារណាឃើញមគ្គសច្ចនិងអត្ថបដិសម្ភិទា១ ធម្មបដិសម្ភិទា ១ និរុត្តិបដិសម្ភិទា១ បដិភាណបដិសម្ភិទា១ រួមត្រូវជាពុទ្ធញ្ញាណ ៨ យកអសាធារញ្ញាណ ៦ មកផ្សំផងទៀតត្រូវជាព្រះពុទ្ធញ្ញាណ ១៤ ។

" ឯកវីសតិកុសលទេសនាសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវទេសនាព្រះសង្គិណិប្បករណៈ ចែកកុសល ២១ គឺ កាមាវចរកុសល ៨ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ ជា ២១ ។

" ចតុវីសតិបច្ចយទេសនាសុ " ព្រះអង្គប្រសើរដោយកិរិយាត្រាស់ដឹងនូវទេសនា ព្រះមហាបដ្ឋានដែលប្រកបដោយបច្ច័យ ២៤ មាន ហេតុប្បច្ច័យជាដើម មានអវិគតប្បច្ច័យជាទីបំផុត។ កោដិសតសហស្សសញ្ចរិតធម្មវជីរញ្ញាណេសុ ព្រះអង្គប្រសើរដោយវជីរញ្ញាណ ដែលត្រាស់ដឹងនូវព្រះធម៌ក្រៃលែងសែនកោដិរកទីបំផុតគ្មានគឺ ទុកបដ្ឋាន តិកបដ្ឋាន ទុកតិកបដ្ឋាន តិកទុកបដ្ឋាននេះឯង ។

" ឥតិ ភគវា អនុត្តរោ " សម្តេចព្រះដ៏មានព្រះភាគប្រសើរក្នុងធម៌ទាំងឡាយដូចពណ៌នាមកនេះ បានជាទ្រង់ព្រះនាមថា " អនុត្តរោ " ប្រែថា " ព្រះអង្គប្រសើររកបុគ្គលណាស្មើគ្មាន " ។

ចប់បទ " អនុត្តរោ " ដោយសង្ខេប

## កែបទ " បុរិសទម្មសារថិ[1] "

បុ. ព្រោះហេតុអ្វីបានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា " បុរិសទម្មសារថិ " ?

វិ. បានជាទ្រង់ព្រះនាមថា " បុរិសទម្មសារថិ " ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

បុ. បុរសដូចម្តេចដែលហៅថា " អ្នកមានឧបនិស្ស័យ " ?

វិ. បុរសដែលបានក៏សាងបារមីអំពីអតីតជាតិ គឺបានឲ្យទាន, រក្សាសីល, ចម្រើនភាវនា, ស្តាប់ធម៌ទេសនាជាដើម ទោះបីតិចក្តី ច្រើនក្តី ល្មមជាបច្ច័យឲ្យព្រះអង្គទូន្មានបាន ហើយស្ថិតនៅក្នុងគុណធម៌ជាន់ទាបក្តី ជាន់ខ្ពស់ក្តី តាមសមគួរដល់ការកសាងរបស់ខ្លួននោះហៅថា " បុរសមាននិស្ស័យ " ។

បុ. ចុះបុរសដែលមាននិស្ស័យនោះៗ គួរទូន្មានបានតែព្រះពុទ្ធ១ ព្រះអង្គទេឬៗក៏ពួកសាវកដទៃៗ គួរទូន្មានបានខ្លះដែរ ?

---

១- ព្រះនាមនេះ បើរួមចូលនឹងព្រះនាមថា " អនុត្តរោ " ខាងដើម ជាព្រះនាមតែមួយក៏បាន ចែកចេញជា ២ ដូចន័យនេះក៏បាន ។

វិ. ការទូន្មាននូវបុរសដែលមានឧបនិស្ស័យនោះៗ មិនបានចំពោះតែព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះទេ ទោះបីសាវកដទៃៗក៏ត្រូវទូន្មានបានខ្លះ ពីព្រោះបុរសដែលគួរទទួលយកដំបូន្មានបាននោះចែកចេញជា ២គឺ ពុទ្ធវេនេយ្យ១ សាវកវេនេយ្យ១ ។ ពុទ្ធវេនេយ្យ អ្នកដែលគួរព្រះពុទ្ធប្រោសបាន សាវកវេនេយ្យ អ្នកដែលសាវកប្រោសបាន ព្រះមុនីសាស្តាទ្រង់ជ្រាបច្បាស់ថា សត្វណាដែលគួរព្រះអង្គប្រោសបាន ទើបទ្រង់យាងទៅប្រោសដោយព្រះអង្គឯង បើសត្វណាគួរដល់សាវក ព្រះអង្គក៏ចាត់សាវកឲ្យទៅប្រោស ។

បុ. ក្នុងវិធីដែលនឹងប្រៀនប្រដៅសត្វតើព្រះបរមគ្រូទ្រង់ប្រើឧបាយបែបណា ?

វិ. ព្រះអង្គប្រើវិនយុបាយ គឺឧបាយជាគ្រឿងណែនាំពន្យល់អំពីទោសនិងអានិសង្ស ឲ្យសត្វចូលចិត្តស្រលាញ់ ឲ្យវៀរ គឺបើសត្វណាគាប់ចិត្តនឹងពាក្យពីរោះផ្អែម ព្រះអង្គក៏ទ្រង់សម្តែងអំពីសុចរិត ៣ ប្រការ មាន កាយសុចរិតជាដើម និងអានិសង្ស

Websites: WatKhemaraRatanaram.org or WatKhmers.org



របស់សុចរិតឲ្យសត្វកើតសេចក្តីរីករាយ បើសត្វណាចូលចិត្ត និងពាក្យជ្រោកជ្រាក ព្រះអង្គក៏ទូន្មានដោយពាក្យជ្រោកជ្រាក គឺទ្រង់ប្រកាសទុច្ចរិតទាំង ៣ ប្រការ មានកាយទុច្ចរិតជាដើម និងផលរបស់ទុច្ចរិត ដើម្បីឲ្យសត្វភិតភ័យខំប្រឹងរៀរឡើងហើយនឹងបានតម្កល់នៅក្នុងកុសលធម៌ ។ ប្រការមួយសោត ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅសត្វដោយអាការ ៣ យ៉ាងគឺ អភិញ្ញា ទ្រង់ប្រដៅឲ្យសត្វដឹងជាក់ស្តែងនូវគុណនិងទោសជាដើម១ សនិទាន ទ្រង់ប្រដៅតាមដំណើរហេតុដំណើររឿង១ សប្បាដិហារិយ ទ្រង់ប្រដៅប្រកបដោយបាដិហារ[1] ១ ។ ព្រះអង្គជាគ្រូទ្រង់ឈ្លាស់វៃក្នុងវិធីប្រៀនប្រដៅសត្វ ដូចហត្ថាចារ្យ ឬ អស្សាចារ្យដែលប៉ិនប្រសប់ហ្វឹកហ្វឺនប្រដៅនូវគុជសា និងអស្សតរ ព្រោះព្រះអង្គជ្រាបច្បាស់នូវសត្វលោកសព្វទាំងអស់ដូចបានអធិប្បាយរួចហើយក្នុងបទលោកវិទូ សត្វណាមានចរិតយ៉ាងណា ឬក្សពារមារយាទយ៉ាងណា ក៏ទ្រង់ជ្រាបបានទាំងអស់ ម្លោះហើយបានជាទ្រង់ប្រដៅសត្វចេះតែលុះក្នុង

---

១- អនុសាសនីបាដិហារ ទ្រង់ប្រដៅកិរិយាដះតឿនក្រើនរំលឹក ១ ឥទ្ធិប្បាដិហារ ទ្រង់ប្រដៅដោយសម្តែងឫទ្ធិ ១ អាណាទេសនាបាដិហារ ទ្រង់ប្រដៅដោយសម្តែងអំណាច ១ ។

ពាក្យជំបូន្មានព្រះអង្គទាំងអស់ ហេតុនេះទើបទ្រង់មានស្មាដៃថ្វីព្រះឱស្ឋល្បីថា " បុរិសទម្មសារថិ " ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

បុ. មុខគួរឲ្យងឿងឆ្ងល់ត្រង់ពាក្យថា " បុរសៗ " សំដៅយកតែមនុស្សប្រុស បើដូច្នោះព្រះពុទ្ធជាម្ចាស់ប្រដៅតែប្រុសៗមិនប្រដៅស្រីៗផងទេឬ ?

វិ. មិនមែនដូច្នោះទេ ព្រះពុទ្ធជាម្ចាស់ប្រដៅបានទាំងអស់ទាំងបុរសទាំងស្ត្រី តែក្នុងទីនេះបានជាលោកចេញឈ្មោះតែបុរស ពីព្រោះជាឧក្កដ្ឋជាតិ ជាតិខ្ពស់ជាងស្រីៗ ។ ស្រីជាហីនៈជាតិ ជាតិទាបជាងប្រុស បានជាលោកតាំងបុរសនេះឲ្យដាក់ជាប្រធាន តែគង់សាធារណៈ ដល់ស្ត្រីផងដែរ ។

បុ. ចុះបុរស ដែលព្រះអង្គទូន្មានបានចំពោះតែជាតិមនុស្សទេឬ ?

វិ. មិនចំពោះតែជាតិមនុស្សទេ បុរសដែលព្រះអង្គទូន្មានបាន មាន៣ ពួកគឺ តិរច្ឆានបុរសពួក១ មនុស្សបុរសពួក១ អមនុស្សបុរសពួក១ ។ តិរច្ឆានបុរសដែលព្រះអង្គ

ទូន្មានបាន ដូចយ៉ាងអបលាលោនាគរាជដែលនៅអាស្រ័យក្នុងហេមវន្តប្រទេស ចុល្លោទរនាគរាជ និង មហោទរនាគរាជ ដែលនៅអាស្រ័យក្នុងនាគទ្វីប អគ្គិសិខនាគរាជ និង ធូមសិខនាគរាជដែលនៅអាស្រ័យក្នុងសីហលទ្វីប ហើយនិងអាឡវាឡនារាជជាដើម ព្រះអង្គទ្រង់ព្រះមហាករុណាស្តេចយាងទៅទូន្មានដោយបាដិហារ្យផ្សេងៗ ញ៉ាំងស្តេចនាគទាំងឡាយនោះឲ្យលះព្យុះកំណាចចោលសូន្យចាកពិសគឺទោសោ ហើយឲ្យតាំងនៅក្នុងព្រះត្រៃសរណគមន៍និងសីល ។ ដំរីធនបាលបាស្តិន្ទសោតទៀតក៏ព្រះអង្គទូន្មានឲ្យតាំងនៅក្នុងព្រះត្រៃសរណគមន៍ ។ តិរច្ឆានបុរស ដែលព្រះអង្គទូន្មានបានមិនមានតែត្រឹមប៉ុណ្ណោះទេ នៅមានច្រើនតទៅទៀត ។ មនុស្សបុរសដែលប្រព្រឹត្តធ្វើអំពើទុច្ចរិតប្រកាន់ធម៌លាមក ប្រកបដោយទិដ្ឋិយ៉ាងសច្ចកនិគ្រណ្ឋបុត្ត អម្ពដ្ឋមាណព បោក្ខរសាសាតិព្រាហ្មណ៍ សោណទណ្ឌព្រាហ្មណ៍ កូដទន្តព្រាហ្មណ៍ជាដើមព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះមហាករុណាទូន្មានដោយព្រះសទ្ធម្មទេសនា ជាអនេកបរិយាយត្រាតែកើតសេចក្តីជ្រះថ្លាជឿគុណព្រះរតនត្រ័យ លះបង់ទិដ្ឋិ

ចោលកាន់យកសម្មាទិដ្ឋិ បានសម្រេចមគ្គនិងផល ។ មនុស្សបុរសដែលលុះក្នុងសំណាញ់ញាណព្រះអង្គ ហើយទ្រង់ទូន្មានបាន មិនមែនមានប្រមាណតិចទេ គឺច្រើនពន់ពេកណាស់។ ឯមនុស្សបុរសនោះដូចយ៉ាងអាឡវកយក្ស សុចិលោមយក្ស ខរលោមយក្ស អម្រិន្ទ្រាធិរាជ និងពកាព្រហ្មជាដើម សុទ្ធតែប្រកបដោយទិដ្ឋិយ៉ាងទ្រនង់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ទូន្មានដោយឧបាយទាំងឡាយ ដ៏វិចិត្រគឺ ព្រះសទ្ធម្មទេសនាត្រាតែមានសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យជាភិយ្យោភាព ។

បុ. ពាក្យសំដីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានសត្វតើយ៉ាងណាខ្លះ ?

វិ. ពាក្យសំដីព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ទូន្មានសត្វមានវិចិត្រច្រើនប្រការពិស្តារណាស់ព្រោះកាលដែលទ្រង់ប្រៀនប្រដៅ តែងប្រដៅអនុលោមតាមចរិតនិងនិស្ស័យ វាសនា តាមសតិបញ្ញារបស់ វេនេយ្យសត្វ និងអនុលោមតាមឧបត្តិហេតុនឹងតាមកាលតាមសម័យ តាមទំនៀមស្រុកប្រទេសខ្លះ ព្រោះហេតុនោះបានជាមានន័យជាអនេកបរិយាយ តែបើរួបរួមឲ្យខ្លី

Websites: WatKhemaraRatanaram.org or WatKhmers.org


ចុះមក ទោះបីច្រើនម្ល៉ោះ ក៏គង់ចូលមកនៅក្នុងពាក្យ ៣ ម៉ាត់ គឺ សព្វបាបស្សអករណំ ទ្រង់ប្រដៅមិនឲ្យធ្វើបាបគ្រប់យ៉ាង១ កុសលស្សូបសម្បទា ទ្រង់ប្រដៅឲ្យសន្សំទុកនូវកុសល១ សចិត្តបរិយោទបនំ ទ្រង់ប្រដៅឲ្យដុសខាត់ចិត្តរបស់ខ្លួនឲ្យផូរផង់១ ។

សេចក្តីអធិប្បាយទី១ ព្រះអង្គប្រដៅមិនឲ្យធ្វើអំពើអកុសលគ្រប់ជំពូក គឺឲ្យវៀរចាកទុច្ចរិតកិរិយាប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត មានសម្លាប់សត្វនិងលួចទ្រព្យជាដើម ទី២ ព្រះអង្គប្រដៅឲ្យសន្សំទុកនូវកុសលធម៌គឺ បុញ្ញកិរិយាវត្ថុ ១០ មានទានជាដើម ទី៣ ព្រះអង្គប្រដៅឲ្យដុសខាត់ចិត្តរបស់ខ្លួនឲ្យស្អាតចាកអនុសយកិលេសគឺ សេចក្តីសៅហ្មងរបស់ចិត្តដែលដេកត្រាំនូវក្នុងសន្តានចិត្តសត្វ ជាកិលេសក៏គ្រោតគ្រាតខ្លះ ល្អិតខ្លះណាដែលគ្រោតគ្រាតមានសម្លាប់សត្វនិងសំឡឹងរំពៃចង់បានទ្រព្យអ្នកដទៃមកជារបស់ខ្លួនជាដើម អាចលះបង់បានដោយអំណាចសីល ឬសមាធិ ណាដែលល្អិតជាដើមហេតុជាមេឲ្យកើតកិលេសដទៃ ដូចឫសកែវនោះ តោង

លះដោយបញ្ញា ។ ក៏ឯពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ បើរួមឲ្យចុះមកនៅត្រឹមតែពាក្យពីរម៉ាត់គឺ ១ ប្រដៅឲ្យលះសេចក្តីប្រមាទ ២ប្រដៅឲ្យចម្រើនអប្បមាទ ។ បមាទគឺ សេចក្តីធ្វេសប្រហែសមានកិរិយាភ្លាំងភ្លេចស្មារតី ឬបណ្តោតបណ្តោយស្មារតីជាលក្ខណៈ បមាទនេះជាមេកំពូលនៃអកុសល ទាំងពួងតែងកើតឡើងដោយសារបមាទ ដែលនិងរកឱកាសចូលមកលុកលុយក្នុងខន្ធសន្តានរបស់សត្វបាន ក៏អាស្រ័យសេចក្តីប្រមាទនេះដែរ ព្រោះហេតុនោះបានជាព្រះបរមគ្រូទ្រង់ប្រដៅឲ្យលះបង់សេចក្តីប្រមាទ ។ ឯអប្បមាទនោះ បានដល់ការមិនធ្វេសប្រហែសគឺប្រុងប្រយ័ត្ន មានមិនភ្លាំងភ្លេចស្មារតីឬមិនបណ្តោតបណ្តោយស្មារតីជាលក្ខណៈ កាលបើសេចក្តីធ្វេសប្រហែសនេះមានហើយ សត្វរមែងប្រឹងប្រែងធ្វើកុសលមានទានជាដើម ដើម្បីបិទផ្លូវមិនឲ្យអកុសលធម៌ ចូលមកលុកលុយក្នុងខន្ធសន្តានបាន ព្រោះហេតុនោះបានជាមានព្រះពុទ្ធបរិហារថា " បណ្ឌិតគេតែងបន្ទោរបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ " គឺបើសេចក្តីមិនប្រមាទកំពុងមាននៅ ធ្វើម្តេចឡើយសេចក្តីប្រមាទ

នឹងរកឱកាសចូលមកបាន ។ សេចក្ដីមិនប្រមាទនេះជាដើម នៃកុសលធម៌ទាំងពួង ជាប្រឡាយបង្ហូរកុសលមកក្នុងខន្ធសន្តាន ជាមេនាំមុខកុសលធម៌ឲ្យកើត ប៉ែកខាងកុសលធម៌ទាំងអស់ធំចំបងជាងគេនៅលើអប្បមាទ ប្រៀបដូចជាជានជើងដំរីធំក្រៃលែងជានជើងសត្វម្រឹគផងទាំងពួង ជានជើងសត្វទាំងពួងដ៏សេស រមែងជាន់ចុះក្នុងជានជើងដំរីបានទាំងអស់យ៉ាងណាមិញ កុសលធម៌ទាំងពួងក៏ដូច្នោះដែរ រមែងប្រជុំចុះមកក្នុងអំណាចអប្បមាទនេះទាំងអស់ ពីព្រោះអប្បមាទធម៌ជាចម្បង ហេតុហ្នឹងហើយបានជាព្រះបរមគ្រូ វេលាទៀតស្ដេចនឹងចូលកាន់និព្វាន ទ្រង់ឈ្ងៀងព្រះនេត្រាទៅមើលបរិសទ្ទាំង ៤គឺ ភិក្ខុ១ ភិក្ខុនី១ ឧបាសក១ ឧបាសិកា១ អង្គុយប្រជុំគ្នាត្រៀបត្រាខ្លះមានមុខក្រៀមក្រំសញ្ជប់សញ្ជឹង ខ្លះមានជលនេត្រាហូរសស្រាក់ដោយខ្លោចផ្សាចិត្តនឹកស្ដាយស្រណោះ ព្រះជាគ្រូទ្រង់ទតឃើញក៏មានព្រះទ័យអាណិតអាសូរ ងាកបែរព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org


ភក្ត្រទៅរក ហើយស្តេចខំប្រឹងត្រដរមានព្រះពុទ្ធដីកាផ្តែផ្តាំទាំងកំពុងប្រឈួនខ្លាំងថា " សង្ខារធម៌ទាំងឡាយរមែងវិនាសសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងប្រយោជន៍របស់ខ្លួនឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះណា! " ពាក្យប៉ុណ្ណេះនេះហើយដែលជាពាក្យផ្តែផ្តាំបង្ហើយក្រោយបំផុត របស់ព្រះពុទ្ធជាបរមគ្រូហៅថា " បច្ឆិមពុទ្ធវចនៈ " ព្រះពុទ្ធបណ្តាំចុងក្រោយបំផុតលុះទ្រង់មានព្រះបន្ទូលផ្តែផ្តាំស្រេចហើយ ព្រះទ័យព្រះអង្គក៏ឡើងស្រឹតតាមថ្នាក់ឈានទាំង ៤ និងអរូបជ្ឈានដរាបដល់ផុតវេទនានិងសញ្ញា ចូលសញ្ញាវេទយិតនិរោធ ហើយត្រឡប់ថយមកតាមកន្លែងដើម រួចឡើងរហូតដល់ចតុត្ថជ្ឈានវិញ ទើបស្តេចទ្រង់រំលត់ខន្ធចូលកាន់ព្រះនិព្វានក្នុងរវាងនោះឯង ។

ក៏ពាក្យថា " មិនប្រមាទ " មួយម៉ាត់នេះ ជាកំពូលនៃធម៌ទាំងពួង ព្រោះហេតុនោះក្នុងពេលដែលព្រះជាគ្រូទ្រង់ព្រះពុទ្ធដំណើរចូលកាន់ព្រះនិព្វានស្តេចគ្រាន់តែផ្តែផ្តាំថា " កុំប្រមាទ "

Websites: WatKhemaraRatanaram.org or WatKhmers.org


ប៉ុណ្ណោះហាក់ដូចជាទ្រង់ត្រាស់សម្តែងធម៌ទាំងឡាយ ដែលទ្រង់បានសម្តែងរួចហើយថែមមួយត្រូតទៀត ពីព្រោះពាក្យបណ្តាំថា " កុំប្រមាទ " គឺត្រូវឲ្យថៃទាំមតកំគឺព្រះធម៌វិន័យដែលទ្រង់បានចែករំលែកទុកឲ្យហើយអស់ ៤៥ វស្សា នោះទាំងអស់ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គឈ្លាស់វៃក្នុងវិធីអនុគ្រោះស្រោចស្រង់សត្វដោយបរិយាយដ៏វិចិត្រមុខគួរឲ្យសត្វស្រណោះ ឲ្យសត្វចង់ស្តាប់ចង់ធ្វើតាម ដូចសេចក្តីដែលបានពណ៌នាមកនេះ ទើបទ្រង់ព្រះនាមថា " បុរិសទម្មសារថិ " ព្រះអង្គប៉ិនប្រសប់ទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

ចប់បទ " បុរិសទម្មសារថិ " ដោយសង្ខេប

កែបទ " សត្ថាទេវមនុស្សានំ "

បុ. ព្រះសម្មាសម្ពុទ្ធដ៏មានជោគហេតុដូចម្ដេចបានជាទ្រង់ព្រះនាមថា " សត្ថាទេវមនុស្សានំ " ?

វិ. បានជាទ្រង់ព្រះនាមថា " សត្ថាទេវមនុស្សានំ " ព្រោះព្រះអង្គជាគ្រូនៃទេវតា និង មនុស្សទាំងឡាយ ។

បុ. ចុះព្រះអង្គប្រដៅអ្វីខ្លះដល់ទេវតា និងមនុស្សទាំងឡាយ ?

វិ. ព្រះអង្គទ្រង់ប្រៀនប្រដៅប្រយោជន៍ ៣ យ៉ាងគឺ ទិដ្ឋធម្មិកត្ថ ប្រយោជន៍ក្នុងបច្ចុប្បន្ន១ សម្បរាយិកត្ថ ប្រយោជន៍ក្នុងបរលោក១ បរមត្ថ ប្រយោជន៍ក្នុងព្រះនិព្វាន១ ។

បុ. ប្រយោជន៍ក្នុងបច្ចុប្បន្នមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. មាន ៤ យ៉ាងគឺ ឧដ្ឋានសម្បទា ដល់ព្រមដោយការខ្នះខ្នែងប្រឹងប្រែងចាត់ចែងការងារដែលខ្លួនត្រូវប្រកបនោះៗ ដែលជាការប្រាសចាកទោស មានកសិកម្មជាដើម១ អារក្ខសម្បទា ដល់ព្រមដោយការថែរទាំ រក្សាទ្រព្យដែលរកបានមកមិនឲ្យវិនាសទៅដោយហេតុផ្សេងៗ មានភ្លើងឆេះចោរលួចនិងលេងល្បែងភ្នាល់ជាដើម១ កល្យាណមិត្ត តាមសេពគប់មិត្តល្អ គឺមិត្ត

ដែលមានសទ្ធា មានសីល មានចាគៈ មានបញ្ញាដ៏ល្អ១ សមជីវិតា ចិញ្ចឹមជីវិតដ៏ស្មើ គឺរកទ្រព្យបានមកហើយចាយវាយតាមកម្លាំងដែលខ្លួនរកបាន មិនឲ្យខ្វះខ្វាយហួសប្រមាណលៃឲ្យស្មើដូចគេថ្លឹងនឹងជញ្ជីង១ ទាំង៤នេះ ឈ្មោះថាប្រយោជន៍ក្នុងបច្ចុប្បន្ន ។

បុ. ចុះប្រយោជន៍ក្នុងបរលោកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិ. មាន ៤យ៉ាងគឺ ១ - សទ្ធាសម្បទា ដល់ព្រមដោយសេចក្តីជឿ គុណព្រះរតនត្រ័យ ជឿកម្ម ជឿផល ២- សីលសម្បទា ដល់ព្រមដោយសីល មានសីល ៥ ជាដើម ៣- ចាគសម្បទា ដល់ព្រមដោយការលះបង់បច្ច័យ ៤ មានចីវរប្បច្ច័យជាដើមដល់សមណៈ និងព្រាហ្មណ៍ ៤- បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា គឺ ការចេះដឹង ។ ប្រយោជន៍ទាំង ៤យ៉ាងនេះបើបុគ្គលណាបានធ្វើហើយ ឈ្មោះថាបានជម្រះផ្លូវទៅកាន់លោកខាងមុខជានិច្ច លុះរំលាងខន្ធពីនេះទៅនឹងបានដើរទៅដោយស្រួលមិនលំបាក ឧបមាដូចមនុស្សដែលដើរតាមថ្នល់ដ៏ស្អាតរមែងមិនលំបាក ។

បុ. ចុះព្រះអង្គទ្រង់ប្រៀនប្រដៅបរមត្ថប្រយោជន៍ដោយធម៌ណា?

វិ. ព្រះអង្គទ្រង់ប្រៀនប្រដៅដោយសច្ចធម៌ ៤គឺ ប្រដៅឲ្យឃើញកងទុក្ខទាំង ១២ មានជាតិទុក្ខជាដើម ប្រដៅឲ្យឃើញហេតុដែលនាំឲ្យកើតទុក្ខ គឺ តណ្ហាទាំង ៣ ឬ ទាំង១០៨ ឲ្យឃើញទីរលត់ទុក្ខ គឺព្រះនិព្វាន ឲ្យឃើញផ្លូវទៅកាន់ទីរំលត់ទុក្ខ គឺអដ្ឋង្គិកមគ្គ ។ ព្រះអង្គទ្រង់ប្រៀនប្រដៅតាមឧបនិស្ស័យ បើសត្វណាមានឧបនិស្ស័យតិច មានកិលេសក្រាស់ព្រះអង្គទ្រង់ប្រៀនប្រដៅដោយប្រយោជន៍ជាបច្ចុប្បន្ន និងប្រយោជន៍ក្នុងបរលោក សត្វណាមានឧបនិស្ស័យចាស់ក្លាព្រះអង្គ ទ្រង់ប្រៀនប្រដៅដោយបរមត្ថប្រយោជន៍ ទើបព្រះអង្គបានទ្រង់ព្រះនាមថា " សត្ថាទេវមនុស្សានំ " ។

ន័យមួយទៀតថា ព្រះវិជិតមារបានជាទ្រង់ព្រះនាមថា " សត្ថា " ព្រោះព្រះអង្គជាគ្រូញុំាងសត្វឲ្យឆ្លងចាកកន្តារ ដូចជាបុរសអ្នកនាំផ្លូវពួកឈ្មួញ សេចក្តីថា បុរសអ្នកនាំផ្លូវពួកឈ្មួញតែងញុំាងពួកឈ្មួញឲ្យឆ្លងចាកផ្លូវឆ្ងាយដាច់ស្រយាល ជាផ្លូវ

ប្រកបដោយសេចក្តីអន្តរាយ ដែលហៅថា " កន្តារ " មាន៥គឺ ចោរកន្តារ ផ្លូវឆ្ងាយដែលមានចោរ១ ពាលកន្តារ ផ្លូវឆ្ងាយដែលមានសត្វសាហាវ១ និរុទកកន្តារ ផ្លូវឆ្ងាយដែលដាច់ទឹក១ អមនុស្សកន្តារ ផ្លូវឆ្ងាយដែលមានអមនុស្សចាំបៀតបៀន១ អប្បភក្ខកន្តារ ផ្លូវឆ្ងាយដែលគ្មានភោជនាហារ១ ឲ្យទៅដល់ខេមន្តភូមិគឺ ទីដ៏ក្សេមក្សាន្តបានយ៉ាងណា ឯសម្តេចព្រះសម្ពុទ្ធជាម្ចាស់ក៏ដូច្នោះដែរ ទ្រង់តែងចម្លងសត្វឲ្យផុតអំពីផ្លូវកន្តារ ១៣ ប្រការ ដែលប្រកបដោយអន្តរាយផ្សេង ៗ គឺ ជាតិកន្តារ១ ជរាកន្តារ១ ព្យាធិកន្តារ១ មរណកន្តារ១ ទុក្ខទុក្ខ១ សោកៈ១ បរិទេវៈ១ ទោមនស្សៈ១ ឧបាយាសៈ១ ទិដ្ឋិ១ ឧទ្ធច្ចៈ១ វិចិកិច្ឆា១ សីលព្វត្តបរាមាសៈ១ ផ្លូវកន្តារទាំង ១៣ ប្រការនេះ ព្រះសាស្តាស្តេចទ្រង់យកបារមីទាំង ៣០ មកធ្វើជាសំពៅ ធ្វើជាហត្ថិយាន រថយាន ជិះឆ្លងសមុទ្ទកន្តារ គឺ វដ្តសង្សារ ចំពោះព្រះអង្គឯងរួចហើយ ទើបស្តេចទ្រង់ចម្លងសត្វទាំងពួងឲ្យឆ្លងចាកជាតិកន្តារ ជរាកន្តារ ព្យាធិកន្តារ មរណកន្តារ ជាដើម ទៅតាមព្រះអង្គផង ។

បុ. សត្វបែបណាដែលព្រះអង្គចម្លងឲ្យផុតចាកជាតិកន្តារ លែងកាន់យកនូវបដិសន្ធិក្នុងផ្ទៃមាតាតទៅទៀត ?

វិ. យេ តេ កប្បសតសហស្សា ធម្មំ សុត្វា បញ្ញាយ បស្សន្តិ សត្វទាំងឡាយឯណាបានបំពេញបារមីអស់ ១សែន កប្ប ហើយបានស្តាប់ធម៌ទេសនាក្នុងសំណាក់ព្រះសាស្តាញ៉ាំង បញ្ញាឲ្យឃាងចុះតាមន័យដែលព្រះអង្គទ្រង់សម្តែងនោះ ឃើញ ច្បាស់នូវអរិយសច្ចទាំង ៤ ប្រការ កាត់លះកិលេស និង តណ្ហា អស់ពីខន្ធសន្តានដោយអរហត្តមគ្គញ្ញាណ ជាសមុច្ឆេទប្បហាន សត្វបែបនេះបានឆ្លងចាកជាតិកន្តារ មិនកាន់យកនូវបដិសន្ធិ ក្នុងគភ៌មាតាតទៅទៀតទេ ដូចបញ្ចវគ្គិយភិក្ខុនិងយសកុលបុត្រ និងសម្លាញ់យសកុលបុត្រជាដើម ។

បុ. បើសត្វឆ្លងរួចចាកជាតិកន្តារហើយ ឈ្មោះថាឆ្លងរួច ចាកជរា ព្យាធិ មរណកន្តារផងបានដែរឬ ?

វិ. ឈ្មោះថាឆ្លងបានដែរ ពីព្រោះព្រះអរិយបុគ្គលដែល ឆ្លងចាកជាតិកន្តារហើយរមែងមិនកើតទៀតទេ នឹងមិនមានជរា ព្យាធិ មរណកន្តារក្នុងអនាគត ដ្បិតថាធម៌ ៣ ប្រការគឺជរា

ព្យាធិ មរណៈ នេះតែងកើតឡើងអាស្រ័យជាតិ កាលបើជាតិមិនមានក្នុងពេលណា ជរា ព្យាធិ មរណៈ ក៏មិនមានក្នុងពេលនោះ ព្រោះហេតុនោះ ជាតិកើតឡើងហើយជាបច្ច័យដល់ជរាៗ ជាបច្ច័យដល់ព្យាធិៗ ជាបច្ច័យដល់មរណៈ និងសោកទុក្ខទោមនស្សឧបាយសៈនោះផង បើជាតិមិនមានធម៌ទាំងឡាយមានជរាជាដើម មានឧបាយាសៈជាទីបំផុត និងធម៌ទាំងឡាយដទៃក្រៅពីនេះគឺចិត្តនិងចេតសិកនិងរូបក៏មិនមានទាំងអស់ បើធម៌ទាំងអស់មិនមានយ៉ាងនេះ ហើយព្រះអរិយបុគ្គលអង្គនោះឈ្មោះថាបានឆ្លងផុតចាកកន្តារទាំង ១៣ ។ ព្រះសាក្យមុនីស្ដេចចម្លងសត្វទាំងឡាយឲ្យឆ្លងផុតអំពីកន្តារ គឺភពវដ្ដសង្សារនាំទៅដាក់ដល់ត្រើយគឺព្រះនិព្វាន យ៉ាងនេះបានជាទ្រង់ព្រះនាមថា " សត្ថា " ប្រែថា " ជាគ្រូញ៉ាំងសត្វឲ្យឆ្លងចាកផ្លូវឆ្ងាយ " ។

ក៏ពាក្យថា " ទេវមនុស្សានំ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ " នោះលោកពោលដោយឧក្រិដ្ឋសំដៅតែភព្វបុគ្គល គឺបុគ្គលដែលគួរទទួលមគ្គផលបានក្នុងបច្ចុប្បន្នជាតិ

Websites: WatKhemaraRatanaram.org or WatKhmers.org


តែដែលពិតនោះ ព្រះអង្គមិនប្រៀនប្រដៅចំពោះតែទេវតានិងមនុស្សប៉ុណ្ណោះទេ ព្រះអង្គប្រៀនប្រដៅទាំងសត្វតិរច្ឆានដោយអនុសាសនីទេសនាផងដែរ ។ តិរច្ឆានទាំងនោះដែលបានស្តាប់ធម៌ព្រះអង្គហើយនឹងបានជា ឧបនិស្ស័យសម្បត្តិដល់ជាតិជាអនាគតក្នុងអត្តភាពទី ២ ទី ៣ ទើបបានសម្រេចផលតួយ៉ាងដូចមណ្ឌុកទេវបុត្រ[1] ជាដើម ។

ដំណាលសេចក្តីថា កាលព្រះសម្ពុទ្ធប្រោសប្រទានព្រះធម៌ទេសនាដល់បរិសទ៍នៅទៀបក្រុងចម្បា ក្បែរមាត់ស្រះបោក្ខរណីឈ្មោះគគ្គរា ។ គ្រានោះ មានសត្វកង្កែប១ សម្ងំស្តាប់សព្ទធម៌ទេសនារបស់ព្រះអង្គ មានគង្វាលគោម្នាក់ដើរមកឈរច្រេតដំបងសង្កត់ពីលើក្បាល កង្កែបៗ ក៏ធ្វើមរណកាលទៅកើតក្នុងភពតាវត្តិង្សនៅក្នុងវិមានមាសកំពស់ ១២ យោជន៍ ហាក់ដូចភ្ញាក់ពីដេកស្រាប់តែឃើញស្រីទេពអប្សរ ចោមរោមជាបរិវារនៅស្ថាននោះ ទេវបុត្រនឹកពិផលក្នុងចិត្តគិតថា យីអើហ្ន៎ គួរឲ្យឆ្ងល់ពន់ពេក ហេតុអ្វីអេះ អញសោតបានមកកើតក្នុងទីនេះ

---

១- ទេវបុត្រនេះកាលជាតិមុនជាសត្វកង្កែប ។

Websites: WatKhemaraRatanaram.org or WatKhmers.org


រំពឹងគិតសព្វៗ ទៅ មិនឃើញបុញ្ញកម្មអ្វីដទៃក្រៅពីកិរិយាកាន់យកនូវនិមិត្តក្នុងសម្លេងធម៌ទេសនាព្រះសម្ពុទ្ធសោះ ទើបហោះមកតាមអាកាសវេហាស៍នភាល័យ ព្រមទាំងវិមានមកក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ គ្រានោះ ព្រះអង្គទ្រង់មានព្រះពុទ្ធតម្រាស់សួរថា:

កោ មេ វន្ទតិ បាទាន ឥទ្ធិយា យសសា ជលំ

អភិកន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។

អ្នកណាហ្ន៎ មានឫទ្ធិ មានយសរុងរឿង មានរស្មីចែងចាំងញ៉ាំងទិសទាំងពួងឲ្យភ្លឺស្វាង មកសំពះបាទានៃតថាគត ។

ទេវបុត្រក្រាបទូលស្នងព្រះពុទ្ធដីកាថា:

មណ្ឌូកោហំ បុរេ អាសឹ ឧទកេ វារិគោចរោ

តវ ធម្មំ សុណន្តស្ស អវធិ វច្ឆបាលកោ ។

ខ្ញុំព្រះអង្គ កាលពីដើមឡើយជាសត្វកង្កែបនៅអាស្រ័យក្នុងទឹក មានវារីជាទីគោចរ កាលកំពុងស្តាប់ធម៌ព្រះអង្គ អ្នកគង្វាលគោគេសម្លាប់ខ្ញុំព្រះអង្គ។ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះសណ្តាប់ហើយក៏ទ្រង់ប្រោសប្រទាន ព្រះសទ្ធម្មវិសេសទេសនា សត្វទាំងឡាយ

៨ ម៉ឺន ៨ពាន់ បានលុះធម្មាភិសម័យ ។ ឯទេវបុត្រនោះ បានលុះសោតាបត្តិផល មានចិត្តរីករាយហើយហោះចាកទីនោះ ទៅកាន់លោកនាយវិញ ។ ព្រះសម្ពុទ្ធដែលទ្រង់ព្រះនាមថា " សត្ថាទេវមនុស្សានំ " ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្ស ទាំងឡាយ ហើយនិងសត្វដទៃដូចសេចក្តីដែលពណ៌នា មកនេះឯង ។

ចប់បទ " សត្ថាទេវមនុស្សានំ " ដោយសង្ខេប

Websites: WatKhemaraRatanaram.org or WatKhmers.org


កែបទ " ពុទ្ធោ "

បុ. ព្រោះហេតុអ្វីបានជាព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា " ពុទ្ធោ " ?

វិ. បានជាទ្រង់ព្រះនាមថា: " ពុទ្ធោ " ព្រោះព្រះអង្គជាអ្នកភ្ញាក់រឭក, ជាបុគ្គលរីក ជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដ៏ទៃឲ្យត្រាស់ដឹងផង ។

បុ. ពាក្យថា " ព្រះអង្គជាអ្នកភ្ញាក់រឭក " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា: ព្រះបរមសាស្តាទ្រង់ភ្ញាក់អំពីកិរិយាដេកលក់ក្នុងអនុស័យ ៧ គឺ កាមរាគានុស័យ ដេកលក់ក្នុងសេចក្តីត្រេកត្រអាលទៅរកបញ្ចកាមគុណ ១ ភវរាគានុស័យ ដេកលក់ក្នុងសេចក្តីត្រេកត្រអាលក្នុងភព ១ បដិឃានុស័យ ដេកលក់ក្នុងបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ ១ មានានុស័យ ដេកលក់ក្នុងមានៈ ( សេចក្តីប្រកាន់ ) ១ ទិដ្ឋានុស័យ ដេកលក់ក្នុងទិដ្ឋិ ( គំនិតយល់ខុស ) មានប្រភេទ ៦២ យ៉ាង ១ វិចិកិច្ឆានុស័យ ដេកលក់ក្នុងវិចិកិច្ឆា គឺសេចក្តីសង្ស័យស្ទាក់ស្ទើរមិនចេះអស់មិន

ចេះហើយ ១ អវិជ្ជានុស័យ ដេកលក់ក្នុងអវិជ្ជា គឺសេចក្តីល្ងង់ទាំង ៨ ប្រការ ដែលបិទបាំងបញ្ញាមិនឲ្យឃើញអរិយសច្ច ១ រួមផងគ្នាត្រូវជាអនុស័យធម៌ ៧ ប្រការ ។ ព្រះសាស្តាស្តេចទ្រង់តើនឡើងចាកធម៌ ៧ ប្រការនេះ ដឹងខ្លួនច្បាស់លាស់ទ្រង់យាងដាស់សត្តនិករទាំងឡាយដែលកំពុងដេកត្រាំ ឬកំពុងដេកលក់ស៊ប់ក្នុងអនុស័យឲ្យភ្ញាក់ ឲ្យដឹងខ្លួនដូចព្រះអង្គផង ។ សត្វណាដែលដេករវៀសរវៃមាននិស្ស័យក្រាស់ក៏ភ្ញាក់ឡើងដឹងខ្លួន សត្វណាមាននិស្ស័យស្តើងនឹងមិនមាននិស្ស័យ គ្រាន់តែប្រែប្រួលខ្លះសម្ងំដេកនៅខ្លះ ។ ព្រះអង្គបានយាងដាស់សត្វតាំងតែអំពីពេលបានត្រាស់រហូតទៅទល់នឹងចូលព្រះនិព្វានអស់ ៤៥ វស្សា ឥតមានទំនេរពេលណាឡើយ ព្រោះទ្រង់ឃើញទោសក្នុងកិរិយាដេកលក់ ឃើញសេចក្តីសុខក្នុងព្រះនិព្វាន បានជាទ្រង់ខ្វល់ខ្វាយដាស់សត្វព្រោះទ្រង់ភ្ញាក់មុនគេ ។ ពិតមែន ព្រះសាស្តាជាម្ចាស់ កាលដែលទ្រង់ភ្ញាក់ឡើងឥតមាននរណាមួយដាស់ព្រះអង្គឡើយ គឺ បារមីទាំង ៣០ ដែលព្រះអង្គកសាងអស់៤អសង្ខេយ្យកម្រៃ ១សែនមហាកប្ប គ្រប់កំណត់ហើយដាស់ព្រះអង្គឲ្យភ្ញាក់

រឭក ប្រៀបដូចមនុស្សដែលដេកលក់ដល់ពេលម៉ោងហើយ រមែងរវៀសរវៃក្រោកឡើងធ្វើការងារ មិនចាំបាច់អ្នកណាតឿន ឡើយ ។ ព្រះដ៏មានបុណ្យជាម្ចាស់ទ្រង់ភ្ញាក់ឡើងហើយយាង ដាស់សត្វឯទៀតដូចថ្លែងមកនេះ ទើបទ្រង់ព្រះនាមថា " ពុទ្ធោ " ប្រែថា " ព្រះអង្គជាបុគ្គលភ្ញាក់រឭក " ។

បុ. ពាក្យថា " ព្រះអង្គជាបុគ្គលរីក " អធិប្បាយដូចម្ដេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គរីក ចេញអំពីអវិជ្ជា គឺសេចក្ដីល្ងង់ ។ កាលសត្វទាំងឡាយកំពុង អន្ទោលទៅក្នុងវដ្ដសង្សារ មិនទាន់បានត្រាស់ដឹងនៅឡើយ អវិជ្ជារមែងរឹងរុំហ៊ុំជិត មិនឲ្យមានពន្លឺ គឺបញ្ញារីកសាយឡើងបាន នឹងមិនឲ្យឃើញនូវធម៌ពិតឡើយ ដូចជាកូនមាន់មិនទាន់ញាស់ សំបកពងនៅកំពុងរុំស្រោប រមែងមិនឃើញពន្លឺព្រះអាទិត្យ លុះតែកូនមាន់នោះ ខំប្រឹងយកចំពុះនិងចុងក្រចកចឹកកកាយ ទម្លុះសំបកពងនោះ ចេញរួចមកទើបឃើញពន្លឺព្រះអាទិត្យ ។ ឯ ព្រះសម្មាសម្ពុទ្ធសោត ក៏ព្រះអង្គមានព្រះបញ្ញាញាណឆ្លុះព្រោង ព្រាយ ព្រោះទ្រង់ទម្លាយនូវសំបកពងគឺ អវិជ្ជាបាន ទ្រង់មាន

ព្រះទ័យស្អាតផូរផង់ ឥតមានគ្រឿងរឹតរុំហ៊ុំស្រោប គឺ អវិជ្ជាឡើយ ហើយព្រះអង្គខំបំពេញពុទ្ធកិច្ច ទាំងអស់ដរាបដល់ចូលព្រះនិព្វាន ដោយប្រការដូច្នេះ ទើបទ្រង់ព្រះនាមថា " ពុទ្ធោ " ប្រែថា " ព្រះអង្គជាបុគ្គលរីក " ។

បុ. ពាក្យថា " ព្រះអង្គជាបុគ្គលត្រាស់ដឹងនូវចតុរារិយសច្ច នោះតើអធិប្បាយដូចម្ដេច " ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់នូវអរិយ-សច្ចទាំង ៤ ប្រការគឺ ទុក្ខសច្ច ទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម ១ សមុទយសច្ច ហេតុដែលនាំឲ្យកើតទុក្ខ គឺតណ្ហាទាំង ៣ ប្រការ មានកាមតណ្ហាជាដើម ១ និរោធសច្ច សេចក្ដីរលត់កងទុក្ខ ១ មគ្គសច្ច អរិយមគ្គទាំង ៨ ជាឧបាយសម្លាប់នូវសេចក្ដីទុក្ខ ១ ។ បណ្ដាសច្ចៈ ទាំង ៤ នោះ ក្នុងសច្ចៈមួយ ៗ មានអត្ថ ៤ ៗ ដូច្នេះគឺ ទុក្ខសច្ចៈមានអត្ថ ៤ គឺ បិឡនត្ថោ មានអត្ថថាបៀតបៀននូវសត្វ ១ សង្ខតត្ថោ មានអត្ថថាជាធម៌ គឺបច្ច័យទាំងឡាយមានតណ្ហាជាដើម ប្រជុំគ្នាតាក់តែងឲ្យកើត ១ សន្តាបត្ថោ មានអត្ថថាញ៉ាំងសត្វឲ្យក្ដៅក្រហាយអន្ទះអន្ទែង ១

Websites: WatKhemaraRatanaram.org or WatKhmers.org


វិបរិណាមត្ថោ មានអត្ថថា ចេះតែប្រែប្រួលមិនឋិតឋិរ ១ ។ សមុទយសច្ចមានអត្ថ ៤ គឺ អាយុហនត្ថោ មានអត្ថថាប្រមូលគៀរគរសេចក្តីទុក្ខឲ្យកើត ១ និទានត្ថោ មានអត្ថថានាំយកសេចក្តីទុក្ខប្រគល់ឲ្យជាផលរបស់ខ្លួន ១ សំយោគត្ថោ មានអត្ថថាប្រកបទាក់ចងសត្វដោយសេចក្តីទុក្ខ ១ បលិពោធត្ថោ មានអត្ថថា ធ្វើឲ្យសត្វរវល់រំខានចិត្ត ស្ទាក់ដំណើរមិនឲ្យបានមគ្គ-ផល ១ ។ និរោធសច្ចៈ មានអត្ថ ៤ គឺ និស្សរណត្ថោ មានអត្ថថារលាស់ចោលនូវឧបធិធម៌ ដែលសម្រាប់ឲ្យសេចក្តីទុក្ខចូលទៅអែបនែបនៅហើយដោះខ្លួនចេញពីភព ១ វិវេកត្ថោ មានអត្ថថាស្ងប់មិនមានសង្ខារធម៌ទាំងពួង ១ អសង្ខតត្ថោ មានអត្ថថាលែងមានធម៌ជាបច្ច័យប្រជុំតាក់តែងឲ្យកើត ១ អមតត្ថោ មានអត្ថថាជាធម្មជាតិមិនចេះស្លាប់ ព្រោះជារបស់ទៀង ១ ។ មគ្គសច្ចៈ មានអត្ថ ៤ គឺ និយានត្ថោ មានអត្ថថា ដឹកជញ្ជូនសត្វចេញពីវដ្ត-សង្សារ ១ ហេតុត្ថោ មានអត្ថថា ជាហេតុញុំាងសត្វឲ្យដល់ព្រះនិព្វាន ១ ទស្សនត្ថោ មានអត្ថថា ឃើញនូវព្រះនិព្វានដែលជា

Websites: WatKhemaraRatanaram.org or WatKhmers.org


ធម៌ល្អិតសុខុមក្រៃលែង ១ អធិបតេយ្យត្ថោ មានអត្ថថា ជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន ១ ។

ក្នុងសច្ចៈ ទាំង ៤ នោះ មានលក្ខណៈ ២ យ៉ាងគឺ សង្ខតលក្ខណៈ ១ ខសង្ខតលក្ខណៈ ១ ។ សង្ខតលក្ខណៈចែកចេញជា ៣ យ៉ាងគឺ ឧប្បាទោ កិរិយាកើតឡើង ១ វយោ កិរិយាសោះសូន្យទៅ ១ ឋិតិ កិរិយាតាំងនៅ ១ ។ អសង្ខតលក្ខណៈ ក៏ចែកចេញជា ៣ យ៉ាងដែរគឺ អនុប្បាទោ កិរិយាមិនកើតឡើង ១ នវយោ សេចក្តីមិនសាបសូន្យទៅ ១ នឋិតិ ការមិនតាំងនៅ ១ ។ បណ្តាសច្ចៈ ទាំង ៤ នោះ ទុក្ខសច្ចៈ សមុទយសច្ចៈ និងមគ្គសច្ចៈ ទាំង ៣ នេះរាប់ចូលក្នុងសង្ខតលក្ខណៈ, និរោធសច្ចៈ រាប់ចូលក្នុងអសង្ខតលក្ខណៈ ។ សច្ចៈ ទាំង ៤ នេះបើចែកដោយកុសល អកុសល និង អព្យាកតវិញ សមុទយសច្ចជាអកុសលសុទ្ធ មគ្គសច្ចៈជាកុសល និរោធសច្ចជាអព្យាកត ទុក្ខសច្ចជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតខ្លះ ។ ទុក្ខសច្ចដែលជាកុសលជាគូគ្នានិងមគ្គសច្ចជាកុសល, អធិប្បាយថា កាលបុរសបុគ្គលខំប្រឹងប្រែងរៀនសូត្រ នឹងចម្រើនសមថកម្មដ្ឋាន ឬប្រព្រឹត្តធុតង្គ ១៣

ឬក៏ធ្វើកុសលផ្សេង ៗ បានសេចក្ដីលំបាកនឿយហត់ យ៉ាងនេះឈ្មោះថាទុក្ខ ប៉ុន្តែអំពើនោះជាកុសល ទើបឈ្មោះថាទុក្ខសច្ចជាកុសល ។ ទុក្ខសច្ចជាអកុសលជាគូគ្នានិងសមុទយសច្ចជាអកុសល អធិប្បាយថា កាលដែលបុរសបុគ្គលប្រព្រឹត្តធ្វើបាបកម្មមាន បាណាតិបាតជាដើម លំបាកដោយភ្លៀងត្រូវក្ដៅ និងភ័យដោយគេចាប់គេចងព្រោះធ្វើចោរកម្មជាដើម យ៉ាងនេះឈ្មោះថាទុក្ខ ថែមទាំងអំពើនោះជាអកុសល ទើបឈ្មោះថាទុក្ខសច្ចជាអកុសល ។ ទុក្ខសច្ចជាអព្យាកតជាគូគ្នានិងនិរោធសច្ចជាអព្យាកត អធិប្បាយថា លោកដែលបានសម្រេចព្រះអរហត្តមានព្រះពុទ្ធជាដើម តែងខំប្រឹងប្រតិបត្តិវត្តិតឹងតែងនឹងសម្ដែងធម៌ប្រោសសត្វ លំបាកនឿយហត់តែឥតបានផលឡើយ យ៉ាងនេះបានជាឈ្មោះថា ទុក្ខសច្ចជាអព្យាកត ។ ក៏សច្ចៈទាំង ៤ ប្រការនេះបើពិចារណាដោយអំណាចខន្ធ ៥ មានរូបជាដើម ត្រូវពិចារណាបំបែកមួយខន្ធម្ដង ៗ ឲ្យបានជាសច្ចៈ ៤ ៗ ដូច្នេះថា សេចក្ដីសុខសោមនស្សឯណា ដែលកើតឡើងដោយសាររូបហៅថា សេចក្ដីត្រេកអរជ្រះថ្លារបស់រូប ចាត់ជាសមុទយសច្ច

ត្រាស់ដឹងបានដោយការលះបង់, រូបដែលមិនទៀងជាទុក្ខនឹងចេះតែប្រែប្រួលទៅ ហៅថា ទោសរបស់រូបកើតឡើងដោយសាររូប ចាត់ជាទុក្ខសច្ច ត្រាស់ដឹងបានដោយការកំណត់, ការលះបង់បាននូវសេចក្តីប្រាថ្នាក្នុងរូប ហៅថារលាស់ចោលនូវរូប ចាត់ជានិរោធសច្ច ត្រាស់ដឹងបានដោយកិរិយាធ្វើឲ្យជាក់ច្បាស់ អដ្ឋង្គិកមគ្គទាំង៨ មាន សម្មាទិដ្ឋិ សេចក្តីយល់ត្រូវក្នុងហេតុទាំង ៣ យ៉ាងនេះជាដើមហៅថា មគ្គសច្ច ត្រាស់ដឹងបានដោយកិរិយាចម្រើន ។ ឯវេទនាសញ្ញាសង្ខារ និងវិញ្ញាណ មានន័យដែលត្រូវចែកដូចគ្នា និងរូបខាងដើមនេះដែរ ។ ក្នុងកងអរិយសច្ចបើពោលដោយធម៌ដែលកើតអាស្រ័យត ៗគ្នា ដូច្នេះ គឺ ជរាមរណៈមានជាតិជាហេតុជាដែនកើត, ឧបាទានមានតណ្ហាជាហេតុជាដែនកើត, តណ្ហាមានវេទនាជាហេតុជាដែនកើត, វេទនាមានផស្សៈជាហេតុជាដែនកើត, ផស្សៈមានសឡាយតនៈជាហេតុជាដែនកើត, សឡាយតនៈមាននាមរូបជាហេតុជាដែនកើត, នាមរូបមានវិញ្ញាណជាហេតុជាដែនកើត, វិញ្ញាណមានសង្ខារជាហេតុជាដែនកើត, សង្ខារមានអវិជ្ជាជាហេតុជាដែនកើត, ។ ជរាចាត់

ជាទុក្ខសច្ច, ជាតិចាត់ជាសមុទយសច្ច, កិរិយារលាស់ផុតចាក ជរាមរណៈ ព្រមទាំងជាតិចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់ នូវនិរោធចាត់ជាមគ្គសច្ច, ជាតិចាត់ជាទុក្ខសច្ច, ភពចាត់ជា សមុទយសច្ច, កិរិយារលាស់ផុតចាកជាតិ និងភពចាត់ជានិរោធ-សច្ច, សេចក្តីដឹងច្បាស់ចាត់ជាមគ្គសច្ច, ឧបាទាននិងតណ្ហា ចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវនិរោធសច្ចចាត់ជាមគ្គសច្ច តណ្ហាចាត់ជាទុក្ខសច្ច, វេទនាចាត់ជាសមុទយសច្ច, កិរិយា រលាស់ផុតចាកតណ្ហានិងវេទនាចាត់ជានិរោធសច្ច សេចក្តីដឹង ច្បាស់នូវនិរោធចាត់ជាមគ្គសច្ច, វេទនាចាត់ជាទុក្ខសច្ច ផស្សៈ ចាត់ជាសមុទយសច្ច, កិរិយារលាស់ផុតចាកវេទនានិងផស្សៈ ចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច ផស្សៈចាត់ជាទុក្ខសច្ច, សឡាយតនៈចាត់ជាសមុទយសច្ច, កិរិយា រលាស់ផុតចាកផស្សៈ និងសឡាយតនៈ ចាត់ជានិរោធសច្ច សេច-ក្តីដឹងច្បាស់នូវនិរោធជាមគ្គសច្ច, សឡាយតនៈចាត់ជាទុក្ខ សច្ច, នាមរូបចាត់ជាសមុទយសច្ច, កិរិយារលាស់ផុតចាក សឡាយតនៈ និងនាមរូបចាត់ជានិរោធសច្ច, សេចក្តីដឹងច្បាស់នូវ

និរោធចាត់ជាមគ្គសច្ច, នាមរូបចាត់ជាទុក្ខសច្ច, វិញ្ញាណចាត់ជាសមុទយសច្ច, កិរិយារលាស់ផុតចាកនាមរូបនិងវិញ្ញាណចាត់ជានិរោធសច្ច, សេចក្ដីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច, វិញ្ញាណចាត់ជាទុក្ខសច្ច, សង្ខារចាត់ជាសមុទយសច្ច, កិរិយារលាស់ផុតចាកវិញ្ញាណនិងសង្ខារចាត់ជានិរោធសច្ច សេចក្ដីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច សង្ខារចាត់ជាទុក្ខសច្ច អវិជ្ជាចាត់ជាសមុទយសច្ច កិរិយារលាស់ផុតចាកសង្ខារនិងអវិជ្ជាចាត់ជានិរោធសច្ច សេចក្ដីដឹងច្បាស់នូវនិរោធចាត់ជាមគ្គសច្ច ។ ក៏ធម៌ទាំងឡាយមានអវិជ្ជាជាដើមនេះជាសភាវៈ, មិនមែនសត្វមិនមែនបុគ្គល មិនមែនខ្លួនប្រាណ មិនមែនគេមិនមែនយើងជាសភាវៈមួយៗ អាស្រ័យគ្នានិងគ្នាហើយកើតឡើងនឹងរលត់សូន្យទៅជាធម្មតា កាលដែលកើតឡើងដំបូងគឺអវិជ្ជា ។ មានហើយជាបច្ច័យឲ្យកើតសង្ខារ ។ មានហើយជាបច្ច័យនាំឲ្យកើតវិញ្ញាណ ។ មានហើយជាបច្ច័យឲ្យកើតនាមរូប ។ មានហើយជាបច្ច័យឲ្យកើតអាយតនៈ ។ មានហើយជាបច្ច័យឲ្យកើតផស្សៈ ។ មានហើយជាបច្ច័យឲ្យកើតវេទនា ។ មានហើយជាបច្ច័យឲ្យកើតតណ្ហា ។

Websites: WatKhemaraRatanaram.org or WatKhmers.org


មានហើយជាបច្ច័យឲ្យកើតឧបាទាន ៗ មានហើយជាបច្ច័យឲ្យកើតភព ៗ មានហើយជាបច្ច័យឲ្យកើតជាតិ ៗ មានហើយជាបច្ច័យឲ្យកើត ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សុបាយាសៈ ឡើងដូចជាភ្លើងដុតឲ្យក្តៅពោលពាលឥតអាក់ យ៉ាងនេះឯងជាធម៌អាស្រ័យគ្នានឹងគ្នាហើយកើតឡើង ញ៉ាំងសត្វឲ្យវិលវល់ក្នុងវដ្តសង្សារ ប្រព្រឹត្តទៅក្នុងអនាទិកាលរកដើមចុងគ្មាន ។ សេចក្តីទុក្ខលំបាកព្រោះតែជាតិ ជរាជាដើម នេះឈ្មោះថាទុក្ខសច្ច ព្រះជាគ្រូទ្រង់កំណត់ដឹងដោយបរិញ្ញាភិសម័យ, អវិជ្ជានិងតណ្ហាដែលជាឫសគល់នៃសង្សារវដ្ត ឬជាក្បាលនៃសង្សារវដ្តជាហេតុឲ្យកើតកងទុក្ខ ឈ្មោះថាសមុទយសច្ច ព្រះអង្គលះបង់ដោយបហានាភិសម័យ បើអវិជ្ជានិងតណ្ហា រលត់អស់ហើយ ធម៌ដទៃ ៗ មានសង្ខារវិញ្ញាណ នាមរូបជាដើម ដែលជាទុក្ខ ក៏រលត់ទៅផងដែរ សេចក្តីរលត់ទុក្ខនេះឯង ហៅថានិរោធសច្ច ព្រះអង្គធ្វើឲ្យច្បាស់ដោយសច្ឆិកិរិយាភិសម័យ, ដំណើរដែលធ្វើឲ្យរលត់ទុក្ខឈ្មោះថាមគ្គសច្ច ព្រះអង្គធ្វើឲ្យមានឡើងដោយភាវនាភិសម័យ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ក្នុងចតុរារិយសច្ចយ៉ាងនេះ ហើយញុំាងសត្វដទៃឲ្យដឹងផង ទើបទ្រង់ព្រះនាមថា " ពុទ្ធោ " ប្រែថា " ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង " ។

សព្វទស្សាវិតា ពុទ្ធោ ម្យ៉ាងវិញទៀត ព្រះមហាករុណាទ្រង់ព្រះនាមថា " ពុទ្ធោ " ព្រោះព្រះអង្គទ្រង់ឃើញភ័យទាំងពួងក្នុងអតីតៈ អនាគត បច្ចុប្បន្ន ។

ខីណាសវសង្ខាតេន ពុទ្ធោ ទ្រង់ព្រះនាមថា " ពុទ្ធោ " ព្រោះព្រះអង្គអស់អាសវៈទាំង ៣ គឺ កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

និរុបកិលេសសង្ខាតេន ពុទ្ធោ ទ្រង់ព្រះនាមថា " ពុទ្ធោ " ព្រោះព្រះអង្គប្រាសចាកកិលេស ១០ យ៉ាងគឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធចៈ ថីនមិទ្ធៈ អហិរិកៈ អនោតប្បៈ ។

ឯកាយ មគ្គំ គតោតិ ទ្រង់ព្រះនាមថា " ពុទ្ធោ " ព្រោះព្រះអង្គទ្រង់ព្រះពុទ្ធដំណើរតាមផ្លូវដែលមូលតែ ១ ត្រង់ស្លូងទៅកាន់អមតនិព្វាន គឺ មជ្ឈិមាបដិបទា ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ឯកោ អនុត្តរសម្មាសម្ពោធឹ អភិសម្ពុទ្ធោ ទ្រង់ព្រះនាមថា " ពុទ្ធោ " ព្រោះព្រះអង្គជាបុគ្គលឯកត្រាស់ដឹងនូវទសពលញ្ញាណ និងសព្វញ្ញុតញ្ញាណ មិនមានទេវតា ឥន្ទព្រហ្មណាប្រសើរស្មើ ។ ព្រះដ៏មានជោគ ប្រកបដោយគុណទាំងឡាយដូចថ្លែងមកនេះឯង បានជាទ្រង់ព្រះនាមថា " ពុទ្ធោ " ។

ចប់បទ " ពុទ្ធោ " ដោយសង្ខេប

Websites: WatKhemaraRatanaram.org or WatKhmers.org


## កែបទ " ភគវា "

បុ. ព្រះសម្ពុទ្ធបរមគ្រូ ហេតុអ្វីបានជាទ្រង់ព្រះនាមថា " ភគវា " ។

វិ. បានជាទ្រង់ព្រះនាមថា " ភគវា " ព្រោះព្រះអង្គមានព្រះភាគ, ព្រះអង្គជាអ្នកចែក, ព្រះអង្គមានជោគ, ព្រះអង្គជាអ្នកបំបាក់បង់, ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ ។

បុ. ដែលថា " ព្រះអង្គមានព្រះភាគ " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់មាន " ភាគ " គឺចំណែកកុសលដ៏ឧត្តមថ្លៃថ្លា មានទានសីលជាដើម អាចញុំាងលោកិយសុខ និងលោកុត្តរសុខឲ្យកើតឡើងដោយប្រការទាំងពួង ព្រោះហេតុនោះ បានជាទ្រង់ព្រះនាមថា " ភគវា " ប្រែថា " ព្រះអង្គមានព្រះភាគ " ។

បុ. ដែលថា " ព្រះអង្គជាអ្នកចែក " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធទ្រង់ចែករំលែកនូវធម៌ទាំងឡាយជាផ្នែក ៗ គឺ ធម៌ល្អចាត់ជាកុសល ធម៌អាក្រក់ចាត់ជាអកុសល ធម៌មិនល្អមិនអាក្រក់ចាត់ជាអព្យាកត: ជាដើម

Websites: WatKhemaraRatanaram.org or WatKhmers.org


ហើយបែងជាចិត្ត- ចេតសិក បំបែកជាភូមិ ៤ ជាដើម ហើយញែកធម៌ទាំងនោះជាខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ៍ អរិយសច្ចៈ បដិច្ច-សមុប្បាទជាដើម ដូច្នេះ ទើបទ្រង់ព្រះនាមថា " ភគវា " ប្រែថា " អ្នកចែក " ។

បុ. ដែលថា " ព្រះអង្គមានជោគ " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះពុទ្ធជាម្ចាស់ទ្រង់មានជោគ មានគ្រោះល្អ គ្រាកាលដែលទ្រង់ទើបបានត្រាស់ច្បាស់ជាព្រះអរហំសម្មាសម្ពុទ្ធជាដំបូង ទ្រង់ប្រកាសសាសនា ញ៉ាំងជនដទៃឲ្យលុះធម៌វិសេសកើតបានជាព្រះសង្ឃកុះករហើយ នឹងអាចញ៉ាំងវេនេយ្យសត្វក្រៅពីនោះ ឲ្យមានសទ្ធាជ្រះថ្លាតាំងនៅក្នុងព្រះពុទ្ធ-សាសនាបាន ។ ប្រការមួយទៀត កាលព្រះអង្គកំពុងប្រកាសសាសនានោះ ពួកជនទាំងឡាយដែលជាសត្រូវមានតិរ្ថិយជាដើម តែងប៉ងប្រាថ្នាល្បួងថ្វីដៃនឹងព្រះអង្គចង់បំបាក់ព្រះអង្គ តែព្រះអង្គមិនដែលថ្លោះធ្លោយ មិនដែលមានភ័យអន្តរាយអំពីសំ-ណាក់ជនជាសត្រូវទាំងឡាយមានតិរ្ថិយជាដើមនោះឡើយ មានតែព្រះអង្គឯងអាចធ្វើឲ្យជនទាំងនោះបាក់បបខ្លបខ្លាចវិញ ព្រោះ

ហេតុនោះបានជាទ្រង់ព្រះនាមថា " ភគវា " ប្រែថា " ព្រះអង្គមានជោគ " ។

បុ. ដែលថា " ព្រះអង្គអ្នកបំបាក់បង់ " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់កាច់កិនញាំញីកងកិលេសទាំងឡាយមាន លោភៈ ទោសៈ មោហៈ ជាដើម ឬថាកាច់កិនញាំញីនូវមារទាំង ៥ បានជាទ្រង់ព្រះនាមថា " ភគវា " ប្រែថា " ជាអ្នកកាច់បំបាក់ " ។

ឯមារទាំង ៥ នោះគឺ កិលេសមារ កិលេសទាំងពួងដែលបៀតបៀនសត្វ ១ ខន្ធមារ មារគឺខន្ធទាំង ៥ អភិសង្ខារមារ កុសលនិងអកុសលដែលបៀតបៀនសត្វ ១ មច្ចុមារ សេចក្តីស្លាប់ដែលបៀតបៀនសត្វ ១ ទេវបុត្តមារ ទេវបុត្តអ្នកបៀតបៀន ១ ។ កិលេសមារបានដល់កិលេស ១៥០០ រាប់យកលោកិយចិត្ត ៨១ ថាជាមួយ យកចេតសិក ៥២ មកផ្សំជា ៥៣ យកនិប្ផន្នរូប ១៨ មកផ្សំជា ៧១ យកអាកាស ១ ជាតិ ១ ជរា ១ ភវង្គ ១ មកផ្សំជា ៧៥ ចាត់ជាកិលេសខាងក្នុង ៧៥ ខាងក្រៅ ៧៥ ផ្សំជាមួយគ្នាជាកិលេស ១៥០ ហើយកិលេស ១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនមិទ្ធៈ អហិរិកៈ អនោតប្បៈ និងឧទ្ធច្ចៈ មកគុណ

និងកិលេស ១៥០ ត្រូវជាកិលេស ១៥០០ ។ កិលេសទាំង ១០ យ៉ាងនេះហើយដែលតែងញុំាងសត្វឲ្យបានសេចក្តីទុក្ខ ក្តៅក្រហាយក្នុងឥធលោក និងបរលោករកល្ហែគ្មាន បានជាឈ្មោះថា កិលេសមារ ។ ខន្ធមារនោះ បានដល់ឧបាទានក្ខន្ធទាំង ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ និង វិញ្ញាណូបាទានក្ខន្ធ ១ ។ ឧបាទានក្ខន្ធទាំង ៥ នេះដូចជាចោរ ៥ នាក់ជាប់តាមចាំបៀតបៀនពួកសត្វ ទើបឈ្មោះថាខន្ធមារ ។ អភិសង្ខារមារនោះបានដល់ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ គឺកុសលាកុសលដែលតាក់តែងសត្វឲ្យល្អឲ្យអាក្រក់ កុសលនិងអកុសល ទាំងនេះបាន ជាឈ្មោះថាមារ ពីព្រោះអកុសល ១២ គឺ លោភមូល ៨ ទោសមូល ២ មោហមូល ២ រមែងនាំសត្វឲ្យធ្វើកម្មផ្សេង ៗ ឲ្យបានសេចក្តីលំបាកក្នុងឥធលោក និងបរលោក ឯលោកិយកុសលទាំង ១៧ គឺកាមាវចរកុសល ៨ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ រមែងល្បួងលួងលោមសត្វឲ្យនៅវិលវល់កើតស្លាប់ជានិច្ចតែក្នុងភូមិទាំង ៣ នេះបានជាឈ្មោះថា អភិសង្ខារ

Websites: WatKhemaraRatanaram.org or WatKhmers.org


មារ ។ មច្ចុមារនោះ បានដល់មច្ចុរាជ គឺសេចក្តីស្លាប់ ហេតុតែសេចក្តីស្លាប់នោះតែងតែផ្តាច់ផ្តិលជីវិតសត្វ ទាំងពួងមិនឲ្យលឿនទៅមុខបាន ។ បានជាហៅថា មច្ចុមារ ។ ទេវបុត្តមារនោះ បានដល់ស្តេចមារាធិរាជ ដែលជាអ្នកចងសត្វទុក្ខដោយខ្សែទាំង ៣ គឺ រាគៈ ទោសៈ និងតណ្ហា ឲ្យបានសេចក្តីវិនាសដោយភ័យ ៥ ប្រការគឺ រាជភ័យ ចោរភ័យ ឧទកភ័យ អគ្គិយភ័យ ចារកភ័យ ភ័យទាំងនេះ តែងកើតឡើងព្រោះទេវបុត្តមារ ។ ព្រះមហាករុណាជាម្ចាស់ព្រះអង្គញាំញីនូវមារទាំង ៥ នេះបាន ទើបបានជាទ្រង់ព្រះព្រះនាមថា " ភគវា " ។

បុ. ដែលថា " ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ " អធិប្បាយដូចម្តេច ?

វិ. អធិប្បាយថា ព្រះបរមសាស្តាព្រះអង្គធ្វើនូវភពទាំង ៣ ឲ្យផុតហើយ គឺព្រះអង្គបានត្រេចរង្គត់ទាល់តែចប់ផុតអស់ភពទាំង ៣ ហើយទ្រង់លែងវិលត្រឡប់ទៅរកភពទាំងនោះវិញទៀតហើយ ទ្រង់ខ្ជាក់ចោលនូវដំណើរដែលត្រូវដើរទៅក្នុងត្រៃភព គឺលែងកើតទៀតហើយ បានជាទ្រង់ព្រះនាមថា " ភគវា " ប្រែថា " ព្រះអង្គមានព្រះដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ " ។

ព្រះសម្មាសម្ពុទ្ធ ប្រកបដោយគុណទាំងឡាយដូចសម្តែងមកនេះទើបទ្រង់ព្រះនាមថា " ភគវា " ។

ចប់បទ " ភគវា " ដោយសង្ខេប

ព្រះនាមទាំង ១០ ចប់ដោយសង្ខេប

អវសានកថា

បុ. ព្រះនាមរបស់ព្រះពុទ្ធជាម្ចាស់ទាំង ១០ រាប់តាំងអំពីអរហំដល់ភគវាជាទីបំផុតនរណាថ្វាយដល់ព្រះអង្គ ? ព្រះចៅសិរីសុទ្ធោទន និងព្រះនាងមហាមាយាទេវីថ្វាយឬ ?

វិ. មិនមានបុគ្គលណាមួយថ្វាយដល់ព្រះអង្គទេ មិនមែនព្រះចៅសិរីសុទ្ធោទន និងព្រះនាងមហាមាយាទេវី ឬក្សត្រីយ៍ជាព្រះញាតិវង្សទាំងប៉ែតសិបពាន់ ឬក៏ទេវតាដ៏វិសេសណា មានសក្កសន្តុសិតជាដើមថ្វាយទេ ព្រះនាមទាំង ១០ នេះ ជានេមិត្តិកនាម រមែងកើតប្រាកដឡើងដល់ព្រះពុទ្ធទាំងឡាយជាមួយនឹងកិរិយាបានព្រះសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ។

Websites: WatKhemaraRatanaram.org or WatKhmers.org


បុ. ចុះគុណ គឺព្រះនាមទាំងអម្បាលនេះបើរាប់បញ្ចូលក្នុងគុណដ៏សង្ខេប ៣ ខាងដើមគឺបញ្ញាគុណ ១ វិសុទ្ធិគុណ ១ ករុណាគុណ ១ តើព្រះនាមណារាប់ចូលក្នុងព្រះគុណណា ?

វិ. សម្មាសម្ពុទ្ធ, វិជ្ជាចរណសម្បន្នោ, លោកវិទូ, ទាំង ៣ នេះរាប់ចូលក្នុងបញ្ញាគុណ, អរហំ, សុគតោ, អនុត្តរោ ទាំង ៣ ព្រះនាមនេះរាប់ចូលក្នុងវិសុទ្ធិគុណ, បុរិសទម្មសារថី, សត្ថាទេវ-មនុស្សានំ, ពុទ្ធោ, ភគវា, ទាំង ៤ ព្រះនាមនេះរាប់ចូលក្នុងករុណាគុណ ។ ម្យ៉ាងទៀតគុណគឺ ព្រះនាម ១០ ចែកដោយសង្ខេបទៅទៀតមាន ២ យ៉ាងគឺ អត្តហិតគុណ គុណដែលជាប្រយោជន៍ចំពោះព្រះអង្គ ១ បរហិតគុណ គុណជាប្រយោជន៍ចំពោះសត្វដទៃ ១, អរហំ, សម្មាសម្ពុទ្ធោ, វិជ្ជាចរណសម្បន្នោ, សុគតោ, លោកវិទូ, ទាំង ៥ នេះជាអត្តហិតគុណ, អនុត្តរោ បុរិសទម្មសារថិ, សត្ថាទេវមនុស្សានំ ទាំង ៣ នេះជាបរហិត-គុណ ។ ឯព្រះនាម ២ គឺ ពុទ្ធោនិងភគវានេះជាអត្តហិតគុណផង ជាបរហិតគុណផង ។

ពណ៌នាអំពីពុទ្ធរតនៈចប់ដោយសង្ខេប

# ពណ៌នាអំពីធម្មរតនៈ

បន្ទាប់អំពីពុទ្ធរតនៈ មកនឹងពណ៌នាក្នុងធម្មរតនៈតទៅទៀត

បុ. សភាវៈ ដូចម្ដេច ហៅថា " ធម៌ " ? មានគុណដូចម្ដេច?

វិ. សភាវៈដែលពិត មែន ឬសភាវៈ ដែលត្រឹមត្រូវល្អ ហៅថា " ធម៌ " ក្នុងទីនេះ ។ ធម៌នោះមានគុណត្រង់រក្សាសត្វអ្នកប្រតិបត្តិតាម ល្អ មិនឲ្យធ្លាក់ទៅក្នុងទីទាប ឲ្យផុតចាកសេចក្ដីទុក្ខ ជាសភាវៈ សម្រាប់បំភ្លឺសត្វដែលមានសេចក្ដីល្ងង់ខ្លៅកំពុងងងឹតដោយមោហៈ ឲ្យភ្លឺស្វាងឡើងបាន ឲ្យស្គាល់គុណទោស ខុសត្រូវនឹងផ្លូវប្រតិបត្តិជាដំណើរទៅកាន់ស្ថានសួគ៌ ស្ថានព្រះនិព្វានបាន ជាគ្រឿងបំភ្លឺសត្វឲ្យស្វែងរកសេចក្ដីសុខឃើញហេតុនោះបានជាលោកប្រៀបថាព្រះធម៌ដូចជាប្រទីប សម្រាប់បំភ្លឺសត្វក្នុងលោក ឬដូចជាព្រះអាទិត្យ សម្រាប់បន្ទោរបង់នូវងងឹត កាលបើងងឹតខ្វាត់ចេញហើយ សត្វលោករមែងយល់ផ្លូវល្អ ដែលសម្រាប់សញ្ចរទៅកាន់ស្ថានដ៏ក្សេម ព្រះធម៌មានគុណអាចឃិតយោង ឬស្រោចស្រង់សត្វឲ្យបានសេចក្ដីសុខយ៉ាងនេះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


កែបទ " ស្វាក្ខាតោ ភគវតា ធម្មោ "

បុ. ព្រះធម៌មានគុណតែប៉ុណ្ណេះទេ ឬនៅមានទៀតដែរ ?

វិ. នៅមានច្រើនតទៅទៀតដូចពណ៌នាតទៅនេះ ។

បទនេះប្រែថា " ព្រះបរិយត្តិធម៌ និងព្រះនពលោកុត្តរធម៌ គឺព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកដ៏ពីរោះ ឬដោយប្រពៃ " ។

បុ. ធម៌ដូចម្តេច ហៅថា " បរិយត្តិធម៌ " ? ធម៌នោះពីរោះដូចម្តេចទៅ ?

វិ. ធម៌សម្រាប់ទន្ទេញស្វាធ្យាយ ហៅថា " បរិយត្តិធម៌ " បានដល់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ជាធម៌គឺព្រះអង្គសម្តែងដ៏ពីរោះដោយបទដើម បទកណ្តាល និងបទចុង ។ អធិប្បាយថា ព្រះភគវាជាម្ចាស់ សូម្បីទ្រង់សម្តែងតែគាថាមួយ ក៏គង់មានពីរោះគ្រប់ទាំង ៣ បទ គឺបទដើមពីរោះដោយបឋមបាទ បទកណ្តាលពីរោះដោយទុតិយបាទនិងតតិយបាទ បទចុងពីរោះដោយបច្ឆិមបាទ ។ បើទ្រង់សម្តែងសូត្រដែលមានអនុសន្ធិតែមួយ មានពីរោះបទដើមដោយនិទានរឿងរ៉ាវ ពីរោះបទចុង

ដោយនិគមវចនៈ គឺព្រះពុទ្ធដីកាដល់ត្រាស់សម្ដែងផ្ទួនម្ដងទៀត ពីរោះបទកណ្ដាល ដោយពាក្យបរិយាយសេសសល់ពីនោះទាំងប៉ុន្មាន ។ បើសម្ដែងសូត្រដែលមានអនុសន្ធិផ្សេងគ្នា បទដើមពីរោះដោយនិទានរឿងរ៉ាវនិងឧប្បត្តិហេតុ បទកណ្ដាលពីរោះដោយសមគួរដល់វេនេយ្យសត្វ និងអត្ថដ៏ក្បោះក្បាយ មិនឃ្លៀងឃ្លាតហើយនឹងមានហេតុមានឧទាហរណ៍ បទចុងពីរោះដោយពាក្យបន្ថែមជាហេតុជម្រុលសត្វអ្នកស្ដាប់ឲ្យមានសទ្ធា ។ ប្រការមួយសោតសាសនធម៌ទាំងអស់ មានពីរោះបទដើមដោយសីល ពីរោះបទកណ្ដាលដោយសមថវិបស្សនានិងមគ្គផល ពីរោះបទចុងដោយព្រះនិព្វាន ។ ម្យ៉ាងទៀត សាសនធម៌ពីរោះបទដើមដោយសមាធិ ពីរោះបទកណ្ដាលដោយវិបស្សនា និងមគ្គទាំងឡាយ ពីរោះបទចុងដោយផលនិងព្រះនិព្វាន ។ ម្យ៉ាងទៀត សាសនាធម៌នោះនាំមកនូវគុណដ៏ល្អដល់អ្នកស្ដាប់ ព្រោះសង្កត់សង្កិននូវនីវរណធម៌បាន ទើបឈ្មោះថាពីរោះបទដើមនាំមកនូវគុណដ៏ល្អដល់អ្នកប្រតិបត្តិ ព្រោះបានសេចក្ដីសុខដែលកើតឡើងអំពីសមថវិបស្សនា ទើបឈ្មោះថាពីរោះបទកណ្ដាលនាំមកនូវគុណដ៏ល្អ ដល់អ្នកប្រតិបត្តិដែលបានសម្រេច

ផលហើយ ព្រោះនាំមកនូវតាទិភាព ទើបឈ្មោះថាពីរោះបទចុង ។ ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដ៏ពីរោះដោយបទដើម បទកណ្តាល និងបទចុងដូចសេចក្តីដែលពណ៌នាមកនេះ ។

ន័យមួយទៀត ព្រះបរិយត្តិធម៌ឈ្មោះថា គឺព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយប្រពៃ ពីព្រោះជាធម៌ប្រកាសនូវសាសន-ព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ដ៏បរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។ អធិប្បាយថា សាសនោវាទ ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសាស្តាឈ្មោះថា សាសនព្រហ្មចរិយៈ ៗ អង្គនៃមគ្គទាំង ៨ ឈ្មោះថា មគ្គព្រហ្មចរិយៈ ។ ព្រហ្មចរិយៈទាំងពីរនេះ បរិ-បូណ៌ដោយអត្ថ និងព្យញ្ជនៈ បរិសុទ្ធិរកចន្លោះឱកាសនឹងបំពេញថែមទៀតមិនបាន ដូចយ៉ាងសតិបដ្ឋាន ៤ ជាដើម គង់នៅជា ៤ ដដែលមិនមានអ្នកប្រាជ្ញណាពោលថាខ្វះ ហើយបញ្ចូលថែមឲ្យទៅជា ៥ បាន និងជាធម៌បរិសុទ្ធិរកទោសគ្មាន ដូចជាអង្គមគ្គទាំង ៨ ដែលព្រះអង្គសម្តែងរួចហើយ នៅជា ៨ ដូចដែលឥតមានអ្នកប្រាជ្ញណា អាចពោលទោសតិះដៀលថាខុស

មិនសមត្រូវដកខ្លះចេញ ឬត្រូវបញ្ចូលថែមទៀតបានឡើយ ។ យ៉ាងនេះបានជាថា ព្រះបរិយត្តិធម៌ គឺព្រះដ៏មានព្រះភាគសម្តែងដោយប្រពៃ ។ ក៏ព្រះពុទ្ធវចនៈ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកដោយប្រពៃ ទាំងអស់នេះបើពោលដោយកិច្ចមានតែម្យ៉ាង, ដោយធម៌វិន័យមាន ២ យ៉ាង, ដោយវចនៈ និងបិដកមាន ៣ យ៉ាង, ដោយនិកាយមាន ៥ យ៉ាង, ដោយអង្គមាន ៩ យ៉ាង, ដោយធម្មក្ខន្ធមានប្រាំបីម៉ឺនបួនពាន់ ។

បុ. ពុទ្ធវចនៈ ដែលពោលដោយកិច្ចមានតែម្យ៉ាងនោះតើដូចម្តេច ?

វិ. ដែលពោលដោយកិច្ចមានតែម្យ៉ាងនោះដូច្នេះថា ព្រះពុទ្ធជាម្ចាស់តាំងពីពេលដែលព្រះអង្គបានត្រាស់ដឹងនូវ អនុត្តរសម្មាសម្ពោធិញ្ញាណមកទល់នឹង ចូលកាន់អនុបាទិសេសនិព្វានក្នុងរវាង ៤៥ ព្រះវស្សា ព្រះអង្គតែងសម្តែងធម៌ប្រោសទេវតានិងមនុស្ស និងនាគយក្សជាដើមឥតមានល្ហែ រួចពុទ្ធវចនៈទាំងអស់នោះរួមមកមានកិច្ច ឬរសតែម្យ៉ាងគឺវិមុត្តិរស ព្រោះហេតុនោះបានជាថា ព្រះពុទ្ធវចនៈទាំងអស់មានត្រឹមតែម្យ៉ាង ។

បុ. ចុះពុទ្ធវចនៈដែលមាន ២ គឺធម៌និងវិន័យនោះតើដូចម្តេច ?

វិ. ដែលមាន ២ នោះដូច្នេះថា ព្រះពុទ្ធដីការបស់ព្រះជាគ្រូទាំងអស់រាប់ចូលមកក្នុងពាក្យពីរម៉ាត់គឺ ធម៌ ១ វិន័យ ១ ។

ព្រះវិន័យបិដកទាំងមូលហៅថាវិន័យ ក្រៅពីនោះទាំងប៉ុន្មានហៅថា ធម៌ ព្រោះហេតុនោះបានជាព្រះមហាកស្សបត្ថេរពេលដែលធ្វើបឋមសង្គាយនា លោកមានថេរវាចាថា " យន្នូន មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយេយ្យាម ម្នាលអាវុសោទាំងឡាយ បើដូច្នោះមានតែយើងនាំគ្នាផ្ទាត់ផ្ទៀងរៀបរៀងធម៌ និង វិន័យឡើង " កាលដែលព្រះបរមគ្រូមានព្រះពុទ្ធដីកាផ្តាំនិងអានន្ទក៏សំដៅតែពាក្យ ២ ម៉ាត់នោះដែរថា " យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ម្នាលអានន្ទ ធម៌ឯណាដែលតថាគត បានសម្តែងហើយ វិន័យឯណាដែលតថាគតបានបញ្ញត្តិហើយ ដល់អ្នកទាំងឡាយ ធម៌និង វិន័យនោះដល់អំណើះតតអំពីតថាគតទៅ នឹងជាគ្រូអ្នករាល់គ្នាហើយ " ព្រះពុទ្ធវចនៈមានបការៈពីរដូច្នេះឯង ។

Websites: WatKhemaraRatanaram.org or WatKhmers.org


បុ. ពុទ្ធវចនៈ ដែលពោលដោយវចនៈមាន ៣ នោះតើអ្វីខ្លះ ?

វិ. ដែលពោលដោយវចនៈមាន ៣ នោះគឺ បឋមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលជាដំបូង ១ មជ្ឈិមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលត្រង់កណ្ដាល ១ បច្ឆិមពុទ្ធវចនៈ ព្រះពុទ្ធដីកាដែលទ្រង់មានព្រះបន្ទូលបង្ហើយចុងក្រោយបំផុត ១ ។ បឋមពុទ្ធវចនៈនោះដូចជាព្រះពុទ្ធដីកាដែលព្រះអង្គបានត្រាស់ជាដំបូង ទ្រង់មានព្រះទ័យសោមនស្សបន្លឺនូវឧទានវាចាឡើងចំពោះតណ្ហាថា អនេកជាតិសង្សារំ ។ បេ ។ តណ្ហានំ ខយមជ្ឈគា ។ បាលីគ្រប់គ្រាន់ព្រមទាំងសេចក្ដីប្រែដូចមានក្នុងពុទ្ធគុណស្រាប់[1] ។ បច្ឆិមពុទ្ធវចនៈ បានដល់ព្រះពុទ្ធដីកាផ្ដែផ្ដាំក្នុងពេលទៀបស្ដេចនឹងចូលកាន់ព្រះនិព្វានថា ហន្ទទានិ- ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថ “ នែភិក្ខុទាំងឡាយអើយ ម្ដងណេះតថាគតផ្ដាំអ្នករាល់គ្នា សង្ខារទាំងឡាយមានកិរិយាសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយរាល់គ្នាចូរកុំប្រមាទ ”។

---

១- មើលត្រង់ទំព័រលេខ ២០-២១ ។

ឯមជ្ឈិមពុទ្ធវចនៈ បានដល់ពាក្យដែលព្រះអង្គទ្រង់ពោលក្នុងចន្លោះកណ្តាលបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះទាំងអស់ ។

បុ. ព្រះពុទ្ធវចនៈ ដែលមានបការៈ ៣ ដោយអំណាចបិដកនោះដូចម្តេច ?

វិ. ព្រះពុទ្ធវចនៈ ទាំងអស់មានប្រភេទតែ ៣ គឺ វិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។ បាតិមោក្ខទាំងទាំង ២ គឺភិក្ខុ-បាតិមោក្ខ និង ភិក្ខុនីបាតិមោក្ខ, វិភង្គទាំង ២ គឺ ភិក្ខុវិភង្គ និង ភិក្ខុ-នីវិភង្គ, ខន្ធកៈ ទាំង ២២ មានមហាខន្ធកៈជាដើម, បរិវារៈ ១៦ មានកត្ថបញ្ញត្តិវារៈជាដើម ដែលព្រះថេរៈទាំងឡាយសមោធានរួបរួមក្នុងបឋមសង្គីតិ ហៅថា វិនយបិដក ។

ព្រះពុទ្ធវចនៈ ដែលមាននៅក្នុងនិកាយទាំង ៥ គឺទីឃនិ-កាយ សង្គ្រោះដោយសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ១, មជ្ឈិមនិកាយសង្គ្រោះដោយសូត្រ ២៥២ មានមូលបរិយាយ-សូត្រជាដើម ១, សំយុត្តនិកាយ សង្គ្រោះដោយសូត្រ ៧៧៦២ មានឱឃតរណសូត្រជាដើម ១, អង្គុត្តរនិកាយ សង្គ្រោះដោយសូត្រ ៩៥៥៧ មានចិត្តបរិយាទានសូត្រជាដើម ១, ខុទ្ទកនិ-

Websites: WatKhemaraRatanaram.org or WatKhmers.org


កាយ មានប្រភេទ ១៥ មានខុទ្ទកបាឋជាដើម ១, ហៅថា សុត្តន្តបិដក ។

ព្រះពុទ្ធវចនៈ ដែលមាននៅក្នុងគម្ពីរទាំង ៧ គឺធម្មសង្គណិ, វិភង្គ, ធាតុកថា, បុគ្គលប្បញ្ញត្តិ, កថាវត្ថុ, យមកៈ និងមហាបដ្ឋាន ហៅថា អភិធម្មបិដក ។

ក៏ពាក្យថា " វិន័យ " ប្រែថា " មានន័យផ្សេង ៗ " មានន័យវិសេស ឬថា " ច្បាប់សម្រាប់ទូន្មាន " ។ អធិប្បាយថា ច្បាប់របស់ព្រះសម្ពុទ្ធតែមួយមែនពិត ប៉ុន្តែមានប្រការផ្សេង ៗ ដូចជាបាតិមោក្ខុទ្ទេស ៥ ប្រការ ផ្សេងពីគ្នា អាបត្តិទាំង ៧ កងក៏ផ្សេងដោយឡែកពីនោះទៅទៀតគឺ បារាជិកមាន ៤ ប្រការ ផ្សេងដោយឡែកទៅ, សង្ឃាទិសេសមាន ១៣ ប្រការ ផ្សេងដោយឡែកទៅ, ផ្សេង ៗ ពីគ្នាដោយការដូច្នេះជាដើមទើបឈ្មោះថាមានន័យផ្សេង ៗ ។ ម្យ៉ាងទៀតវិន័យនេះមានន័យវិសេសឡើងដូចយ៉ាងអនុប្បញ្ញត្តិមានក្នុងសិក្ខាបទនីមួយ ៗ មានប្រយោជន៍ធ្វើឲ្យតឹងឡើងខ្លះ ឲ្យធូរចុះមកខ្លះយ៉ាងនេះទើបហៅថា មានន័យវិសេស, ប្រែថា " ច្បាប់សម្រាប់ទូន្មានកាយវាចា " ព្រោះ

វិន័យជាគ្រឿងទូន្មានកាយវាចាឲ្យមានរបៀបបែបផែន ឲ្យមានសណ្តាប់ធ្នាប់មិនឲ្យច្រឡោះបោះប្រព្រឹត្តអនាចារផ្សេង ៗ ។

ឯពាក្យថា " សុត្ត " ប្រែថា " សម្តែងចេញ " ថា " គឺព្រះដ៏មានព្រះភាគពោលដោយប្រពៃ " ថា " ញ៉ាំងប្រយោជន៍ឲ្យកើត " ថា " ខ្សែបន្ទាត់ " ថា " ដោតក្រង " ។

អធិប្បាយថា ព្រះសូត្រនេះឯងសម្តែងចេញនូវប្រយោជន៍ច្រើនប្រការ មានប្រយោជន៍ចំពោះខ្លួន និងប្រយោជន៍របស់អ្នកដទៃជាដើម ។ ប្រយោជន៍ទាំងអស់នោះ ព្រះដ៏មានព្រះភាគពោលដោយប្រពៃ គឺព្រះអង្គទ្រង់សម្តែងអនុលោមតាមអធ្យាស្រ័យនៃវេនេយ្យសត្វ ។ អាចញ៉ាំងប្រយោជន៍គ្រប់ជំពូកឲ្យកើតឡើងបាន បានជាពុទ្ធវចនៈត្រង់ដូចជាខ្សែបន្ទាត់នៃជាងឈើ គួរឲ្យវិញ្ញូជនទាំងឡាយកាន់យកជាបែបជាប្រមាណ ។ មិនជាពាក្យរាត់រាយទេ ជាពាក្យមានចង្កោម មានកម្រងដូចជាផ្កាដែលនាយមាលាការអ្នកប៉ិនប្រសប់ដោតក្រងជារបៀបល្អ ៗ ដោយការនេះឯងទើបឈ្មោះថា " សុត្ត " ។

ឯពាក្យថា " អភិធម្ម " ប្រែថា " ធម៌មានសេចក្តីចម្រើន

ធម៌ប្រកបដោយសេចក្តីកំណត់, ធម៌គួរបូជា, ធម៌មិនច្រឡំគ្នា, ធម៌ដ៏ក្រៃលែង ” ។

ដែលថា “ ធម៌មានសេចក្តីចម្រើន ” អធិប្បាយថា ព្រះយោគីណាដែលបានចម្រើនធម៌នោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទាំងពួង ញ៉ាំងឈានឲ្យកើតឡើងហើយរមែងបានទៅកើតក្នុងឈានភូមិទើបឈ្មោះថា “ មានសេចក្តីចម្រើន ” ។

ដែលថា “ ធម៌ប្រកបដោយសេចក្តីកំណត់ ” អធិប្បាយថា ធម៌នោះ, រមែងមានលក្ខណៈគ្រឿងកំណត់សំគាល់ដោយសភាវៈទាំងឡាយមានអារម្មណ៍ទាំង ៥ ជាដើម ។

ដែលថា “ ធម៌គួរបូជា ” អធិប្បាយថា ធម៌ទាំងឡាយនោះគួរដល់កិរិយាបូជាដោយពិត ព្រោះជាសេក្ខធម៌, អសេក្ខធម៌និងលោកុត្តរធម៌ជាដើម ។

ដែលថា “ ធម៌មិនច្រឡំគ្នា ” អធិប្បាយថា ធម៌ទាំងឡាយនោះ មិនច្រឡំគ្នាដោយសភាវៈមានផស្សៈ និងវេទនាជាដើម ។ ដែលថា “ ធម៌ដ៏ក្រៃលែង ” អធិប្បាយថា ធម៌ទាំងឡាយនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងដ៏ក្រៃលែង មាន

មហគ្គតធម៌ និង អប្បមាណធម៌និងអនុត្តរធម៌ជាដើម ។ ដោយការដែលរៀបរាប់មកនេះហៅថា " អភិធម្ម " ។

រួមប្រភេទទាំង ៣ គឺវិន័យ, ព្រះសូត្រ, ព្រះអភិធម្ម, ហៅថា បរិយត្តិ ឬព្រះត្រៃបិដក ។ សព្ទថា " បិដក " ប្រែថា " ចំណែក " ឬថា " ភាជនៈ " ព្រោះព្រះបរិយត្តិធម៌មានកិរិយាចែកនូវអត្ថច្រើនផ្នែកផ្សេងដោយឡែកពីគ្នា, ឬថា ភាជនៈសម្រាប់ទ្រនូវពុទ្ធវចនៈទាំងពួង ។ ព្រះត្រៃបិដកនោះ បើចែកជាទេសនាមាន ៣ គឺអាណាទេសនា ១ វោហារទេសនា ១ បរមត្ថទេសនា ១ ។ វិន័យបិដកដែលចាត់ជាអាណាទេសនា ព្រោះព្រះសម្ពុទ្ធសម្តែងដោយអាជ្ញា គឺក្រិត្យបញ្ញត្តិអំពីការខុសត្រូវ, សុត្តន្តបិដកចាត់ជាវោហារទេសនា ព្រោះព្រះអង្គសម្តែងដោយវោហារហេតុព្រះអង្គប៉ិនប្រសប់ក្នុងវិធីបញ្ចុះបញ្ចូលសត្វ, អភិធម្មបិដកចាត់ជាបរមត្ថទេសនា ព្រោះព្រះអង្គសម្តែងដោយបរមត្ថសាច់ធម៌ដ៏ជ្រាលជ្រៅ ហេតុព្រះអង្គឈ្លាសវៃក្នុងប្រយោជន៍ឧត្តម ។ ព្រះត្រៃបិដកបើចែកដោយសាសនាមាន ៣ គឺ យថាបរាធសាសនា ពាក្យប្រៀនប្រដៅតាមសមគួរដល់កំហុសរបស់សត្វ

បានដល់វិន័យបិដក ១ យថានុលោមសាសនា ពាក្យប្រៀនប្រដៅអនុលោមតាមសមគួរដល់អធ្យាស្រ័យ និងអនុលោម និងចរិតសត្វបានដល់សុត្តន្តបិដក ១ យថាធម្មសាសនា ពាក្យប្រៀនប្រដៅដ៏សមគួរដល់ធម៌ជាន់ខ្ពស់ ចំពោះសត្វដែលមានមាន: ខ្លាំងបានដល់អភិធម្មបិដក ១ ។ បើចែកដោយកថាមាន ៣ គឺ សំវរាសំវរកថា ព្រះពុទ្ធដីកាសម្ដែងអំពីការសង្រួម និងមិនសង្រួមដែលជាបដិបក្ខដល់អជ្ឈាចារ គឺការប្រព្រឹត្តល្មើសចាត់ជាវិន័យបិដក ១ ទិដ្ឋិនិវេឋនកថា ព្រះពុទ្ធដីកាសម្ដែងអំពីការលះបង់នូវទិដ្ឋិដែលជាបដិបក្ខដល់ទិដ្ឋិ ៦២ ចាត់ជាសុត្តន្ត-បិដក ១ នាមរូបបរិច្ឆេទកថា ព្រះពុទ្ធដីកាសម្ដែងអំពីការកំណត់នូវនាម និង រូបដែលជាបដិបក្ខដល់កិលេសមានរាគ: ជាដើមចាត់ជាអភិធម្មបិដក ១ ។ បើចែកដោយសិក្ខាមាន ៣ គឺ អធិសីល-សិក្ខា បានដល់វិន័យបិដក ១ អធិចិត្តសិក្ខា បានដល់សុត្តន្ត-បិដក ១ អធិបញ្ញាសិក្ខា បានដល់អភិធម្មបិដក ១ ។ បើចែកដោយបហាន មាន ៣ គឺ វិតិក្កមប្បហាន កិរិយាលះបង់នូវវិតិក្កមកិលេស ដែលជាសត្រូវដល់សីល ចាត់ជាវិន័យបិដក ១

បរិយុដ្ឋានប្បហាន កិរិយាលះបង់នូវបរិយុដ្ឋានកិលេសដែលជាសត្រូវដល់សមាធិ ចាត់ជាសុត្តន្តបិដក ១ អនុសយប្បហាន កិរិយាលះបង់នូវអនុសយកិលេស ដែលជាសត្រូវដល់បញ្ញា ចាត់ជាអភិធម្មបិដក ១ ។ ម្យ៉ាងទៀត តទង្គប្បហាន កិរិយាលះបង់នូវកិលេស បានដោយពេលដោយស្របក់ ចាត់ជាវិនយ-បិដក, វិក្ខម្ភនប្បហាន កិរិយាលះបង់នូវកិលេសដោយការសង្កត់សង្កិនញាំញី ចាត់ជាសុត្តន្តបិដក, សមុច្ឆេទប្បហាន កិរិយាលះបង់នូវកិលេសដោយផ្តាច់ផ្តិលដាច់ស្រឡះ ចាត់ជាអភិធម្មបិដក ។ បណ្តាបិដកទាំង ៣ បិដកមួយ ៗ មានជម្រៅគម្ភីរភាព ៤ គឺ ធម្មគម្ភីរៈ មានជម្រៅដោយបាលី ១ អត្ថគម្ភីរៈ មានជម្រៅដោយសេចក្តីនៃបាលីនោះ ១ ទេសនាគម្ភីរៈ មានជម្រៅដោយកិរិយាសម្តែងនូវបាលីនោះ ១ បដិវេធគម្ភីរៈ មានជម្រៅដោយការចាក់ធ្លុះចំពោះបាលី និងអត្ថរបស់បាលី ។ ន័យមួយទៀតថា ធម៌បានដល់ហេតុ, អត្ថ បានដល់ផលនៃហេតុ, ទេសនាបានដល់បញ្ញត្តិ គឺ ព្រះពុទ្ធដីកាដែលពោលមិនភ្លាត់តាមសមគួរដល់ធម៌ពិត បដិវេធ បានដល់អភិសម័យ

គឺការត្រាស់ដឹងជាលោកិយ និងលោកុត្តរ ។ ក្នុងបិដកទាំង ៣ មានភាសិត ៤ គឺពុទ្ធភាសិត ធម៌ដែលព្រះពុទ្ធទ្រង់សម្តែងផ្ទាល់ព្រះអង្គ ១ សាវកភាសិត ធម៌ដែលសាវកសម្តែង បានដល់អនង្គណសូត្រ និងសម្មាទិដ្ឋិសូត្រជាដើម ១ ឥសីភាសិត ធម៌ដែលឥសី ឬបរិព្វាជកសម្តែង បានដល់បរិព្វាជកវគ្គជាដើម ១ ទេវតាភាសិត ធម៌ដែលទេវតាមារព្រហ្មសម្តែងបានដល់របៀបពាក្យក្នុងទេវតាសំយុត្តជាដើម ១ ។ បរិយត្តិប្បភេទក្នុងបិដកមាន ៣ យ៉ាងគឺ អលគទ្ទូបមាបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិយបរិយត្តិ ១ ។ បរិយត្តិមានឧបមាដូចពស់មានពិសយ៉ាងក្លា គឺបរិយត្តិដែលបុគ្គលរៀនមិនល្អប្រកបដោយហេតុអាក្រក់មានប៉ងប្រាថ្នាតែបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម នឹងរៀនគ្រាន់តែប្រណាំងប្រជែង ដណ្តើមយកមុខគ្រាន់តែដោះពាក្យដំណេះដំនៀលជាដើមប៉ុណ្ណោះ រៀននូវធម៌ហើយមិនពិចារណាសេចក្តីនៃធម៌នោះដោយបញ្ញា មិនពិនិត្យឲ្យជាក់ច្បាស់ឲ្យបានគុណវិសេសដែលត្រូវបាន ត្រឡប់ជាបានតែសេចក្តីទុក្ខអស់កាលជាអង្វែង ព្រោះតែរៀនមិនល្អឧបមាដូចបុរសចង់

បានពស់ ក្រឡេកឃើញពស់ធំ លូកដៃទៅចាប់ត្រង់កន្ទុយ ពស់វាងាកបែរមកចឹក ជួនត្រូវកដៃ ជួនត្រូវដើមដៃជាដើម បុរសនោះរមែងដល់នូវមរណៈ បើពុំនោះទេក៏គង់ដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ព្រោះហេតុអ្វី ? ព្រោះតែខ្លួនចាប់មិនល្អ ពស់វាចឹកយ៉ាងណាមិញ មោឃបុរសក្នុងសាសនានេះដែលរៀនធម៌មិនល្អក៏ដូច្នោះដែរ បរិយត្តិបែបនេះហៅថា អលគទ្ទូបមាបរិយត្តិ ។ បរិយត្តិដែលបុគ្គលរៀនល្អ គឺរៀនប្រាថ្នានឹងបំពេញនូវសីលក្ខន្ធជាដើម ដើម្បីរលាស់ខ្លួនឲ្យផុតពីវដ្តទុក្ខ បរិយត្តិបែបនេះឈ្មោះ និស្សរណត្ថបរិយត្តិ ។ បរិយត្តិដែលព្រះខីណាស្រពលោកអ្នកលះកិលេសបានអស់ហើយ លោករៀនគ្រាន់តែរក្សាបវេណី រក្សាវង្សប៉ុណ្ណោះ បរិយត្តិបែបនេះឈ្មោះ ភណ្ឌាគារិយបរិយត្តិ ។

សេចក្តីប្រតិបត្តិក្នុងបិដកទាំង ៣ ហុចប្រយោជន៍ឲ្យផ្សេងគ្នាដូច្នេះ ភិក្ខុប្រតិបត្តិល្អក្នុងវិន័យរមែងបានត្រៃវិជ្ជា ព្រោះអាស្រ័យសីលសម្បត្តិ ។ ប្រតិបត្តិល្អក្នុងប្រសូត្ររមែងបានអភិញ្ញា ៦ ព្រោះអាស្រ័យសមាធិសម្បត្តិ ប្រតិបត្តិល្អក្នុងអភិធម្ម

Websites: WatKhemaraRatanaram.org or WatKhmers.org


រមែងបានបដិសម្ភិទា ៤ ព្រោះអាស្រ័យបញ្ញាសម្បត្តិ ។ បើប្រតិបត្តិខុសក្នុងព្រះវិន័យដល់នូវភាពទ្រុស្តសីល, ប្រតិបត្តិខុសក្នុងព្រះសូត្រដល់នូវភាពជាមិច្ឆាទិដ្ឋិ ប្រតិបត្តិខុសក្នុងព្រះអភិធម្មដល់នូវចិត្តក្ខេប ( ក្រឡុកចិត្ត ឬឆ្កួតចិត្ត ) ។ ព្រះពុទ្ធវចនៈ មានបការៈ ៣ ដូចពណ៌នាមកនេះ ។

បុ. ព្រះពុទ្ធវចនៈ មានបការៈ ៥ ចែកដោយនិកាយនោះតើដូចម្តេច ?

វិ. ចែកដោយនិកាយ ៥ នោះដូច្នេះ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

បុ. ពុទ្ធវចនៈ ចែកដោយអង្គ ៩ នោះគឺអ្វីខ្លះ ?

វិ. សុត្តៈ ១ គេយ្យៈ ១ វេយ្យាកណៈ ១ គាថា ១ ឧទាន ១ ឥតិវុត្តកៈ ១ ជាតកៈ ១ អព្ភូតធម្មៈ ១ និងវេទលៈ ១ ។ សុត្តៈនោះបានដល់ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និង បរិវារៈ ជាដើមផង បានដល់ពួកសូត្រក្នុងសុត្តនិបាតមានមង្គលសូត្រ រតនសូត្រ នាលកសូត្រ តុវដ្តកសូត្រជាដើមផង នឹងបានដល់ពុទ្ធ-

វចនៈ ដទៃដែលមានឈ្មោះថា សុត្តន្តៈផង ។ គេយ្យៈ បានដល់សូត្រប្រកបដោយគាថាទាំងអស់ ហើយនឹងសគាថកវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ។ វេយ្យាករណៈ បានដល់អភិធម្មបិដកទាំងអស់ និងសូត្រដែលមិនលាយដោយគាថា ហើយនឹងពុទ្ធវចនៈ ដទៃដែលមិនបានសង្រោះចូលក្នុងអង្គ ៨ នេះផង ។ គាថា បានដល់ធម្មបទ ថេរគាថាថេរីគាថាដែលជាគាថាសុទ្ធ ហើយមិនមានឈ្មោះថាសូត្រ ។ ឧទានៈ បានដល់សូត្រទាំង ៨២ ដែលប្រកបដោយគាថាអាស្រ័យសោមនស្ស-ញាណ ។ ឥតិវុត្តកៈ លោកសង្រ្គោះយកសូត្រ ១១០ ដែលពួកសាវកសម្តែងអាងដល់ព្រះពុទ្ធដីកាថា " វុត្តំ ហេតំ ភគវតា អាងដល់ព្រះពុទ្ធដីកានេះ ដែលព្រះមានជោគទ្រង់ត្រាស់សម្តែងហើយ " ដូច្នេះជាដើម ។ ជាតកៈ គឺរឿងរ៉ាវដែលព្រះអង្គសម្តែងស្រាវជ្រាវអំពីអតីតសំដៅយកជាតក ៥៥០ មានអបណ្ណក-ជាតកជាដើម ។ អព្ភូតធម្មៈ បានដល់ព្រះសូត្រទាំងអស់ដែលប្រកបដោយអច្ឆរិយព្ភូតធម៌ គឺធម៌ដែលព្រះអង្គសម្តែងមានពាក្យថា មិនដែលកើត ឥឡូវកើតឡើងហើយ ថាគួរអស្ចារ្យ

គួរសើច ដូចសូត្រមានបាលីថា ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ “ ម្នាលភិក្ខុទាំងឡាយ ធម៌មិនដែលកើត ហើយកើតឡើងបានគួរអស្ចារ្យ ៤ ប្រការនេះរមែងមានក្នុងអានន្ទ ” ដូច្នេះជាដើម ។ វេទល្លៈ គឺពួកសូត្រដែលគេសួរហើយបានចេះដឹងបានសេចក្ដីរីករាយ ហៅថា វេទល្លៈ ។ ពុទ្ធវចនៈមានអង្គ ៩ ដូចពណ៌នាមកនេះ ។

បុ. ដូចម្ដេច ពុទ្ធវចនៈដែលចែកដោយធម្មក្ខន្ធជា ៨៤០០០ ព្រះធម្មក្ខន្ធ ?

វិ. ព្រះពុទ្ធវចនៈទាំងអស់ មានប្រភេទ ៨៤០០០ចាត់ដោយធម្មក្ខន្ធតាមថេរវាចាដែលព្រះអានន្ទបានប្រកាសថា៖

ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេសហស្សានិ ភិក្ខុតោ

ចតុរាសីតិ សហស្សានិ យេ មេ ធម្មា បវត្តិនោ ។

ប្រែថា “ ធម៌ទាំងឡាយដែលមាននៅក្នុងហឫទ័យរបស់ខ្ញុំ ៨៤០០០ ព្រះធម្មក្ខន្ធនោះ, ខ្ញុំបានរៀនផ្ទាល់អំពីសំណាក់ព្រះពុទ្ធអង្គ ៨២០០០ ធម្មក្ខន្ធ រៀនអំពីសំណាក់ភិក្ខុ ២០០០ ធម្មក្ខន្ធ ” ។ ឯធម្មក្ខន្ធមួយ ៗ បើក្នុងព្រះសូត្រ, សូត្រដែល

Websites: WatKhemaraRatanaram.org or WatKhmers.org


មានអនុសន្ធិមួយ ហៅថា ធម្មក្ខន្ធ ១, សូត្រដែលមានអនុសន្ធិច្រើនត្រូវរាប់អនុសន្ធិមួយ ៗ ក្នុងសូត្រនោះថាជាធម្មក្ខន្ធមួយ ៗ, ក្នុងគាថាពន្ធ ពាក្យដែលសួរបញ្ហាចាត់ជាធម្មក្ខន្ធមួយ, ពាក្យដែលឆ្លើយក៏ចាត់ជាធម្មក្ខន្ធមួយដែរ ។ បើក្នុងអភិធម្ម ផ្នែកតិកៈ ទុកៈ មួយ ៗ ឬផ្នែកចិត្តវារៈ មួយ ៗ ចាត់ជាធម្មក្ខន្ធមួយ ៗ ។ ចំណែកខាងវិន័យមានរឿងមានមាតិកា មានបទភាជនីយៈ មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ មានកំណត់តិកៈ ហើយក្នុងរឿងមួយ ៗ ត្រូវចាត់ជាធម្មក្ខន្ធមួយ ៗ មាតិកាមួយ ៗ ចាត់ជាធម្មក្ខន្ធមួយ ៗ ដូចគ្នាតទៅ ។ ពុទ្ធវចនៈ ចែកដោយធម្មក្ខន្ធយ៉ាងនេះឯង ។

ឯវំតាវបរិយត្តិធម្មោ ស្វាក្ខាតោ

ព្រះបរិយត្តិធម៌ ដែលព្រះដ៏មានព្រះភាគសម្តែងហើយដោយប្រពៃដូចសេចក្តីដែលសម្តែងមកក្នុងខាងលើទាំងប៉ុណ្ណោះនេះ ។

បុ. ចុះចំណែកខាងលោកុត្តរធម៌ ដែលព្រះអង្គសម្តែងដោយប្រពៃនោះ តើដូចម្តេច ?

រ៉ៃ. លោកុត្តរធម៌ ដែលព្រះអង្គសម្តែងដោយប្រពៃនោះ គឺព្រះអង្គសម្តែងអំពីបដិបទា សេចក្តីបដិបត្តិមានសភាពសមគួរដល់ព្រះនិព្វាន ។ ក៏មានសភាពសមគួរដល់សេចក្តីបដិបត្តិ ព្រោះព្រះនិព្វានដែលបុគ្គលគប្បីដល់ ដោយសេចក្តីប្រតិបត្តិជាស្ពានបរិសុទ្ធិមិនមានកិលេសគឺ រាគៈ ទោសៈ មោហៈ រួចចំណែកខាងបដិបទា ដែលជាដំណើរទៅកាន់ព្រះនិព្វាន គឺត្រៃសិក្ខាសោតក៏ជាធម្មជាតិសម្រាប់ឃាត់កិលេសដែរ គឺ សីល ឃាត់រាគៈ ទោសៈ មោហៈ ដ៏គ្រោកគ្រោកដែលជាវិតក្កមៈ គឺសេចក្តីប្រព្រឹត្តកន្លងសិក្ខាបទដោយកាយវាចា ចំណែកសមាធិឃាត់កិលេស គឺ រាគៈ ទោសៈ មោហៈ យ៉ាងកណ្តាល ឯបញ្ញាឃាត់កិលេស គឺ រាគៈ ទោសៈ មោហៈ យ៉ាងល្អិតដែលឈ្មោះថា អនុស័យ ( កិលេសដែលត្រាំនៅក្នុងសន្តាន ) ។ នេះឯងជាផ្លូវប្រតិបត្តិដើម្បីដល់នូវព្រះនិព្វានមិនទាស់ទំនងគ្នា នឹងព្រះនិព្វានជាផ្លូវសមគួរមិតម្លូលហូរចូលមកក្នុងទីជាមួយគ្នា ប្រៀបដូចទឹកក្នុងស្ទឹងគង្គាហូរចុះទៅក្នុងទីជាមួយគ្នា មួយអន្លើដោយទឹកក្នុងស្ទឹងយមុនាស្មើគ្នាដោយពណ៌នា នឹងរស់មិនខុសពីគ្នាឡើយ ។ ព្រោះហេតុ

នោះហើយបានជាលោកុត្តរធម៌ឈ្មោះថា គឺព្រះដ៏មានព្រះភាគសម្តែងហើយដោយប្រពៃ ។

បុ. ចុះដូចម្តេចហៅថា " លោកុត្តរធម៌ " ?

វិ. លោកំ ឧត្តរន្តីតិ លោកុត្តរា ធម៌ស្រង់ឡើងនូវសត្វលោកហៅថា លោកុត្តរៈ ។ លោកា ឧត្តរន្តីតិ លោកុត្តរា ធម៌ស្ទួយឡើងនូវសត្វឲ្យឆ្លងចាកលោក ហៅថា លោកុត្តរៈ ។ លោកេ អតិរេកាតិ លោកុត្តរា ធម៌ប្រសើរឯកក្នុងលោកហៅថា លោកុត្តរៈ ។

បុ. លោកុត្តរធម៌នោះ បានដល់ធម៌ណាខ្លះ ?

វិ. បានដល់សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពល ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ និងព្រះនិព្វាន ១ ។

បុ. សតិប្បដ្ឋាន ៤ នោះគឺអ្វីខ្លះ ?

វិ. កាយានុបស្សនា សតិប្បដ្ឋាន តម្កល់ស្មារតី ពិចារណារាងកាយ ១ វេទនានុបស្សនា សតិប្បដ្ឋាន តម្កល់ស្មារតីពិចារណាវេទនា ១ ចិត្តានុបស្សនា សតិប្បដ្ឋាន តម្កល់ស្មារតី

Websites: WatKhemaraRatanaram.org or WatKhmers.org


ពិចារណាចិត្ត ១ ធម្មានុបស្សនា សតិប្បដ្ឋាន តម្កល់ស្មារតីពិចារណាធម៌ ១ ។

បុ. ត្រូវពិចារណារាងកាយដូចម្តេច ?

វិ. ត្រូវពិចារណាដូច្នេះថា ឱហ្ន៎! បឋវី[1] កាយជាដើមនេះមិនទៀងសោះទេ តែងតែមានទុក្ខមិនមែនខ្លួន ហើយក៏នឿយណាយប្រាសចាកដម្រេកស្ងប់រម្ងាប់មិនជាប់ចិត្ត ។ កាលពិចារណាថាមិនទៀងរមែងលះបង់និច្ចសញ្ញា កាលពិចារណាថាទុក្ខរមែងលះបង់សុខសញ្ញា កាលពិចារណាថាមិនមែនខ្លួនរមែងលះបង់អត្តសញ្ញា កាលនឿយណាយរមែងលះបង់សេចក្តីរីករាយ កាលប្រាសចាកដម្រេករមែងលះបង់រាគៈ កាលដែលស្ងប់រម្ងាប់រមែងលះបង់នូវសមុទយៈ កាលមិនជាប់ចិត្តរមែងលះបង់សេចក្តីប្រកាន់ ។ ត្រូវពិចារណានូវកាយយ៉ាងនេះហៅថា កាយានុបស្សនា សតិប្បដ្ឋាន ។

---

១- រាប់ដោយពិស្តារ បឋវីកាយពួកធាតុដី, អាបោកាយពួកធាតុទឹក, តេជោកាយពួកធាតុភ្លើង, វាយោកាយពួកធាតុខ្យល់, កេសកាយពួកសក់, លោមកាយពួករោម, ឆវីកាយពួកសម្បុរថ្ងៃ, ចម្មកាយពួកស្បែក, មំសកាយពួកសាច់, នហារុកាយពួកសរសៃ, អដ្ឋិកាយពួកឆ្អឹង, អដ្ឋិមិញ្ជកាយពួកខួរក្នុងឆ្អឹង ។

បុ. ភិក្ខុក្នុងសាសនានេះពិចារណារឿយ ៗ នូវវេទនាដូចម្តេច ?

វិ. ពិចារណាដូច្នេះថា ឱហ្ន៎! សុខ[1] វេទនាជាដើមនេះមិនទៀងសោះទេ តែងតែមានទុក្ខមិនមែនខ្លួនហើយក៏នឿយណាយប្រាសចាកដម្រេកស្ងប់រម្ងាប់ មិនជាប់ចិត្ត, កាលពិចារណាដូច្នេះហើយក៏លះបង់នូវធម៌បាន ជាលំដាប់ ៗ ដូចន័យមុន, ភិក្ខុពិចារណានូវវេទនាយ៉ាងនេះហៅថា វេទនានុបស្សនាសតិប្បដ្ឋាន ។

បុ. ភិក្ខុក្នុងសាសនានេះពិចារណារឿយៗ នៅចិត្តដូចម្តេច ?

វិ. ពិចារណាដូច្នេះថា ឱហ្ន៎! ចិត្ត[២] ដែលប្រកបដោយរាគៈ ជាដើមនេះមិនទៀងសោះទេ តែងតែនាំមកនូវសេចក្តីទុក្ខ

---

១- រាប់ដោយពិស្តារ សុខវេទនា ធម្មជាតិសោយអារម្មណ៍ជាសុខ, ទុក្ខវេទនា ធម្មជាតិសោយអារម្មណ៍ជាទុក្ខ, អទុក្ខមសុខវេទនា ធម្មជាតិសោយអារម្មណ៍មិនស្លោះជាទុក្ខជាសុខ, ចក្ខុសម្ផស្សវេទនា ដែលកើតអំពីចក្ខុពាល់ត្រូវអារម្មណ៍, សោតសម្ផស្សវេទនា ដែលកើតអំពីត្រចៀកពាល់ត្រូវអារម្មណ៍, ឃានសម្ផស្សវេទនា ដែលកើតអំពីច្រមុះពាល់ត្រូវអារម្មណ៍, ។ ២- រាប់ដោយពិស្តារ សរាគំ ចិត្តំ ចិត្តនៅមានរាគៈ, វិតរាគំ ចិត្តំ ចិត្តប្រាសចាករាគៈហើយ, សទោសំ ចិត្តំ ចិត្តនៅមានទោសៈ, វិតទោសំ ចិត្តំ ចិត្តប្រាសទោសហើយ, សមោហំ ចិត្ត ចិត្តនៅមានមោហៈ, វិតមោហំ ចិត្តំ ចិត្តប្រាសចាកមោហៈហើយ, សង្ខិត្តំ ចិត្តំ ចិត្តរួញរា, វិក្ខិត្តំ ចិត្តំ ចិត្តរវើរវាយ,.... ។

Websites: WatKhemaraRatanaram.org or WatKhmers.org


មិនមែនខ្លួន, ហើយក៏នឿយណាយ, ប្រាសចាកដម្រេក ស្ងប់រម្ងាប់, មិនជាប់ចិត្ត, កាលពិចារណាដូច្នេះក៏លះបង់នូវធម៌បាន ជាលំដាប់ ៗ ដូចគ្នា ។ ភិក្ខុពិចារណានូវចិត្តយ៉ាងនេះ ហៅថា ចិត្តានុបស្សនា សតិប្បដ្ឋាន ។

បុ. ភិក្ខុក្នុងសាសនានេះ ពិចារណានូវ[1] ធម៌រឿយ ៗ ដូចម្ដេច ?

វិ. ពិចារណាដូច្នេះថា ឱហ្ន៎! ធម៌នេះមិនទៀងសោះទេ នាំមកនូវសេចក្ដីទុក្ខ មិនមែនខ្លួន ហើយក៏នឿយណាយប្រាស ចាកដម្រេក ស្ងប់រម្ងាប់ មិនជាប់ចិត្ត, កាលពិចារណាថាមិន ទៀងរមែងលះបង់និច្ចសញ្ញា កាលពិចារណាថាជាទុក្ខ រមែង លះបង់នូវសុខសញ្ញា កាលពិចារណាថាមិនមែនខ្លួន រមែង លះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវ សេចក្ដីរីករាយ កាលប្រាសចាកដម្រេក រមែងលះបង់នូវរាគៈ កាលស្ងប់រម្ងាប់ រមែងលះបង់នូវសមុទយៈ កាលមិនជាប់ចិត្ត រមែងលះបង់នូវសេចក្ដីប្រកាន់ ភិក្ខុពិចារណានូវធម៌ យ៉ាងនេះ ហៅថា ធម្មានុបស្សនា សតិប្បដ្ឋាន ។

---

១- ធម៌ក្នុងទីនេះសំដៅយកនីវរណៈ ៥ ឧបាទានក្ខន្ធ ៥ អាយតនៈ ១២ ជាដើម ។

បុ. សម្មប្បធាន គឺសេចក្ដីព្យាយាមជាគ្រឿងតាំងទុកទូទៅព្រមមាន ៤ គឺអ្វីខ្លះ ?

វិ. សេចក្ដីព្យាយាមដើម្បីនឹងលះបាបធម៌ ដែលកើតឡើងហើយ ១ សេចក្ដីព្យាយាមដើម្បីញុំាងបាបធម៌ដែលមិនទាន់កើតឡើងមិនឲ្យកើតឡើងបាន ១ សេចក្ដីព្យាយាមដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឡើងឲ្យកើតឡើង ១ សេចក្ដីព្យាយាមញុំាងកុសលធម៌ដែលកើតឡើងហើយ ឲ្យចម្រើនឡើងដោយភិយ្យោភាពក្រៃលែងឡើង ១ ត្រូវជា ៤ ។

បុ. ឥទ្ធិបាទ ៤ ប្រការនោះគឺអ្វីខ្លះ ?

វិ. ឆន្ទិទ្ធិបាទ សេចក្ដីបំណងជាទីតាំងនៃឫទ្ធិ ១ វិរិយិទ្ធិ-បាទ សេចក្ដីប្រឹងប្រែងជាទីតាំងនៃឫទ្ធិ ១ ចិត្តិទ្ធិបាទ សេចក្ដីសន្សំត្រិះរិះជាទីតាំងនៃឫទ្ធិ ១ វិមំសិទ្ធិបាទ ប្រាជ្ញាដែលដឹងគ្រប់យ៉ាងជាទីតាំងនៃឫទ្ធិ ១ ត្រូវជា ៤ ។

បុ. ឥន្ទ្រិយ ៥ ប្រការនោះតើដូចម្ដេចខ្លះ ?

វិ. ឥន្ទ្រិយទាំង ៥ នោះដូច្នេះគឺ សទ្ធិន្ទ្រិយំ សេចក្ដីជឿចាត់ជារបស់ធំ ១ វិរិយិន្ទ្រិយំ សេចក្ដីព្យាយាមចាត់ជារបស់ធំ ១

Websites: WatKhemaraRatanaram.org or WatKhmers.org


សតិន្ទ្រិយំ សតិចាត់ជារបស់ធំ ១ សមាធិន្ទ្រិយំ សមាធិចាត់ជារបស់ធំ ១ បញ្ញិន្ទ្រិយំ បញ្ញាចាត់ជារបស់ធំ ១ ។

បុ. ចុះឥន្ទ្រិយទាំង ៥ នោះបរិសុទ្ធិដោយអាការៈប៉ុន្មានយ៉ាង ?

វិ. ឥន្ទ្រីយ៍ទាំង ៥ នោះបរិសុទ្ធិដោយអាការៈ ១៥ ក្នុងឥន្ទ្រីយ៍មួយ ៗ បរិសុទ្ធិដោយអាការ ៣ ៗ ដូច្នេះ សទ្ធិន្ទ្រីយ៍បរិសុទ្ធិដោយអាការៈ ៣ គឺ អស្សទ្ធេ បុគ្គលេ បរិវជ្ជយតោ ដោយវៀរបុគ្គលដែលគ្មានសទ្ធា ១ សទ្ធេបុគ្គលេ សេវិតោ ដោយគប់រកបុគ្គលដែលមានសទ្ធា ១ បសាទនីយេ សុត្តន្តេ បច្ចវេក្ខិតោ ដោយពិចារណាព្រះសូត្រដែលជាទីញ៉ាំងចិត្តឲ្យជ្រះថ្លា ១ ។ វីរិយិន្ទ្រីយ៍ បរិសុទ្ធិដោយអាការ ៣ គឺ កុសីតេ បុគ្គលេ បរិវជ្ជតោ ដោយចៀសវាងបុគ្គលខ្ជិលច្រអូស ១ អារទ្ធវីរិយេ បុគ្គលេ បដិសេវតោ ដោយគប់រកបុគ្គលដែលមានព្យាយាមប្រឹងប្រែង ១ សមប្បធានេ បច្ចវេក្ខិតោ ដោយពិចារណាសមប្បធានទាំងបួន ១ ។ សតិន្ទ្រីយ៍ បរិសុទ្ធិដោយអាការ ៣ គឺ មុដ្ឋស្សតិ បុគ្គលេ បរិវជ្ជយតោ ដោយវៀរបុគ្គលដែលមានសតិមិនខ្ជាប់ខ្ជួន ១ ឧបដ្ឋិតស្សតិ បុគ្គលេ បដិសេវតោ ដោយគប់រកបុគ្គលដែលមានសតិតម្កល់

មាំ ១ សតិប្បដ្ឋានេ បច្ចវេក្ខិតោ ដោយពិចារណាសតិប្បដ្ឋាន ទាំងបួន ១ ។ សមាធិន្ទ្រីយ៍ បរិសុទ្ធិដោយអាការ ៣ គឺ អសមាហិតេ បុគ្គលេ បរិវជ្ជតោ ដោយវៀរបុគ្គលដែលមានចិត្តរសាត់អណ្តែតមិនបានតម្កល់មាំ ១ សមាហិតេ បុគ្គលេ សេវិតោ ដោយសេពគប់បុគ្គលដែលមានចិត្តតម្កល់មាំ ១ ឈានវិមោក្ខេ បច្ចវេក្ខិតោ ដោយពិចារណានូវឈាន និង វិមោក្ខ ១ ។ បញ្ញិន្ទ្រីយ៍ បរិសុទ្ធិដោយអាការ ៣ គឺ ទុប្បញ្ញេ បុគ្គលេ បរិវជ្ជយតោ ដោយវៀរបុគ្គលដែលអប្បប្រាជ្ញា ១ បញ្ញវន្តេ បុគ្គលេ បដិវិតោ ដោយសេពគប់បុគ្គលដែលមានប្រាជ្ញា ១ គម្ភិរញ្ញាណចរិយំ បច្ចវេក្ខិតោ ដោយពិចារណានូវញាណចរិយៈ ដ៏ជ្រាលជ្រៅ ១ ។ ឥន្ទ្រីយ៍ទាំង ៥ នេះ បរិសុទ្ធិដោយវៀរបុគ្គល ៥ ពួក ដោយសេពគប់បុគ្គល ៥ ពួក ដោយពិចារណានូវព្រះសូត្រ ៥ រួមទាំងអស់ត្រូវជាអាការ ១៥ ។

បុ. ចុះឥន្ទ្រីយ៍ទាំង ៥ នោះ តើនឹងចម្រើនដោយអាការៈប៉ុន្មានយ៉ាង ?

វិ. ដោយអាការ ១០ យ៉ាងគឺ ក្នុងឥន្ទ្រិយមួយ ១ ចម្រើនឡើងដោយអាការពីរ ១ ដូច្នេះ អស្សទ្ធិន្ទ្រយំ បជហន្តោ សទ្ធិន្ទ្រិយំ

Websites: WatKhemaraRatanaram.org or WatKhemers.org


ភាវេតិ លះបង់នូវអស្សទ្ធិន្ទ្រីយ៍ ចម្រើនសទ្ធិន្ទ្រីយ៍ ១ សទ្ធិន្ទ្រិយំ ភាវេន្តោ អស្សទ្ធិន្ទ្រិយំ បជហាតិ លះបង់អស្សទ្ធិន្ទ្រីយ៍១ កោសជ្ជំ បជហន្តោ វីរិយិន្ទ្រិយំ ភាវេតិ លះបង់កោសជ្ជៈ ចម្រើនវីរិយិន្ទ្រីយ៍ ១ វីរិយិន្ទ្រិយំ ភាវេន្តោ កោសជ្ជំ បជហាតិ ចម្រើនវីរិយិន្ទ្រីយ៍ លះបង់កោសជ្ជៈ ១ បមាទំ បជហន្តោ សតិន្ទ្រិយំ ភាវេតិ លះបង់សេចក្ដីប្រមាទ ចម្រើនសតិន្ទ្រីយ៍ ១ សតិន្ទ្រិយំ ភាវេន្តោ បមាទំ បជហាតិ ចម្រើនសតិន្ទ្រីយ៍ លះបង់សេចក្ដីប្រមាទ ១ ឧទ្ធច្ចំ បជហន្តោ សមាធិន្ទ្រិយំ ភាវេតិ លះបង់ឧទ្ធច្ចៈ ចម្រើននូវសមាធិន្ទ្រីយ៍ ១ សមាធិន្ទ្រិយំ ភាវេន្តោ ឧទ្ធច្ចំ បជហាតិ ចម្រើននូវសមាធិន្ទ្រីយ៍ លះបង់នូវឧទ្ធច្ចៈ ១ អវិជ្ជំ បជហន្តោ បញ្ញិន្ទ្រិយំ ភាវេតិ លះបង់នូវអវិជ្ជា ចម្រើនបញ្ញិន្ទ្រីយ៍ឲ្យកើតឡើង ១ បញ្ញិន្ទ្រិយំ ភាវេន្តោ អវិជ្ជំ បជហាតិ ចម្រើនបញ្ញិន្ទ្រីយ៍ លះបង់អវិជ្ជា ១ ឥន្ទ្រីយ៍ ទាំង ៥ នោះបើបុគ្គលបានចម្រើនល្អហើយ ឈ្មោះថាធ្វើឲ្យបរិសុទ្ធិនូវមគ្គ និង ផល ។

បុ. បុគ្គលមិនគួរចម្រើននូវឥន្ទ្រីយ៍ទាំងនោះ មានប៉ុន្មានពួក ?

វិ. មាន ៨ ពួកគឺ សេក្ខបុគ្គល ៧ មានសោតាបត្តិមគ្គដ្ឋជាដើម មានអរហត្តមគ្គជាទីបំផុត នឹងរាប់កល្យាណបុថុជ្ជនមួយបញ្ចូលផងជា ៨ ។

បុ. ពល ( កម្លាំង ) ៥ នោះគឺអ្វីមួយ ?

វិ. សទ្ធា ១ វីរិយា ១ សតិ ១ សមាធិ ១ បញ្ញា ១ ត្រូវជា ៥ ។

បុ. ដូចម្ដេចហៅថា សទ្ធាពល ?

វិ. ធម្មជាតិមិនរំភើបក្នុងសភាព ដែលមិនគួរជឿហៅថាសទ្ធាពល ៗ នេះមានអត្ថថា " ជួយឧបត្ថម្ភសហជាតធម៌ទាំងឡាយ " ថា " សំអាតនូវកិច្ចទាំងឡាយមានកិរិយាត្រាស់ដឹងជាដើម " ថា " ជាគ្រឿងតម្កល់ ឬតាំងចិត្ត " ថា " ជាគ្រឿងផ្លូវផង់ចិត្ត " ថា " ជាគ្រឿងត្រាស់ដឹងនូវគុណវិសេស " ថា " ជាគ្រឿងត្រាស់ដឹងក្រៃលែង " ថា " ជាគ្រឿងត្រាស់ដឹងនូវសច្ចៈ " ថា " ជាធម្មជាតិញ៉ាំងបុគ្គលឲ្យប្រតិស្ឋាននៅក្នុងនិរោធ " ។

បុ. ដូចម្ដេចហៅថា វីរិយពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងកោសជ្ជៈ ហៅថា វីរិយពលដែលហៅថា វីរិយព្រោះមានអត្ថថា " ជួយឧបត្ថម្ភសហជាតធម៌

ទាំងឡាយ ” ថា “ គ្របសង្កត់នូវកិលេសទាំងឡាយ ” ថា “ សំអាតនូវកិច្ចមានបដិវេធៈ ជាដើម ” ថា “ ជាទីតាំងនៃចិត្ត ” ថា “ ជាគ្រឿងត្រាស់ដឹងនូវសច្ចៈ ” ថា “ ជាធម្មជាតិញ៉ាំងបុគ្គលឲ្យតាំងនូវក្នុងព្រះនិព្វាន ” ។

បុ. ដូចម្ដេចហៅថា សតិពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងសេចក្ដីប្រមាទ ហៅថា សតិពល ។ នេះមានអត្ថថា “ ជួយឧបត្ថម្ភនូវសហជាតធម៌ទាំងឡាយ ” ។ ល ។ ថា “ ជាធម្មជាតិញ៉ាំងបុគ្គលឲ្យប្រតិស្ឋាននៅក្នុងព្រះនិព្វាន ” ។

បុ. ដូចម្ដេចហៅថា សមាធិពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងឧទ្ធច្ចៈ ហៅថា សមាធិពល ។ នេះមានអត្ថថា “ ជួយឧបត្ថម្ភនូវសហជាតធម៌ទាំងឡាយ ” ។ ល ។ ថា “ ជាធម្មជាតិញ៉ាំងបុគ្គលឲ្យប្រតិស្ឋាននៅក្នុងព្រះនិព្វាន ” ។

បុ. ដូចម្ដេចហៅថា បញ្ញាពល ?

វិ. ធម្មជាតិមិនញាប់ញ័រក្នុងអវិជ្ជា ហៅថា បញ្ញាពល ។

Websites: WatKhemaraRatanaram.org or WatKhmers.org


នេះមានអត្ថថា " ជួយឧបត្ថម្ភនូវសហជាតធម៌ទាំងឡាយ " ។ល។ ថា " ជាធម្មជាតិញ៉ាំងបុគ្គលឲ្យប្រតិស្ឋាននៅក្នុងព្រះនិព្វាន " ។

បុ. ពោជ្ឈង្គ ( អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ) ៧ គឺអ្វីខ្លះ ?

វិ. ១- សតិសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ ។ សតិ ប្រែថា " សេចក្ដីរឭក " ឬថា " សេចក្ដីកំណត់បាន " ជាធម៌សំខាន់បំផុតក្នុងការញ៉ាំងប្រយោជន៍ឲ្យសម្រេច ព្រោះថា បុគ្គលនឹងធ្វើការងារឯណា ដោយកាយឬដោយវាចា លុះតែអាស្រ័យសតិនេះជាទីតាំងទើបការងារនោះសម្រេចបានតាមសេចក្ដីប្រាថ្នា ។ម្យ៉ាងទៀត សតិជាគ្រឿងគយគន់ ឬ រវាំងរក្សានូវទ្វារទាំងពួង មានចក្ខុទ្វារជាដើម មិនឲ្យអភិជ្ឈា និងទោមនស្សជាដើមចូលមកបានក្នុងពេលដែលអារម្មណ៍ទាំងឡាយមានរូបជាដើមមកខ្ទាំងខ្ទប់ ប្រៀបដូចជាអ្នករក្សាទ្វារព្រះរាជនិវេសន៍រមែងរវាំងមើលមនុស្ស ដែលគួរឲ្យចូលបាន បើមនុស្សណាគួរឲ្យចូលក៏បើកឲ្យចូលទៅ មនុស្សណាមិនគួរឲ្យចូលក៏ឃាត់មិនឲ្យចូល ព្រោះហេតុនោះ បានជាថាសតិនេះជាធម៌សំខាន់បំផុត តែថាសតិក្នុងទីនេះសំដៅត្រង់រឭកត្រូវ មានរឭកក្នុងសតិបដ្ឋាន ៤ ជាដើម ។

២- ធម្មវិចយសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងគឺ ធម្មវិចយៈ ។ ធម្មវិចយៈ ប្រែថា ប្រាជ្ញាពិចារណានូវធម៌ ហើយប្រតិបត្តិសមគួរតាមធម៌ដោយសេចក្ដីយល់ត្រូវ ដោយការពិនិត្យដែលល្មមជាឧបាយលះកិលេសបាន ។

៣- វីរិយសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺវីរិយៈ សេចក្ដីព្យាយាមប្រឹងប្រែងត្រូវតាមសម្មប្បធានទាំង ៤ ប្រការ ។

៤- បីតិសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបីតិ សេចក្ដីពេញចិត្ត ។ បីតិនេះជាហេតុនាំឲ្យបុគ្គលធ្វើកិច្ចទាំងពួងសម្រេច ពីព្រោះការអ្វី ៗ តោងអាស្រ័យសេចក្ដីត្រេកអរ សេចក្ដីពេញចិត្ត ទើបបុគ្គលប្រឹងធ្វើកើត ព្រោះហេតុនោះ កាលបើបីតិមានហើយជាគុណញុាំងកិច្ចទាំងពួងឲ្យសម្រេចបាន ។

៥- បស្សទ្ធិសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបស្សទ្ធិបានដល់ភាពនៃកាយនិងចិត្តស្ងប់រម្ងាប់ រៀបរយ ជាគុណនាំឲ្យសម្រេចកិច្ចទាំងពួង ពីព្រោះបុគ្គលនឹងធ្វើកិច្ចអ្វី ៗ ដោយកាយក្ដីដោយចិត្តក្ដី លុះតែកាយនឹងចិត្តស្ងប់គ្មានក្រវល់ក្រវាយទើបធ្វើបាន ។

៦- សមាធិសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសមាធិបានដល់ការតាំងចិត្តឲ្យស្ថិតនៅនឹងក្នុងអារម្មណ៍ ជាគុណនាំឲ្យឃើញត្រៃលក្ខណ៍ជាដើម ។

៧- ឧបេក្ខាសម្ពោជ្ឈង្គ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺឧបេក្ខាសេចក្តីព្រងើយកន្តើយ មិនសោមនស្ស មិនទោមនស្ស ជាគុណឲ្យសម្រេចប្រយោជន៍ទាំងពួងបាន ។

បុ. អដ្ឋង្គិកមគ្គទាំង ៨ គឺអ្វីមួយ ?

វិ. សម្មាទិដ្ឋិ បញ្ញាយល់ត្រូវ ១ សម្មាសង្កប្បោ គំនិតត្រិះរិះត្រូវ ១ សម្មាវាចា សំដីនិយាយត្រូវ ១ សម្មាកម្មន្តោ ការងារត្រូវ ១ សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមោ ព្យាយាមត្រូវ ១ សម្មាសតិ រឭកត្រូវ ១ សម្មាសមាធិ តម្កល់ចិត្តត្រូវ ១ ។

បុ. សម្មាទិដ្ឋិ បញ្ញាយល់ត្រូវដូចម្តេច ?

វិ. យល់ត្រូវដូច្នេះគឺ ទុក្ខេ ញាណំ យល់ក្នុងកងទុក្ខទាំង ១២ ទុក្ខសមុទយេ ញាណំ យល់ក្នុងហេតុដែលប្រជុំឲ្យកើតទុក្ខ, ទុក្ខ-និរោធេ ញាណំ យល់ក្នុងកន្លែងដែលរលត់ទុក្ខ, ទុក្ខនិរោធគា-

មិនិយា បដិបទាយ ញាណំ យល់ក្នុងសេចក្តីប្រតិបត្តិដែលជាដំណើរទៅកាន់កន្លែងរលត់ទុក្ខ, យ៉ាងនេះហៅថា សម្មាទិដ្ឋិ ។

បុ. ចុះសម្មាទិដ្ឋិនុ៎ះតើមានប៉ុន្មានយ៉ាង ?

វិ. មាន ២ យ៉ាងគឺ លោកិយសម្មាទិដ្ឋិ បញ្ញាយល់ត្រូវជាលោកិយៈ គឺយល់ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ១ លោកុត្តរសម្មាទិដ្ឋិ បញ្ញាយល់ត្រូវជាលោកុត្តរៈ គឺយល់ក្នុងសច្ចធម៌ទាំង ៤ មានទុក្ខសច្ចជាដើម ១, បើចែកតាមឈ្មោះបុគ្គលវិញសម្មាទិដ្ឋិមាន ៣ គឺបុថុជ្ជនសម្មាទិដ្ឋិ បញ្ញាយល់ត្រូវរបស់បុថុជ្ជន ១ សេក្ខសម្មាទិដ្ឋិ បញ្ញាយល់ត្រូវរបស់សេក្ខ-បុគ្គល ៧ ជំពូកមានសោតាបត្តិមគ្គដ្ឋៈ ជាដើមអរហត្តមគ្គដ្ឋៈ ជាបរិ-យោសាន ១ អសេក្ខសម្មាទិដ្ឋិ បញ្ញាយល់ត្រូវនៃអសេក្ខបុគ្គល គឺព្រះអរហត្តផលដ្ឋៈ ១ ។

បុ. សម្មាសង្កប្បោ គំនិតត្រិះរិះត្រូវដូចម្តេច ?

វិ. គំនិតត្រិះរិះត្រូវដូច្នេះគឺ នេក្ខម្មសង្កប្បោ ត្រិះរិះដើម្បីចេញចាកកាមគុណ, អព្យាបាទសង្កប្បោ ត្រិះរិះដើម្បីមិនព្យាបាទ អវិហឹង្សាសង្កប្បោ ត្រិះរិះដើម្បីមិនបៀតបៀន យ៉ាងនេះ

ហៅថា សម្មាសង្កប្បោ ។ ប្រការមួយសោត សម្មាទិដ្ឋិ បញ្ញាយល់ត្រូវយ៉ាងណាត្រិះរិះតាមយ៉ាងនោះ តាមដំណើរដែលយល់នោះ ដូច្នេះក៏ហៅថា សម្មាសង្កប្បោ ។

បុ. សម្មាវាចា សំដីនិយាយត្រូវដូចម្តេច ?

វិ. សំដីនិយាយត្រូវតាមដំណើរសម្មាទិដ្ឋិគឺ មុសាវាទា-វេរមណី វៀរពាក្យកុហក, បិសុណាយ វាចាយ វេរមណី វៀរពាក្យញុះញង់ ឬអុចអាល, ផរុសាយ វាចាយ វេរមណី វៀរពាក្យទ្រគោះឃ្លើសឃ្លង, សម្ផប្បលាបា វេរមណី វៀរពាក្យឥតប្រយោជន៍, យ៉ាងនេះហៅថា សម្មាវាចា ។

បុ. សម្មាកម្មន្តោ ការងារត្រូវដូចម្តេច ?

វិ. ការងារត្រូវគឺ បាណាតិបាតា វេរមណី វៀរបាណាតិ-បាត, អទិន្នាទានា វេរមណី វៀរអទិន្នាទាន, កាមេសុមិច្ឆាចារា វេរមណី វៀរការប្រព្រឹត្តខុសក្នុងកាម, ហើយប្រព្រឹត្តធ្វើការកុសលដែលសម្រេចដោយផ្លូវកាយ មានបោសច្រាស់ទីលានព្រះចេតិយ៍ជាដើម យ៉ាងនេះហៅថា សម្មាកម្មន្តោ ។

បុ. សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវដូចម្តេច ?

វិ. ចិញ្ចឹមជីវិតត្រូវ គឺលះមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុស ( បើគ្រហស្ថលះជំនួញ ៥ ប្រការជាដើម បើអ្នកបួសលះអនេសនៈ ២១ នឹងបាបធម៌ ៥ ) ហើយចិញ្ចឹមជីវិតដោយសម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ យ៉ាងនេះហៅថា សម្មាអាជីវោ ។

បុ. សម្មាវាយាមោ ព្យាយាមត្រូវដូចម្តេច ?

វិ. ព្យាយាមត្រូវ គឺ ញ៉ាំងឆន្ទៈ ឲ្យកើតប្រារព្ធព្យាយាមផ្គងចិត្តឡើងដើម្បីមិនឲ្យកើតអកុសលធម៌ ដ៏លាមកដែលមិនទាន់កើតឡើង ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ, ដើម្បីញ៉ាំងកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង នឹងដើម្បីញ៉ាំងកុសលធម៌ដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរនៅ, ឲ្យចម្រើនពេញលេញជាភិយ្យោភាពឡើង, យ៉ាងនេះហៅថា សម្មាវាយាមោ ។

បុ. សម្មាសតិ រឭកត្រូវដូចម្តេច ?

វិ. រឭកក្នុងសតិបដ្ឋានទាំង ៤ កំចាត់បង់អភិជ្ឈានទោមនស្សក្នុងលោកនឹងរឭកដល់អនុស្សតិទាំង ១០ យ៉ាងនេះ ហៅថា សម្មាសតិ ។

បុ. សម្មាសមាធិ តម្កល់ចិត្តត្រូវដូចម្ដេច ?

វិ. ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ចាកអកុសលធម៌ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កវិចារៈ មានបីតិ និង សុខៈ ដែលកើតអំពីវិវេក ។ ដល់រម្ងាប់នូវវិតក្កៈ និង វិចារៈចូលកាន់ ទុតិយជ្ឈាន ដែលមានសទ្ធាដ៏រងថ្លាផូរផង់តាំងនៅខាងក្នុងជា គ្រឿងញុំាងសមាធិចិត្តយ៉ាងឯកឲ្យកើតឡើង មិនមានវិតក្កៈ វិចារៈ មានតែបីតិ និង សុខៈដែលកើតអំពីសមាធិ ។ ជាអ្នកព្រងើយ កន្តើយព្រោះខ្ពើមបីតិ មានស្មារតី មានប្រាជ្ញាដឹងសព្វ នឹងសោយ សុខដោយកាយផង រួចចូលកាន់តតិយជ្ឈាន ។ ចូលកាន់ ចតុត្ថជ្ឈានមានស្មារតីដ៏ស្អាតដែលកើតអំពីឧបេក្ខា ឥត ទុក្ខ ឥត ភ័យព្រោះលះបង់នូវសុខ និង ទុក្ខផង ព្រោះអស្ដង្គតរលត់ទៅ នៃសោមនស្ស និង ទោមនស្សអំពីមុនផង យ៉ាងនេះ ហៅថា សម្មាសមាធិ ។

បុ. អដ្ឋង្គិកមគ្គទាំង ៨ នេះ បើសង្គ្រោះចូលក្នុងកម្មទាំង ៣ គឺ កាយកម្ម វចីកម្ម និង មនោកម្ម តើអង្គណាសង្គ្រោះចូលក្នុង កម្មណា ?

វិ. សម្មាវាចា សង្គ្រោះចូលក្នុងវចីកម្ម, សម្មាកម្មន្តោ ចូលក្នុងកាយកម្ម, សម្មាអាជីវោ ចូលក្នុងកាយកម្មផងវចីកម្មផង, សម្មាទិដ្ឋិ, សម្មាសង្កប្បោ, សម្មាវាយាមោ, សម្មាសតិ និងសម្មាសមាធិ, សង្គ្រោះចូលក្នុងមនោកម្ម ។

បុ. ចុះបើចាត់ចូលក្នុងខន្ធទាំង ៣ គឺ សីលក្ខន្ធ សមាធិក្ខន្ធ និង បញ្ញាក្ខន្ធវិញ អង្គណាសង្គ្រោះចូលក្នុងខន្ធណា ?

វិ. សម្មាទិដ្ឋិ និង សម្មាសង្កប្បោ សង្គ្រោះចូលក្នុងបញ្ញាក្ខន្ធ, សម្មាវាចា សម្មាកម្មន្តោ និងសម្មាអាជីវោ សង្គ្រោះចូលក្នុងសីលក្ខន្ធ, សម្មាវាយាមោ សម្មាសតិ និង សម្មាសមាធិ សង្គ្រោះចូលក្នុងសមាធិក្ខន្ធ ។

បុ. ក្នុងអដ្ឋង្គិកមគ្គនេះ ហេតុអ្វីបានជាចាត់បញ្ញាទុកខាងដើម សីលនៅកណ្តាល, សមាធិនៅខាងចុង, រួចក្នុងត្រៃសិក្ខាបែរជាចាត់សីល ទុកខាងដើម, សមាធិនៅកណ្តាល,បញ្ញានៅខាងចុងវិញ ?

វិ. ក្នុងអដ្ឋង្គិកមគ្គនេះ បានជាចាត់បញ្ញាទុកជាខាងដើម ព្រោះបញ្ញាក្នុងអដ្ឋង្គិកមគ្គនេះ គ្រាន់តែជាបញ្ញាអមផង ជាហេតុ

ផង ព្រោះក្នុងអដ្ឋង្គិកមគ្គលើកសមាធិជាធំ ធម៌ ៧ ខាងដើម ជាបរិក្ខារបស់សមាធិ, ឯក្នុងត្រៃសិក្ខាលោកចាត់សមាធិជាហេតុ បញ្ញាជាផល ។ ហេតុនិងផល រមែងផ្លាស់ប្តូរគ្នាបាន កាលបើបញ្ញានៅខ្ចី បញ្ញាជាហេតុសមាធិជាផល ដល់បញ្ញាចាស់ក្លា បញ្ញាជាផល សមាធិជាហេតុវិញ ដូចក្នុងអដ្ឋង្គិក-មគ្គទុកសមាធិជាខាងដើម ព្រោះឃើញត្រូវហើយ ទើបរក្សាសីល ទើបធ្វើសមាធិជាខាងក្រោយ បានជាថាសមាធិជាហេតុ, លុះដល់ចម្រើនសមាធិចិត្តចាស់ក្លា ទើបចម្រើនវិបស្សនាជាខាងក្រោយ វិបស្សនាបញ្ញាកើតមកពីសមាធិ សមាធិកើតមកពីសីល សីលកើតមកពីបញ្ញាដែលឃើញត្រូវពីខាងដើម ឧបមាដូចអ្នកដាំដើមឈើ មុនដំបូងយកផ្លែទៅដាំ ដាំដុះមកបានជាដើមត្រូវធ្វើរបងព័ទ្ធជុំវិញ ហើយស្រោចទឹក ឈើក៏លូតលាស់ធំឡើងមានផ្លែ បានឈ្មោះថាផ្លែកើតមកពីដើម ៗ កើតមកពីពូជ ។ ក្នុងអដ្ឋង្គិកមគ្គទាំង ៨ នោះ សម្មាទិដ្ឋិ សម្មា-សង្កប្បោ ជាពូជ, សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ជារបង, សម្មាវាយាមោ សម្មាសតិ ទាំងពីរជាទឹកសម្រាប់ស្រោច

សម្មាសមាធិជាតួដើម, ផ្លែគឺវិបស្សនាបញ្ញា ។ ព្រោះហេតុនោះបានជាថា ហេតុនិងផលផ្លាស់ប្តូរគ្នាទៅវិញទៅមកបាន ។

បុ. មគ្គនោះប្រែដូចម្តេច ?

វិ. ប្រែថា ផ្លូវជាទីទៅកាន់ព្រះនិព្វាន ឬថា សភាវៈសម្លាប់កិលេសបណ្តើរទៅបណ្តើរ ដូចវិគ្គហៈថា កិលេសេ មារេន្តោ គច្ឆតីតិ មគ្គោ ។ សភាវៈ ឯណាសម្លាប់កិលេសបណ្តើរទៅបណ្តើរ សភាវៈនោះ ហៅថា មគ្គ ។

បុ. មគ្គដែលលះកិលេសនោះតើលះកិលេសជាអតីត ឬអនាគត ឬបច្ចុប្បន្ន ?

វិ. កិលេសជាអតីតក៏មិនលះ អនាគតក៏មិនលះ ជាបច្ចុប្បន្នក៏មិនលះ ។

បុ. បើកិលេសជាអតីត អនាគត បច្ចុប្បន្នមិនលះទេ បើដូច្នេះ មគ្គភាវនា ( ការចម្រើននូវមគ្គ ) មិនឥតប្រយោជន៍ទៅហើយឬ ?

វិ. មិនមែនឥតប្រយោជន៍ទេ ព្រោះកិលេសដែលកន្លងទៅហើយក្តីដែលមិនទាន់មានក្តី ដែលជាបច្ចុប្បន្នក្តី មិនត្រូវ

មគ្គលះទេ ដែលមគ្គត្រូវលះនោះគឺ លះតែហេតុនិងបច្ច័យរបស់កិលេសទាំងឡាយនោះទេតើ ឧបមាដូចដើមឈើដែលទើបដុះនៅមិនទាន់មានផ្លែនៅឡើយ បើគេប្រាថ្នានឹងកាប់ មិនឲ្យដុះលូតលាស់តទៅទៀត គេមិនកាប់ពូជផ្លែពីដើម ឬផ្លែដែលមិនទាន់មាន ឬដើមដែលទើបនឹងដុះថ្មីនោះទេ គេតែងជីករំលើងឫសចោល ទើបបានវាមិនដុះឡើងទៀត ។ មគ្គវេទនា ទុកដូចជាអ្នកកាប់ឈើ ផ្លែដែលជាពូជទុកដូចជាកិលេសអតីត ផ្លែដែលមិនទាន់មានមក ទុកដូចជាកិលេសជាអនាគត ដើមឈើដែលទើបនឹងដុះឡើងថ្មីនោះទុកដូចជាខន្ធ ៥ ឫសទុកដូចជាហេតុនៃកិលេស បើលះកិលេសដែលជាហេតុបានហើយ កិលេសទាំងអស់នោះ ក៏សាបសូន្យទៅផង ដូចដើមឈើដែលគេគាស់រំលើងឫសនោះដែរ ។

បុ. មគ្គនោះតើមានប៉ុន្មានយ៉ាង ?

វិ. មាន ៤ យ៉ាងគឺ សោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អានាគាមិមគ្គ ១ អរហត្តមគ្គ ១ ។

បុ. ចុះផលមានប៉ុន្មានយ៉ាង ?

Websites: WatKhemaraRatanaram.org or WatKhmers.org


វិ. មាន ៤ យ៉ាងដែរគឺ សោតបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។

បុ. មគ្គ សម្រាប់លះកិលេស, ចុះផលសម្រាប់លះអ្វីដែរ ?

វិ. ផលមិនត្រូវមុខការលះអ្វីទេ គ្រាន់តែសម្រាប់សោយសេចក្ដីសុខប៉ុណ្ណោះប្រៀបដូចមនុស្សមានរោគ ដល់ពេលដែលជារោគបានសេចក្ដីសុខហើយមិនត្រូវដាក់ថ្នាំទៀតទេ កិលេសទុកដូចរោគ មគ្គទុកដូចថ្នាំ ការដែលជារោគបានសេចក្ដីសុខទុកដូចផល ព្រោះហេតុនោះបានជាផលមិនត្រូវលះកិលេសទៀត សម្រាប់តែសោយសេចក្ដីសុខប៉ុណ្ណោះ ។

បុ. លោកុត្តរធម៌ប្រែថា ធម៌ជាគ្រឿងឆ្លងចាកលោកទាំង ៣ គឺ កាមលោក រូបលោក និង អរូបលោក , ចុះហេតុអ្វីដូចជាលោកដែលបានកុត្តរធម៌ គឺ សោតា, សកទាគា, អនាគា, ហើយក៏នៅកើតក្នុងលោកទៀត ? បើដូច្នោះពាក្យដែលថាឆ្លងចាកលោកមិនខុសទៅហើយឬ ?

វិ. មិនខុសទេ ព្រោះលោកុត្តរធម៌នោះជាគ្រឿងឆ្លងចាកលោកពិតមែន ដូចជាមគ្គដែលលះកិលេសឯណាបានហើយ កិលេសនោះមិនដែលត្រឡប់មកនាំសត្វឲ្យកើតទៀតទេ

ឯលោកដែលនៅកើតទៀតនោះ កើតដោយអំណាចធម៌ជាលោកិយទេតើ លោកបានលោកុត្តរធម៌មែន ប៉ុន្តែលោកុត្តរធម៌នោះ លះកិលេសមិនទាន់អស់ កិលេសដែលសេសសល់ទាំងអម្បាលម៉ាននោះឯងដែលនាំលោកឲ្យកើតទៀត ។ កុសលាកុសលធម៌ដែលតែងនាំសត្វឲ្យកើតដូចអកុសលចិត្ត ១២ នាំសត្វឲ្យកើតក្នុងអបាយភូមិ ៤ , មហាកុសល ៨ នាំសត្វឲ្យកើតក្នុងស្ថានសួគ៌ ៦ ជាន់ និងមនុស្សលោក, រូបាវចរកុសល ៥ នាំសត្វឲ្យកើតក្នុងរូបព្រហ្ម, អរូបាវចរកុសល ៤ នាំសត្វឲ្យកើតក្នុងអរូបព្រហ្ម ឯលោកុត្តរធម៌ ៨ មិនមាននាំសត្វឲ្យបដិសន្ធិក្នុងស្ថានណានីមួយឡើយ ព្រោះហេតុនោះបានជាថា ឆ្លងចាកលោកមិនកើតទៀត ថ្វីបើព្រះសោតាបន្ន សកទាគាមិ អនាគាមិ ដែលលោកនៅកើតទៀតនោះ គឺលោកកើតដោយលោកិយធម៌ទេតើ ឯលោកុត្តរធម៌គ្រាន់តែជាកំរៃជួយរាំងមិនឲ្យទៅកាន់ទីទាបប៉ុណ្ណោះទេ ។

បុ. និព្វានប្រែដូចម្តេច ?

វិ. ប្រែថា ធម្មជាតិចេញផុតអំពីកិលេសជាគ្រឿងរិតរុំសត្វ ឬថាធម្មជាតិជាទីរំលត់ភ្លើងកិលេស និង ភ្លើងទុក្ខ ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ភ្លើងកិលេសនោះបានដល់ រាគៈ ទោសៈ មោហៈ ព្រោះកើតឡើងមួយអន្លើដោយចិត្ត ធ្វើចិត្តឲ្យល្អក់កករឲ្យក្តៅក្រហាយអន្ទះអន្ទែង ។ ភ្លើងទុក្ខបានដល់ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ព្រោះជាហេតុនៃសេចក្តីទុក្ខ និង តួទុក្ខតែងបំពក់សត្វឲ្យក្តៅក្រហាយដូចជាគំនរភ្លើង ។

មានតែព្រះនិព្វានម្យ៉ាង ដែលជាគ្រឿងរំលត់ភ្លើងទាំងនេះបាន ព្រោះភ្លើងទាំងនេះមិនមាននៅក្នុងព្រះនិព្វាន ។ ជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង មិនមានឧបធិក្កិលេស ជាទីក្ស័យតណ្ហា ។ ព្រះនិព្វានមិនមែនជាដី មិនមែនជាភ្លើង មិនមែនជាខ្យល់ មិនមែនជាអាកាសនញ្ចាយតនៈ មិនមែនជាវិញ្ញាណញ្ចាយតនៈ មិនមែនអកិញ្ចញ្ញាយតនៈ មិនមែននេវសញ្ញានាសញ្ញាយតនៈ មិនមែនជាលោកនេះ មិនមែនលោកខាងមុខ មិនមែនព្រះអាទិត្យព្រះចន្ទ ។ ព្រះនិព្វានមិនមានដំណើរមកអំពីភូមិនោះដល់ភូមិនេះ មិនមានដំណើរទៅអំពីភូមិនេះដល់ភូមិដទៃ មិនមានកិរិយាឈប់នៅ មិនមានចុតិ មិនមានបដិសន្ធិ មិនមានទីប្រតិស្ឋានតាំងនៅក្នុងតំបន់ណាឡើយ ។

បុ. សភាវៈ ទាំងពួងដែលបានពោលមកហើយទាំងប៉ុន្មាន ថាសុទ្ធតែមិនមែនព្រះនិព្វានទាំងអស់ បើដូច្នេះមានតែព្រះនិព្វានសូន្យទេដឹង ?

វិ. មិនមែនដូច្នោះទេ ព្រះនិព្វានមានពិត តែជាធម្មជាតិល្អិតសុខុមណាស់ ព្រះអរិយៈទាំងឡាយតែងឃើញរបស់ដោយបញ្ញាចក្ខុ គឺ អរិយមគ្គញ្ញាណ ព្រោះហេតុនោះបានជាព្រះនិព្វានជាអសាធារណៈ មិនទូទៅគឺ មិនប្រាកដដល់បុថុជ្ជនផង ។

បុ. បើព្រះនិព្វានមានមែន តើស្ថិតនៅក្នុងទីណា ? ជិតឬឆ្ងាយ ?

វិ. ព្រះនិព្វានជាអរូបធម៌ មិនមែនមានទីកន្លែងសម្រាប់ស្ថិតនៅដូចជារបស់ទាំងពួងដែលមានរូបទេ ព្រះនិព្វានថាស្ថិតនៅជិតក៏ថាបាន ថាឆ្ងាយក៏ថាបាន ដែលថាជិតគឺ សំដៅត្រង់អស់ រាគៈ ទោសៈ មោហៈ ត្រង់ណា ព្រះនិព្វាននៅត្រង់នោះ ដែលថាឆ្ងាយគឺ ព្រះនិព្វានប្រតិស្ឋាននៅត្រង់ទីបំផុតលោកទាំង ៣ គឺ កាមលោក រូបលោក អរូបលោក ។

បុ. ព្រះនិព្វានជាធម្មជាតិ ឥតរូបទេ ចុះដែលស្ថិតនៅនោះ តើមានអ្វីទ្រទ្រង់ ?

វិ. មានធម្មាយតនៈ ជាគ្រឿងទ្រទ្រង់ ព្រោះព្រះនិព្វាននិងធម្មាយតនៈ ជាអរូបធម៌ដូចគ្នា បានជាអាចទ្រទ្រង់បាន ប្រៀបឧបមាដូចជាផ្សែងដែលជារបស់មានរូបល្អិតចាប់ផ្ដុំមិនបាន តែគង់អាចស្ថិតនៅឰដ៏អាកាស ដែលជារបស់មានរូបល្អិតចាប់ផ្ដុំមិនបានដូចគ្នាបានយ៉ាងណា ព្រះនិព្វានក៏ស្ថិតនៅយ៉ាងនោះដែរ ។

ព្រះនិព្វាននេះប្រាកដជាមានមែន ដូចជាប្រទេសដែលមានផ្លូវដើរ នៅទីបំផុតរបស់ផ្លូវនោះ តែងមានស្រុកភូមិយ៉ាងណា ព្រះនិព្វានក៏មានអដ្ឋង្គិកមគ្គជាផ្លូវ ឯទីបំផុតផ្លូវគឺព្រះនិព្វានយ៉ាងនោះដែរ ។

បុ. ចុះព្រះនិព្វាននៅមានសល់ធម្មជាតិអ្វីដែរឬ ?

វិ. មាននៅសល់ផលញ្ញាណតែម្យ៉ាង ។

បុ. ផលញ្ញាណនោះតើបានមកពីណា ?

វិ. បានមកពីការពិចារណានូវខន្ធ ៥ ដោយវិបស្សនាញាណទាំង ១០ ឧបមាដូចជាតិដូងទុំ បើទុកយូរទៅវាស្អុយ បើយកទៅដាំវាដុះទៀត បើគេមិនចង់ឲ្យស្អុយ មិនចង់ឲ្យដុះឡើងទៀត គេយកទៅចម្រាញ់ធ្វើជាប្រេង ដាំក៏មិនដុះ ទុកក៏មិនស្អុយ យ៉ាងណា ព្រះនិព្វានដែលចម្រាញ់មកពីវិបស្សនា-

ញាណ ក៏មិនមែនសូន្យទទេហើយមិនមានពូជតទៅទៀតយ៉ាងនោះដែរ ។

បុ. ពួកបុថុជ្ជនហេតុអ្វីបានជាមើលព្រះនិព្វានមិនឃើញ ?

វិ. បានជាមើលមិនឃើញ ព្រោះរាគៈ ទោសៈ មោហៈ បិទបាំងដូចជាបុគ្គលមានធូលីនៅក្នុងភ្នែក រមែងមើលវត្ថុ សខៅជាដើមមិនឃើញ ។

បុ. ព្រះនិព្វានសុខតែម្យ៉ាង ឬក៏ច្រឡំដោយទុក្ខដែរ ?

វិ. ជាសុខតែម្យ៉ាង ហៅថា ឯកន្តបរមសុខ មិនមែនលាយឡំដោយទុក្ខផងឡើយ ។

បុ. បើព្រះនិព្វានមានពិតហើយជា ឯកន្តបរមសុខមែន រូបសណ្ឋានឬប្រមាណនៃព្រះនិព្វាននោះ គេអាចសម្តែងឧបមាដោយហេតុ ដោយបច្ច័យ ឬក៏ដោយន័យឯណាមួយបានដែរឬ ?

វិ. មិនអាចឧបមាដោយហេតុបច្ច័យ ឬក៏ដោយន័យឯណាមួយបានទេ ពិតជាមានមែន ប៉ុន្តែល្អិតសុខុមហួសវិស័យនឹងឧបមាកើត ដូចជាមហាសមុទ្រក្នុងលោកនេះមានមែន ប៉ុន្តែគេមិនអាចរាប់ទឹក និង សត្វក្នុងមហាសមុទ្រនោះបាន ព្រោះហួសវិស័យនឹងរាប់ បើពុំនោះទេ ដូចអរូបកាយិកទេវតា ពិត

ជាមានមែន ប៉ុន្តែគេមិនអាចនឹងសម្តែងប្រៀបធៀបថា មានរូបភាពយ៉ាងនេះយ៉ាងនោះបាន ។

បុ. ព្រះនិព្វានគ្មានអ្នកណាអាចសម្តែងរូបជាដើម ដោយសេចក្តីឧបមាបានពិតមែនហើយ ចុះគុណនៃព្រះនិព្វាន បើសម្តែងធៀបដោយសភាវៈដទៃបានដែរឬ ?

វិ. បើគ្រាន់តែសម្តែងធៀបបាន តែឲ្យចោះចំពោះចំ ៗ តាមធម្មតារបស់ខ្លួនមិនបានទេ មានសេចក្តីប្រៀបច្រើនអំពីព្រះនិព្វានមានដើមថា ដំណក់ទឹកដក់នៅលើស្លឹកឈូកមិនបានយ៉ាងណា កិលេសទាំងឡាយក៏តាំងនៅក្នុងព្រះនិព្វានមិនបានយ៉ាងនោះដែរ ទឹកជារបស់ត្រជាក់សម្រាប់រម្ងាប់បង់នូវសេចក្តីក្រវល់ក្រវាយយ៉ាងណា ព្រះនិព្វានក៏ជាធម្មជាតិរម្ងាប់បង់នូវសេចក្តីក្រវល់ក្រវាយគឺកិលេសយ៉ាងនោះដែរ ទឹកជារបស់បំបាត់បង់នូវសេចក្តីលំបាកព្រោះស្រេកទឹក នៃមនុស្ស និង សត្វទាំងឡាយដែលដើរទៅក្នុងទីមានកំដៅយ៉ាងណា ព្រះនិព្វានក៏បំបាត់បង់នូវសេចក្តីលំបាកពោលគឺកាមតណ្ហា ភវតណ្ហា និង វិភវតណ្ហាយ៉ាងនោះដែរ ។

បុ. ចុះព្រះនិព្វានមានលក្ខណៈ ដូចម្តេច ?

Websites: WatKhemaraRatanaram.org or WatKhmers.org


វិ. តយិទំ សន្តិលក្ខណំ ព្រះនិព្វានមានលក្ខណៈរម្ងាប់បង់នូវ លោភៈ ទោសៈ មោហៈ រម្ងាប់បង់នូវអវិជ្ជា និង តណ្ហា រម្ងាប់បង់នូវសង្កិលេសធម៌ទាំងពួង ដែលធ្វើឲ្យសៅហ្មងវិលស្លាប់វិលកើតក្នុងវដ្តសង្សារ ។

បុ. ព្រះនិព្វានមានកិច្ចដូចម្ដេច ?

វិ. អចុតិរសំ មានកិច្ចមិនចុតិ មិនលុះក្នុងអំណាចនៃសង្ខតធម៌ទាំងឡាយគឺ នាម និង រូប ដែលជាកុសល និង អកុសលដែលប្រជុំគាក់តែងឲ្យកើតឲ្យបែកធ្លាយ ព្រះនិព្វាននេះជាធម៌ទៀង មិនចេះកើតមិនចេះបែកធ្លាយព្រោះផុតពីកណ្ដាប់ដៃនៃសង្ខតធម៌ ហេតុនេះកិរិយាដែលមិនចេះចុតិនេះជាកិច្ចរបស់ព្រះនិព្វាន ។ អស្សាសករសំវា ម្យ៉ាងទៀតថា ព្រះនិព្វានមានកិច្ចធ្វើឲ្យសន្តាននៃព្រះអរិយបុគ្គលរីករាយសោមនស្ស អធិប្បាយតាមពាក្យព្រះដីកាចារ្យថា ព្រះនិព្វាននេះមានអាការហាក់ដូចជានឹងប្រលោមយកចិត្តរបស់ព្រះអរិយៈ ដែលមានសន្តាននឿយណាយចាកសង្សារទុក្ខ ឲ្យប្រកបដោយសេចក្ដីក្សេមក្សាន្ត ឲ្យប្រាសចាកទុក្ខ ចាកក្ដៅក្រហាយ ឲ្យមានសេចក្ដីត្រជាក់នៅក្នុងសន្តានចិត្ត ។

បុ. ព្រះនិព្វានមានអ្វីជាផល ?

វិ. អនិមិត្តប្បច្ចុប្បដ្ឋានំ ព្រះនិព្វានមានសភាវៈ ប្រាសចាក សង្ខតនិមិត្តជាផល ។ម្យ៉ាងទៀតថា និប្បបញ្ចប្បច្ចុប្បដ្ឋានំ ព្រះនិព្វានមានសភាវៈ ជាហេតុឲ្យរម្ងាប់នូវបបញ្ចធម៌ មានកាមរាគៈជាដើមជាផល, អធិប្បាយថា សង្ខតនិមិត្ត គឺកុសល និង អកុសល ដែលជាហេតុជាបច្ច័យ ប្រជុំតាក់តែងនាម និង រូបឲ្យវិលឧបត្តិកើតក្នុងភពទាំង ៣ គឺ កាមភព រូបភព អរូបភព នោះមិនមានក្នុងព្រះនិព្វាន, បបញ្ចធម៌ទាំងពួងមាន រាគបបញ្ចធម៌ជាដើម ដែលធ្វើឲ្យសត្វទាំងឡាយ ឃើតយូររារង់នៅក្នុងវដ្តសង្សារ ក៏មិនមានក្នុងព្រះនិព្វាន ។ នេះជាបច្ច័យឲ្យរលត់បាននូវរាគាទិបបញ្ចធម៌ ហេតុដូច្នោះទើបថាព្រះនិព្វានធម៌នោះ មានសភាវៈប្រាសចាក សង្ខតនិមិត្តជាផល ឬមានសភាវៈ ជាហេតុឲ្យស្ងប់រម្ងាប់នូវបបញ្ចធម៌ មានរាគៈ ជាដើមជាផល ។

បុ. គុណរបស់ព្រះនិព្វានមានប៉ុន្មានយ៉ាង អ្វីខ្លះ ?

វិ. មាន ៣២ គឺ អជាតិ ព្រះនិព្វានមិនមានកំណើត, អជរំ ព្រះនិព្វានមិនមានសេចក្តីគ្រាំគ្រា អព្យាធិ ព្រះនិព្វានមិនមាន ព្យាធិ ( ជម្ងឺដំកាត់ ) និព្ភយំ ព្រះនិព្វានមិនមានភ័យ អសង្ខតំ ព្រះនិព្វាន

គឺបច្ច័យតាក់តែងមិនបាន ភវភិន្នំ ព្រះនិព្វានទំលាយនូវភព ៣ សុខំ សីតំ ព្រះនិព្វានជាសុខដ៏ត្រជាក់ ខេមំ ព្រះនិព្វានដ៏ក្សេម តាណំ ព្រះនិព្វានជាទីពឹងដល់ព្រះអរិយៈ លេនំ ព្រះនិព្វានជាទីពួនអំពីមច្ចុរាជ និច្ចំ ព្រះនិព្វានទៀង គឺមិនបានប្រែប្រួល អចលំ ព្រះនិព្វានមិនបានកម្រើក ធុវសស្សតំ ព្រះនិព្វានទៀងប្រាកដ អវដ្តសារំ ព្រះនិព្វានខ្លឹមសារ មិនមានវិលវល់ត្រឡប់ សុខមទ្ទនំ ព្រះនិព្វានញ៉ាំញីនូវសុខក្នុងមនុស្ស និងសុខក្នុងស្ថានសួគ៌ ខុទ្ទមទ្ទនំ ព្រះនិព្វានញ៉ាំញីនូវសេចក្ដីឃ្លានបាយ បិបាសព្វិនយំ ព្រះនិព្វានបន្ទោរបង់នូវសេចក្ដីស្រេកទឹក អនាលយំ ព្រះនិព្វានមិនមានអាល័យ សមុគ្ឃាដវដ្តំ-ទដ្ដេសំ ព្រះនិព្វានដកនូវទោសដែលជោកនៅក្នុងចិត្តដូចជាពិសពស់ វិសង្ខារំ ព្រះនិព្វានប្រាសចាកសង្ខារ គឺនាម និង រូប វិវដ្តំ ព្រះនិព្វានប្រាសចាកទោសទាំងឡាយ តណ្ហក្ខយំ ព្រះនិព្វានជាទីក្ស័យនៃតណ្ហា វិភវំ ព្រះនិព្វានប្រាសចាកភពទាំង ៣ វិរាគំ ព្រះនិព្វានប្រាសចាករាគៈ វីតមោហំ ព្រះនិព្វានប្រាសចាកមោហៈ និរោធំ ព្រះនិព្វានរំលត់ទុក្ខទាំងពួង អនិមិត្តំ ព្រះនិព្វានមិនមាននិមិត្ត សន្តភាវំ ព្រះនិព្វានមានសភាពរម្ងាប់

កិលេស អរសាករំ ព្រះនិព្វានមិនមានរស គឺតណ្ហា អប្បសាលញ្ច ព្រះនិព្វានលះចេញនូវសេចក្តីរីករាយនៃចិត្ត អមតំ ព្រះនិព្វានមិនចេះស្លាប់ រួមទាំងអស់ត្រូវជាគុណនៃព្រះនិព្វាន ៣២ ប្រការ ។

ឯវំ លោកុត្តរធម្មោបិ ស្វាក្ខាតោ លោកុត្តរធម៌ដែលព្រះដ៏មានព្រះភាគ សម្តែងហើយដោយប្រពៃ ដូចសេចក្តីដែលសម្តែងមកនេះ ។

កែបទ " សន្ទិដ្ឋិកោ "

បុ. " សន្ទិដ្ឋិកោ " ប្រែដូចម្តេច ? អធិប្បាយយ៉ាងណា ?

វិ. ប្រែថា ធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង ( បានដល់អរិយមគ្គ និង លោកកុត្តរធម៌ ) ។

អធិប្បាយថា ព្រះអរិយបុគ្គលជាម្ចាស់លោកធ្វើកិលេសទាំងឡាយមានរាគៈជាដើម ឲ្យអស់ពីសន្តានលោកហើយ ក៏ឃើញនូវអរិយមគ្គជាក់ច្បាស់ ដោយព្រះអង្គលោក គឺឃើញថា " បុគ្គលមានចិត្តទទឹកដោយរាគៈ មានចិត្តត្រូវរាគៈ គ្របសង្កត់ មានចិត្តជាកំណាន់របស់រាគៈ ជួនណាគិតដើម្បីបៀតបៀនខ្លួនឯង ជួនណាគិតដើម្បីបៀតបៀននូវអ្នកដទៃ ជួនណាគិតដើម្បីបៀតបៀនខ្លួនឯងផង ដើម្បីបៀតបៀនអ្នកដទៃផង

Websites: WatKhemaraRatanaram.org or WatKhmers.org


រមែងសោយទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ” បើលះបង់ភាគៈបានហើយ រមែងមិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ នឹងមិនគិតដើម្បីបៀតបៀនខ្លួនឯងផងអ្នកដទៃផង រមែងមិនសោយទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត យ៉ាងនេះឯងដែលឈ្មោះថា ធម៌គឺ ព្រះអរិយបុគ្គលឃើញច្បាស់ដោយព្រះអង្គលោក ។

ឯលោកុត្តរធម៌ទាំង ៩ ប្រការគឺ មគ្គ ៤ ផល ៤ និព្វាន ១ បើបុគ្គលណាបានត្រាស់ដឹងហើយ បុគ្គលនោះរមែងលះបង់នូវកិរិយាជឿអ្នកដទៃ ព្រោះលោកឃើញច្បាស់ដោយខ្លួនឯងដោយបច្ចវេក្ខណញ្ញាណ ។

ន័យមួយទៀត អរិយមគ្គដែលឈ្នះនូវកិលេសទាំងឡាយបានដោយសេចក្ដីយល់ត្រូវដែលព្រះជាគ្រូទ្រង់សរសើរ ហៅថា សន្ទិដ្ឋិកោ ។ ពិតដូច្នោះមែន ព្រះអរិយមគ្គរមែងឈ្នះនូវកិលេសទាំងឡាយ ដោយសេចក្ដីយល់ត្រូវដែលសម្បយុត្តដោយអរិយ-មគ្គដែលកើតជាហេតុនៃអរិយផល ដែលកើតជាអារម្មណ៍នៃព្រះនិព្វាន ។

នយ័មួយទៀត លោកុត្តរធម៌គួរដល់កិរិយាឃើញ ហៅថា សន្ទិដ្ឋិកោ ព្រោះលោកុត្តរធម៌ បុគ្គលតែងឃើញបានដោយភាវនាភិសម័យ និង សច្ឆិកិរិយាភិសម័យ ទើបបានឈ្មោះថា សន្ទិដ្ឋិកោ ។

## កែបទ " អកាលិកោ "

បុ. បទថា " អកាលិកោ " ប្រែដូចម្ដេច អធិប្បាយដូចម្ដេច ?

វិ. ប្រែថា " ធម៌មិនមានកាលវេលា " អធិប្បាយថា ព្រះធម៌ គឺ អរិយមគ្គ តែកើតឡើងហើយក្នុងសន្ដាននៃបុគ្គលណា រមែងឲ្យផលក្នុងលំដាប់បន្ទាប់អំពីខ្លួនប្រព្រឹត្តនោះឯង មិនមានកាលវេលា គឺថាមិនឈប់បង្អង់រារង់នៅអស់ ៥ ថ្ងៃ ៧ ថ្ងៃ ឬក៏ត្រឹមតែមួយថ្ងៃ កន្លះថ្ងៃទើបឲ្យផលឡើយ ព្រោះជវនវារៈរបស់ចិត្តដែលសម្បយុត្តដោយមគ្គរលត់ហើយ ជវនៈនៃចិត្តដែលសម្បយុត្តដោយផលក៏កើតឡើង ក្នុងលំដាប់នោះ ឥតមានជវនវារៈ នៃចិត្តដទៃកើតស្កាត់ក្នុងចន្លោះបានឡើយ ព្រោះហេតុនោះបានជាអរិយមគ្គ ឈ្មោះថា " អកាលិកោ " ជាធម៌មិនមានកាលវេលា ឬថាជាធម៌ឲ្យនូវផលមិនរង់ចាំកាលវេលា ។

កែបទ " ឯហិបស្សិកោ "

បុ. បទថា " ឯហិបស្សិកោ " ប្រែដូចម្តេច ? អធិប្បាយដូចម្តេច ?

វិ. ប្រែថា " ធម៌គួរដល់ឯហិបស្សវិធី " អធិប្បាយថា ព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ គួរនឹងហៅអ្នកដទៃមកចង្អុលប្រាប់បានថា អ្នកចូលមកមើលធម៌នេះដូច្នេះ ព្រោះលោកុត្តរធម៌ជាសភាវៈមានពិតផង ជាធម្មជាតិបរិសុទ្ធិផង បានជាគួរនឹងហៅអ្នកដទៃឲ្យចូលមកមើល ។ បុគ្គលក្តាប់ដៃទទេ មិនអាចនឹងហៅអ្នកដទៃមកប្រាប់ថា ប្រាប់មាសរបស់យើងមាន ចូរអ្នកមើលចុះដូច្នេះឡើយ ព្រោះក្នុងដៃនោះមិនមានរបស់អ្វី ឬបើក្នុងដៃនោះ មានរបស់ដែរ តែជាមូត្រឬលាមក ក៏មិនអាចនឹងហៅអ្នកដទៃមកប្រាប់ថា អ្នកចូរមើលដូច្នេះ ដើម្បីញ៉ាំងចិត្តគេឲ្យជ្រះថ្លាដោយកិរិយាប្រកាសនូវមនុញ្ញភាពឡើយ ព្រោះមូត្រលាមកនោះជារបស់មិនស្អាតត្រូវតែបិទបាំងដោយស្មៅ និង ស្លឹកឈើជាដើម ។ ឯលោកុត្តរធម៌នេះ ជាធម្មជាតិមានពិត ដោយសភាវៈ នឹងជាធម្មជាតិស្អាតបរិសុទ្ធិដូចមណ្ឌលនៃព្រះចន្ទ្រ ដ៏ពេញវង់ក្នុងអាកាសដែលប្រាសចាកមេឃវលាហកៈ ប្រការមួយសោតស្អាតបរិសុទ្ធិ

Websites: WatKhemaraRatanaram.org or WatKhmers.org


ដូចជាជាតិនៃកែវមណី ដែលគេតម្កល់ទុកក្នុងសំពត់កម្ពល ព្រោះហេតុនោះបានជាលោកុត្តរធម៌ឈ្មោះថា " ឯហិបស្សិកោ " គួរនឹងហៅអ្នកដទៃឲ្យចូលមកមើលផងបាន ។

កែបទ " ឱបនយិកោ "

បុ. បទថា " ឱបនយិកោ " ប្រែដូចម្ដេច ? អធិប្បាយដូចម្ដេច ?

វិ. ប្រែថា ធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា ។ អធិប្បាយថា លោកុត្តរធម៌នោះ ព្រះអរិយបុគ្គលតែងបង្អោនមកទុកក្នុងខ្លួន ដោយអំណាចភាវនា បើទុកជាភ្លើងឆេះផ្ទាំងសំពត់ក្ដី ឆេះក្បាលក្ដី ក៏មិនអើពើ ។ ពាក្យនេះសំដៅយកលោកុត្តរធម៌ដែលជាសង្ខតៈនៅឡើយ ឯលោកុត្តរធម៌ជាអសង្ខតៈ ព្រះអរិយបុគ្គលបង្អោនមកទុកក្នុងខ្លួនដោយចិត្ត គឺពាល់ត្រូវដោយអំណាចកិរិយាធ្វើឲ្យជាក់ច្បាស់ ។ម្យ៉ាងទៀត ព្រះអរិយមគ្គដែលបង្អោនទៅរកព្រះនិព្វាន ក៏ឈ្មោះថា " ឱបនយិកោ " ផលនិងព្រះនិព្វានក៏ឈ្មោះថា " ឱបនយិកោ " ។

## កែបទ " បច្ចត្តំ វេទិតព្វោ វិញ្ញូហិ "

បុ. បទថា " បច្ចត្តំ វេទិតព្វោ វិញ្ញូហិ " ប្រែដូចម្តេច ? អធិប្បាយដូចម្តេច ?

វិ. ប្រែថា ធម៌គឺវិញ្ញូជនទាំងឡាយ មានឧគ្ឃដិតញ្ញូជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។ អធិប្បាយថា លោកុត្តរធម៌គឺ ព្រះអរិយបុគ្គលជាឧគ្ឃដិតញ្ញូ និង វិបច្ចិតញ្ញូ និង នេយ្យ ទាំង ៣ ជំពូកនេះគប្បីឃើញច្បាស់ក្នុងខ្លួនថា ( មគ្គ ) អញបានចម្រើនហើយ ( ផល ) អញបានត្រាស់ដឹងហើយ ព្រះនិព្វានជាទីរំលត់ទុក្ខ អញបានធ្វើឲ្យជាក់ច្បាស់ហើយ ។ មគ្គដែលឧបជ្ឈាយ៍ចម្រើនបានហើយ នឹងលះបង់នូវកិលេសនៃសទ្ធិវិហារិក ដែលជាកូនសិស្សរបស់ខ្លួនផងក៏មិនបាន សទ្ធិវិហារិកសោត ក៏មិនបាននូវសុខសម្រាន្តដោយសារផល សមាបត្តិរបស់ឧបជ្ឈាយ៍នោះ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលឧបជ្ឈាយ៍នោះធ្វើឲ្យជាក់ច្បាស់ហើយក៏មិនបាន ព្រោះហេតុនោះ លោកុត្តរធម៌មិនគឺ អ្នកដទៃឃើញបានផងឡើយ ដូចគ្រឿងប្រដាប់

សិរសារបស់អ្នកដទៃ ជាធម៌គឺ វិញ្ញូជនដែលបានគប្បីឃើញ គប្បីសោយក្នុងចិត្តរបស់ខ្លួនតែម្យ៉ាង មិនមែនជាវិស័យនៃពាលបុថុជ្ជន ព្រោះហេតុនោះបានជាថា " បច្ចត្តំ វេទិតព្វោ វិញ្ញូហិ " ជាធម៌គឺ អ្នកប្រាជ្ញវិសេសទាំងឡាយគប្បីដឹងចំពោះខ្លួន ។

ឯគុណនៃព្រះធម៌មាន " សន្ទិដ្ឋិកោ " ជាដើម ដូចបានពណ៌នាមកនេះសុទ្ធតែជាគុណនៃលោកុត្តរធម៌ជារបស់ខ្ពស់ ជាវិស័យនៃព្រះអរិយតែម្យ៉ាង មិនមែនជាវិស័យនៃបុថុជ្ជនឡើយ ។

ពណ៌នាមកអំពីធម្មរតនៈ ចប់ដោយសង្ខេប ។

Websites: WatKhemaraRatanaram.org or WatKhmers.org


# ពណ៌នាអំពីសង្ឃរតនៈ

បន្ទាប់អំពីធម្មរតនៈមក នឹងពណ៌នានូវសង្ឃរតនៈតទៅទៀត

បុ. ពាក្យថា " សង្ឃ " ប្រែដូចម្ដេច ? មានប៉ុន្មាន ? មានគុណដូចម្ដេច ?

វិ. ប្រែថា " ពួក " ចែកចេញទៅ មាន ២ គឺ

១- សម្មតិសង្ឃ[1] ពួកភិក្ខុដែលសន្មតិពី ៤ រូបឡើងទៅដើម្បីធ្វើនូវកម្មណាមួយ ។

២- អរិយសង្ឃ ពួកលោកដែលជាព្រះអរិយៈបានតាំងនៅក្នុងមគ្គ និង ផល ។

សង្ឃ បើប្រែថា " ជិតគ្នា " ក៏បាន ព្រោះថាព្រះអរិយសង្ឃទាំងអម្បាលនោះ ទោះបីទៅឆ្ងាយពីគ្នា មួយអង្គប្រទេស ១ មួយអង្គប្រទេស ១ ផ្សេង ៗ ពីគ្នា ឬខុសគ្នាដោយជាតិ ក៏ឈ្មោះថា " ជិតគ្នា " គឺជិតដោយហេតុចុះរបៀបបែបផែនដូចគ្នាត្រូវគ្នាដោយគុណគឺ សីល និង ទិដ្ឋិ សេចក្ដីយល់ឃើញបែប ៗ គ្នា ។

---

១- គុណព្រះសង្ឃនេះមានពិស្ដារក្នុងវិនយបិដក ។

ន័យមួយទៀត សង្ឃ ប្រែថា " អ្នកជីកកិលេស " ព្រោះលោកទាំងនោះជាអ្នកព្យាយាម ជីករំលើងគាស់កកាយកិលេសទាំងឡាយមានរាគជាដើមឲ្យផុតចេញពីខន្ធសន្តាន ។

ម្យ៉ាងទៀត ព្រះសង្ឃជាសាវកចែកចេញជា ២ គឺ បុថុជ្ជនសាវក ១ អរិយសាវក ១ ។ ពួកលោកដែលបានស្តាប់ឱវាទផ្ទាល់អំពីព្រះឱស្ឋចំពោះព្រះភក្ត្រព្រះជាគ្រូ ឬក៏ស្តាប់អំពីសំ-ណាក់សាវកដទៃនៃព្រះអង្គក្តី មិនបានត្រាស់ដឹងមគ្គផលទេបានត្រឹមតែ សទ្ធាជឿគុណព្រះរតនត្រ័យស្ថិតនៅក្នុងសរណគមន៍ប៉ុណ្ណោះ បុគ្គលពួកនេះឈ្មោះថា " បុថុជ្ជនសាវក " ។ ពួកលោកដែលស្តាប់ធម្មានុសាសនៈ ដែលព្រះជាគ្រូទ្រង់ប្រោសប្រទានសម្តែង ដោយព្រះអង្គឯងក្តី ឬសាវកព្រះអង្គសម្តែងក្តីហើយបានលុះលោកុត្តរាភិសម័យ ( មគ្គផល ) ក្នុងខណៈកំពុងតែស្តាប់នោះក្តី ឬប្រតិបត្តិតាមពាក្យប្រដៅនោះហើយបានលុះមគ្គផលក្នុងពេលមកខាងក្រោយក្តី បុគ្គលពួកនេះឈ្មោះថា " អរិយសាវក " ។

ក៏ព្រះសង្ឃជាសាវកទាំងនោះ លោកមានគុណច្រើនមានសុបដិបន្នោជាដើម ដូចសេចក្តីដែលមានសម្តែងក្នុងខាងមុខនេះ ។

បទនេះប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ។

បុ. លោកប្រតិបត្តិដូចម្តេចទើបឈ្មោះថា " ប្រតិបត្តិដោយប្រពៃ " ។

វិ. លោកប្រតិបត្តិតាមសម្មាបដិបទា អនិវត្តិប្បដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា និងធម្មានុធម្មប្បដិបទា ។

បុ. សេចក្តីប្រតិបត្តិដូចម្តេចដែលហៅថា " សម្មាបដិបទា " ?

វិ. សេចក្តីប្រតិបត្តិត្រូវ ល្អតាមគន្លងដំណើរព្រះនពលោកុត្តរធម៌ និងអដ្ឋង្គិកមគ្គដែលសង្គ្រោះដោយខន្ធ ៣ គឺ សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ ហៅថា " សម្មាបដិបទា " ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា " អនិវត្តប្បដិបទា " ?

វិ. សេចក្តីប្រតិបត្តិមិនវិលត្រឡប់ គឺបុគ្គលអ្នកប្រតិបត្តិដល់ជាទីអរិយៈហើយ មិនវិលត្រឡប់មកជាបុថុជ្ជនវិញ ហៅថា " អនិវត្តិប្បដិបទា " ។

បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា " អនុលោមប្បដិបទា " ?

វិ. សេចក្តីប្រតិបត្តិជាអនុលោមដល់ព្រះនិព្វាន ហៅថា " អនុលោមប្បដិបទា " ។

Websites: WatKhemaraRatanaram.org or WatKhmers.org


បុ. សេចក្តីប្រតិបត្តិដូចម្តេច ហៅថា " អបច្ចនីកប្បដិបទា " ?

វិ. សេចក្តីប្រតិបត្តិមិនជាសត្រូវ គឺ មិនទំនាស់ដល់ព្រះនិព្វាន ហៅថា " អបច្ចនីកប្បដិបទា " ។

បុ. សេចក្តីដូចម្តេច ហៅថា " ធម្មានុធម្មប្បដិបទា " ?

សេចក្តីប្រតិបត្តិតាមធម៌ដ៏សមគួរដល់ធម៌ គឺប្រតិបត្តិសមគួរដល់ព្រះនិព្វាន ហៅថា " ធម្មានុធម្មប្បដិបទា " ។ ព្រះសង្ឃជាសាវកលោកធ្វើដំណើរតាមសម្មាបដិបទា ដូចសម្តែងមកនេះ ទើបឈ្មោះថា " សុបដិបន្នោ " ប្រតិបត្តិដោយប្រពៃ ។ បណ្ឌិតគប្បីជ្រាបថា លោកដែលតាំងនៅក្នុងមគ្គ ឈ្មោះថា " សុបដិបន្នោ " ប្រតិបត្តិដោយប្រពៃ ព្រោះលោកដល់ព្រមដោយសម្មាបដិបទា គឺ មគ្គ លោកដែលតាំងនៅក្នុងផលក៏ឈ្មោះថា " សុបដិបន្នោ " ប្រតិបត្តិដោយប្រពៃដែរ ដោយអាស្រ័យផ្លូវប្រតិបត្តិជាអតីត ព្រោះធម៌ដែលលោកគប្បីដល់ដោយសម្មា-បដិបទានោះលោកបានដល់ហើយ ។ ម្យ៉ាងទៀត ព្រះសង្ឃជាសាវកអ្នកប្រតិបត្តិតាមឱវាទដែលព្រះពុទ្ធជាម្ចាស់ ប្រៀនប្រដៅ គឺធម៌វិន័យហើយនិងប្រតិបត្តិតាមអបណ្ណកប្បដិបទា គឺដំណើរសេចក្តីប្រតិបត្តិមិនខុស ឈ្មោះថា " សុបដិបន្នោ " ។ ម្យ៉ាង

ទៀត ដែលឈ្មោះថា " សុបដិបន្នោ " ប្រតិបត្តិល្អនោះ គឺលោកតាំងទុកនូវសីល ដូចជារបង ឬកំផែងសម្រាប់ការពារសឹកសត្រូវ គឺទុច្ចរិតសំកិលេស ដែលជាអកុសលដ៏អាក្រក់តែងកើតក្នុងកាយទ្វារវចីទ្វារ លោកធ្វើសមាធិបីដូចជាផែនសីលាដ៏ធំបិទបាំងនូវសត្រូវខាងក្នុង គឺបរិយុដ្ឋានសំកិលេស ដែលជាអកុសលកើតឡើងគ្របសង្កត់ចិត្ត លោកធ្វើបញ្ញាដូចជាប្រទីបបំភ្លឺក្នុងកងសង្ខារទាំងពួងដោយចំណែក ៗ មានខន្ធជាដើម ឃើញច្បាស់ថាជាទុក្ខមិនមែនខ្លួន ហើយលោកធ្វើបញ្ញាដូចជាសស្ត្រាវុធមានមុខដ៏មុតថ្លា ពិឃាតសម្លាប់អនុសយកិលេសដែលជាចំណែកដ៏ល្អិត យ៉ាងទាបបំផុតបានត្រឹមសោតាបន្នបុគ្គល អស់វិចិកិច្ឆាដោយឃើញគុណព្រះពុទ្ធជាក់ច្បាស់ ហើយលោកុត្តរធម៌ក៏កើតឡើងប្រាកដក្នុងសន្តាន លុះលោកបានសម្រេចជាព្រះអរិយៈ ហើយ ទើបអស់សីលពត្តបរាមាសៈ ព្រោះឃើញច្បាស់ថាខ្លួនបរិសុទ្ធិដោយត្រៃសិក្ខា ដែលជាសម្មាបដិបទា ផ្លូវប្រតិបត្តិប្រពៃ យ៉ាងនេះទើបឈ្មោះថា " សុបដិបន្នោ " ។

កែបទ " ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ "

បទនេះប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដោយត្រង់ ។

បុ. លោកប្រតិបត្តិដូចម្ដេច ទើបឈ្មោះថាប្រតិបត្តិត្រង់ ?

វិ. លោកប្រតិបត្តិត្រង់ មិនវៀច មិនកោង មិនល្អៀង មិនឃ្វាង គឺជាដំណើរឆ្ពោះត្រង់ទៅរកព្រះនិព្វាន មិនពានពារទៅលើផ្លូវលាមក ២ ប្រការគឺ កាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ដែលជាផ្លូវប្រតិបត្តិខុស ជាដំណើរឃ្វាងមិនចំព្រះនិព្វាន លោកតែងធ្វើដំណើរតាមមជ្ឈិមប្បដិបទា ដែលជាផ្លូវប្រតិបត្តិយ៉ាងកណ្ដាល ។ ម្យ៉ាងទៀត លោកប្រតិបត្តិត្រង់ដើម្បីលះបង់នូវទោស គឺសេចក្ដីកោងឃ្មើសឃ្មាងឆ្គងកាយវាចាចិត្ត ដូច្នេះ ទើបឈ្មោះថា " ឧជុបដិបន្នោ " ។

កែបទ " ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ "

បទនេះប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ។

បុ. លោកប្រតិបត្តិដូចម្ដេចឈ្មោះថា ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ។

វិ. លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវសម្មាបដិបទា ដែលជាផ្លូវប្រតិបត្តិសម្រាប់ដឹងច្បាស់ចាក់ធ្លុះនូវព្រះនិព្វាន ដែលជាគន្លងតម្រាយរបស់ព្រះអរិយៈជាម្ចាស់ទាំងឡាយ លោកតែងយាត្រាទៅកាន់ព្រះនិព្វានយ៉ាងនេះទើបឈ្មោះថា " ញាយបដិបន្នោ " ។ ម្យ៉ាងទៀត លោកប្រតិបត្តិដើម្បីចេញចាកសង្សារវដ្ត មិនប្រតិបត្តិដើម្បី លាភ និង យស និងសេចក្តីសរសើរក្នុងបច្ចុប្បន្ន ឬដើម្បីស្ថានសួគ៌ឡើយ លោកប្រតិបត្តិដើម្បីចេញចាកសង្សារតែម្យ៉ាង យ៉ាងនេះទើបឈ្មោះថា " ញាយវដ្តសុបដិបន្នោ " ។

កែបទ " សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ "

បទនេះប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម ។

បុ. លោកប្រតិបត្តិដូចម្តេចទើបឈ្មោះថា " សមគួរដល់សាមីចិកម្ម " ?

វិ. លោកប្រតិបត្តិតាមសម្មាបដិបទា ដែលជាផ្លូវគួរដល់ព្រះនិព្វានបានពត់កាយវាចាចិត្ត ដោយត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា សមរម្យគួរគេថ្វាយបង្គំនមស្សការយ៉ាងនេះទើបឈ្មោះថា " សាមីចិបដិបន្នោ " ។

Websites: WatKhemaraRatanaram.org or WatKhmers.org


កែបទ " យទិទំ ចត្តារិបុរិសយុគ្គានិ អដ្ឋបុរិសបុគ្គលានិ "

បទនេះប្រែថា ព្រះសង្ឃដែលរាប់ជាគូនៃបុរសបុគ្គលមាន ៤ គូ បើរាប់រាយរៀងជាបុរសបុគ្គលមាន ៨ ។

បុ. ដែលរាប់ជាគូ ៗ នោះតើរាប់ដូចម្ដេច ? ដែលរាបរាយរៀងតួនោះដូចម្ដេច ?

វិ. រាប់ជាគូនោះដូច្នេះ គឺ លោកដែលបានសម្រេចនូវសោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ សកទាគាមិមគ្គ និង សកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផល ជាគូ ១ ត្រូវជា ៤ គូ ។ រាប់រាយដូច្នេះគឺ លោកដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ត្រូវជា ៨ ។

បុ. សោតាបន្នបុគ្គលដែលបានសម្រេចសោតាហើយ តើលះបានអកុសលចិត្តណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត ៤ វិចិកិច្ឆាសម្បយុត្ត ១ ជា ៥ , លះបានសំយោជនៈ ៣ គឺសក្កាយទិដ្ឋិសំយោជនៈ ១

វិចិកិច្ឆាសំយោជនៈ ១ សីលព្វតបរាមាសាសំយោជនៈ ១ ជា ៣ លះបានអនុស្ស័យ ២ គឺ ទិដ្ឋានុស្ស័យ ១ វិចិកិច្ឆានុស្ស័យ ១ ជា ២, លះបានកាមឆន្ទៈ និងព្យាបាទជាចំណែកគ្រោតគ្រាត ដែលឲ្យកើតទុច្ចរិត ៣ ដែលជាអបាយគាមិ ។

បុ. បច្ចវេក្ខណៈ ( ការពិចារណា ) របស់សោតាបន្នបុគ្គលមានប៉ុន្មានយ៉ាង ?

វិ. មាន ៥ យ៉ាងគឺ មគ្គំ បច្ចវេក្ខតិ ព្រះសោតបន្នបុគ្គលរមែងពិចារណានូវមគ្គ ១ ផលំ បច្ចវេក្ខតិ ពិចារណានូវផល ១ បហីនក្កិលេស បច្ចវេក្ខតិ ពិចារណានូវកិលេសដែលលោកលះបានហើយ ១ អវសិដ្ឋក្កិលេសេ បច្ចវេក្ខតិ ពិចារណានូវកិលេសដែលនៅសេសសល់ ១ និព្វានំ បច្ចវេក្ខតិ ពិចារណានូវអមតមហានិព្វាន ១ រួមត្រូវជាបច្ចវេក្ខណៈរបស់សោតាបន្នបុគ្គលមាន ៥ ។

បុ. សោតាបន្នបុគ្គលនោះ ចែកចេញជាប៉ុន្មានយ៉ាង ?

វិ. ចែកចេញជា ៣ ពួក[1] គឺឯកពីជី ១ កោលំកោលៈ ១

---

១- ដែលសម្ដែងថា មាន ៣ ពួកនេះ សំដៅយកតែព្រះសោតាបន្នបុគ្គលដែលមិនស្សកភាព គឺភាពច្រឡូកច្រឡំអន្ទោលទៅមកក្នុងមនុស្ស និង ស្ថានទេព្ដាប៉ុណ្ណោះទេ ឯសោតាបន្នបុគ្គលក្រៅពីនេះ ច្រើនពេកណាស់រាប់មិនអស់ឡើយ ( បាលីអដ្ឋកថាអភិធម្ម ) ។

សត្តក្ខត្តុំបរមៈ ១ ។ ឯកពីជី លោកដែលមានពូជគឺ ភពតែ ១ គឺនៅកើតក្នុងមនុស្សលោកតែ ១ ជាតិទៀត ហើយធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល លែងមានកំណើតទៅខាងមុខទៀត ។ កោលំកោលៈ លោកដែលទៅពីត្រកូល ១ ទៅកាន់ត្រកូល ១ ទៀត គឺលោកដែលនៅកើត ២ ជាតិ ឬ៣ ជាតិទៀតទើបបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។ សត្តក្ខត្តុំបរមៈ លោកដែលត្រេចរង្គាត់ទៅកើតក្នុងមនុស្សលោក និង ទេវតាលោកយ៉ាងច្រើនបំផុតត្រឹម ៧ ជាតិទៀត ទើបបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលដោយខន្ធបរិនិព្វានក្នុងជាតិជាគំរប់ ៧ ពិតប្រាកដ ។

បុ. ហេតុអ្វីបានជាសោតាបន្នបុគ្គល មានប្រភេទផ្សេងគ្នា អង្គខ្លះជា ឯកពិជី អង្គខ្លះជា កោលំកោលៈ អង្គខ្លះជា សត្តក្ខត្តុំបរមៈ ?

វិ. បានជាមានប្រភេទផ្សេងគ្នា ពីព្រោះមានវិបស្សនាផ្សេងគ្នា គឺ ឯកពីជី មានវិបស្សនាក្លៀវក្លាបំផុត កោលំកោលៈ មានវិបស្សនាក្លៀវក្លាយ៉ាងកណ្ដាល សត្តក្ខត្តុំបរមៈ មានវិបស្សនាទន់បំផុត ។

បុ. សោតាបន្នបុគ្គល លោកបរិបូណ៌ដោយធម៌អ្វី ?

វិ. បរិបូណ៌ដោយសីល ។

បុ. សោតាបន្នបុគ្គលនោះនៅមានចែកចេញទៅទៀតឬ ?

វិ. មានចែកចេញទៀត បើចែកតាមឈ្មោះដើមមានតែ ៣ ដូចពោលមកហើយ តែបើចែកតាមខណៈចិត្តដែលលះកិលេសបានផ្សេងគ្នាមាន ២៤ ដូច្នេះគឺយកបដិបទា ៤ និង ធុរៈ ២ មកគុណ ឯកពីជីមានបដិបទា ៤ កោលំកោលៈ មានបដិបទា ៤ សត្តក្ខត្តុំបរមៈ មានបដិបទា ៤ រួមត្រូវជា ១២ ចែកជាសទ្ធាធុរៈ ១២ បញ្ញាធុរៈ ១២ បានជា ២៤ ។

បុ. សកទាគាមិបុគ្គល លះបានអកុសលចិត្តណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិវិប្បយុត្ត ៤ ទោមនស្សសហគតចិត្ត ២ ជា ៦ លះបានសំញោជនៈ ២ គឺ កាមរាគសំញោជនៈ ១ ព្យាបាទសំញោជនៈ ១ ជា ២ លះបានអនុស័យ ២ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ ជា ២ លះរាគៈ ទោសៈ មោហៈ បានដោយស្រាលស្តើង ។ សកទាគាមិបុគ្គលនេះរមែងមកកើតក្នុងកាមភពនេះម្តងទៀត ទើបធ្វើឲ្យជាក់ច្បាស់នូវអហត្តផលជាទីបំផុត នៃទុក្ខហើយទើបបានរំលត់ខន្ធចូលកាន់និព្វាន ។

ឯបច្ចវេក្ខណៈ របស់សកទាគាមិបុគ្គលក៏មាន ៥ ដូចសោតាបន្នបុគ្គលដែរ ហើយបរិបូណ៌ដោយសីលដូចគ្នា ។

បុ. សកទាគាមិបុគ្គលបើចែកតាមខណៈចិត្តដែលលះកិលេសបានមានប៉ុន្មាន ?

វិ. មាន ១២ គឺក្នុងសកទាគាមិបុគ្គលមួយ ៗ មានវិមោក្ខ ៣ ក្នុងវិមោក្ខមួយ ៗ មានបដិបទា ៤ រួមត្រូវជា ១២ ។

បុ. អនាគាមិបុគ្គលលះបានអកុសលណាខ្លះ ?

វិ. លះបានអកុសលចិត្ត ជាទិដ្ឋិគតវិប្បយុត្ត ៤ ទោមនស្សសហគតចិត្ត ២ លះបានសញ្ញោជនៈ ២ គឺ កាមរាគៈ ១ ព្យាបាទៈ ១ និងអនុស័យ ២ គឺកាមរាគានុស័យ ១ បដិឃានុស័យ ១ ដោយដាច់ស្រឡះ ។ ឯបច្ចវេក្ខណៈរបស់អនាគាមិបុគ្គលនេះក៏មាន ៥ ដូចសោតាបន្នបុគ្គលដែរ ។

បុ. អនាគាមិបុគ្គលចែកជាប៉ុន្មានពួក ?

វិ. ចែកចេញជា ៥ ពួកគឺអន្តរបរិនិព្វានយី ១ ឧបហច្ចបរិនិព្វាយី ១ អសង្ខារបរិព្វាយី ១ សសង្ខារបរិនិព្វានយី ១ ឧទ្ធំសោតោអកនិដ្ឋគាមី ១ ។

អន្តរបរិនិព្វានយី លោករំលត់ក្នុងចន្លោះ គឺលោកដែល

Websites: WatKhemaraRatanaram.org or WatKhmers.org


កើតក្នុងសុទ្ធាវាសព្រហ្មលោក ហើយនៅមិនទាន់ដល់ពាក់កណ្តាលអាយុ ក៏ញ៉ាំងអរហត្តមគ្គឲ្យកើតឡើងលះសំយោជនៈខាងលើបាន ។ ឧបហច្ចបរិនិព្វាយី លោកកន្លងពីថ្នាក់នោះបន្តិចទៅទៀត គឺលោកដែលមានអាយុជាងពាក់កណ្តាលឡើងទៅ ដល់កាលទៀបនឹងអស់អាយុ ទើបញ៉ាំងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈ ខាងលើទាំង ៥ ។ អសង្ខារបរិនិព្វាយី រំលត់ដោយសង្ខារ គឺលោកដែលញ៉ាំងអរហត្តមគ្គឲ្យកើតឡើងលះសំយោជនៈទាំង ៥ ខាងលើបានងាយ មិនបាច់ប្រកបព្យាយាមតឹងតែងពេក ។ សសង្ខារបរិនិព្វាយី លោកជាអ្នករំលត់ដោយសសង្ខារ គឺលោកដែលញ៉ាំងអរហត្តមគ្គឲ្យកើតឡើងបានដោយកម្រ ទាល់តែប្រកបសេចក្តីព្យាយាមយ៉ាងធំ ។ ឧទ្ធំសោតោអកនិដ្ឋគាមី លោកជាអ្នកមានខ្សែព្ធដ៏ខាងលើទៅកាន់ភពអកនិដ្ឋ គឺចុតិចាកព្រហ្មលោកឈ្មោះអវិហាហើយ ទៅកាន់អតប្បាព្រហ្មលោកទៀត លុះចុតិចាកអតប្បាព្រហ្មលោកហើយទៅកាន់សុទស្សាព្រហ្មលោកទៀត លុះចុតិចាកសុទស្សាព្រហ្មលោកហើយ ទៅកាន់សុទស្សីព្រហ្មលោកទៀត លុះចុតិចាកសុទស្សីព្រហ្មលោកហើយទៅកាន់អកនិដ្ឋ-

ព្រហ្មលោកទៀត ទើបញ៉ាំងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈ ខាងលើក្នុងព្រហ្មលោកនោះ រួមផងគ្នាត្រូវជាអនាគាមិបុគ្គល ៥ ពួក ។ ក្នុងស្ថានអវិហា ៥ អតប្បា ៥ សុទស្សា ៥ សុទស្សី ៥ អកនិដ្ឋ ៤ លើកឧទ្ធំសោតៈ មួយចេញរួមជាអនាគាមិបុគ្គលមាន ២៤ គុណទៅទៀតជាសទ្ធាធុរៈ ២៤ បញ្ញាធុរៈ ២៤ ទើបបានជាអនាគាមិបុគ្គល ៤៨ ។

បុ. ព្រះអនាគាមិបុគ្គលលោកបរិបូណ៌ដោយធម៌អ្វី ?

វិ. លោកបរិបូណ៌ដោយសមាធិ ។

បុ. ព្រះអរហត្តលះបានអកុសលចិត្តណាខ្លះ ?

វិ. លះបានអកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត ៤ ឧទ្ធច្ចសហគតចិត្ត ១ ជា ៥ លះបានសំយោជនៈ គឺរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា និងមានានុស័យ រាគានុស័យ អវិជ្ជានុស័យ ដាច់ស្រឡះពីខន្ធសន្ដាន ។

បុ. បច្ចវេក្ខណៈ ការពិចារណារបស់ព្រះអរហន្តមានប៉ុន្មានយ៉ាង ?

វិ. មាន ៤ យ៉ាងគឺ មគ្គំ បច្ចវេក្ខតិ លោកពិចារណាមគ្គ ១ ផលំ បច្ចវេក្ខតិ ពិចារណានូវផល ១ បហីនក្កិលេសំ

បច្ចវេក្ខតិ ពិចារណានូវកិលេសដែលលោកលះបានហើយ ១ និព្វានំ បច្ចវេក្ខតិ ពិចារណានូវព្រះនិព្វាន ១ រួមផងគ្នាត្រូវជា ៤ ។

បុ. អរហន្តនោះចែកជាប៉ុន្មានពួក ?

វិ. ចែកជា ៤ ពួកគឺ សុក្ខវិបស្សកោ លោកអ្នកមានវិបស្សនាដ៏រីងស្ងួតព្រោះមិនមានជ័រគឺសមថភាវនា បានចម្រើនវិបស្សនាលុះដល់ព្រះអរហត្តមិនប្រកបដោយឫទ្ធិវិសេស ឯណាឡើយ មួយពួក, តេវិជ្ជោ លោកដែលបានវិជ្ជា ៣ មួយពួក, ឆឡភិញ្ញោ លោកដែលបានអភិញ្ញា ៦ មួយពួក, បដិសម្ភិទ-ប្បត្តោ លោកដែលដល់បដិសម្ភិទា ៤ មួយពួក, ត្រូវជាព្រះអរហន្តមាន ៤ ពួក ។ ព្រះអរហន្តទាំង ៤ ពួកនេះ រួមមកជា ២ គឺសុក្ខវិបស្សកៈ ១, ហើយនិងខាងចុង ៣ រួមមក ហៅថាសមថយានកៈតែម្យ៉ាង ១ ។ ចាត់ទៅតាមវិមោក្ខ ៣ គឺក្នុងវិមោក្ខមួយ ៗ មានបដិបទាបួន ៗ រួមត្រូវជា ១២, ជាសុក្ខវិប-ស្សកៈ ១២ សមយានកៈ ១២ ជាព្រះអរហន្ត ២៤ ។

បុ. ព្រះអរហន្តលោកបរិបូណ៌ដោយធម៌អ្វី ?

វិ. លោកបរិបូណ៌ដោយបញ្ញា ។

Websites: WatKhemaraRatanaram.org or WatKhmers.org


រួមព្រះអរិយបុគ្គលទាំងអស់ត្រូវជា ១០៨ គឺសោតាបន្នបុគ្គល ២៤ , សកទាគាមិ ១២ , អនាគាមី ៤៨ , អរហន្ត ២៤ , សមនឹងពុទ្ធដីកាព្រមទាំងអដ្ឋកថា ថា យេ បុគ្គលា អដ្ឋសតំ បសដ្ឋាតី ឥមិស្សា គាថាយ វណ្ណនាយំ អដ្ឋុត្តរសតំ អរិយា វុត្តា ។ ក៏ព្រះអរិយបុគ្គលទាំង ១០៨ នេះ ចែកជាមគ្គ ៥៤ ផល ៥៤ ត្រូវជាព្រះអរិយបុគ្គលទាំង ១០៨ ដដែល ។

បុ. បដិបទាទាំង ៤ យ៉ាងនោះគឺអ្វីខ្លះ ?

វិ. គឺ ទុក្ខាបដិបទាទន្ធាភិញ្ញា កាលប្រតិបត្តិលំបាក ដល់បានត្រាស់ដឹងក៏លំបាក ១ សុខាបដិបទាទន្ធាភិញ្ញា កាលប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរវិញ ១ ទុក្ខាបដិបទាខិប្បាភិញ្ញា កាលប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ១ សុខាបដិបទាខិប្បាភិញ្ញា កាលប្រតិបត្តិងាយ ត្រាស់ដឹងឆាប់វិញ ១ ។

បុ. បដិបទា ផ្សេងគ្នាដោយយឺតយូរ និង ឆាប់រហ័សយ៉ាងនេះព្រោះហេតុអ្វី ?

វិ. ព្រោះបុគ្គលដែលប្រតិបត្តិនោះ មានឥន្ទ្រីយ៍ និង កិលេសផ្សេងគ្នា គឺ៖

១- បុគ្គលដែលប្រតិបត្តិយឺតយូរ ព្រោះកិលេសក្លៀវក្លា

Websites: WatKhemaraRatanaram.org or WatKhmers.org


បានត្រាស់ដឹងយឺតយូរព្រោះឥន្ទ្រីយ៍ទន់ ប្រៀបឧបមាដូចជាអ្នកមានជម្ងឺជាទម្ងន់ដើរទៅផ្ទះគ្រូពេទ្យ ដំណើរដែលទៅនោះរមែងយឺតយូរព្រោះខ្លួនឈឺធ្ងន់ បានដល់ផ្ទះពេទ្យហើយទៅរកថ្នាំ ៗ នោះក៏បានតិច ម្លោះហើយជម្ងឺនោះក៏ទៅជា ជាសះស្បើយបានដោយយឺតយូរ យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

២- ប្រតិបត្តិងាយ ត្រាស់ដឹងយឺតយូរ ព្រោះកិលេសតិចឥន្ទ្រីយ៍ទន់ ឧបមាដូចជាអ្នកមានជម្ងឺស្រាល ដើរទៅរកផ្ទះពេទ្យឆាប់ដល់ តែព្យាបាលរោគយូរ ព្រោះមានថ្នាំតិច យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៣- ប្រតិបត្តិលំបាក ត្រាស់ដឹងឆាប់ ព្រោះកិលេសក្លៀវក្លាឥន្ទ្រីយ៍ក៏ក្លៀវក្លាដែរ ឧបមាដូចជាអ្នកមានជម្ងឺធ្ងន់ ដើរទៅរកផ្ទះពេទ្យយឺតយូរ តែបានសះជារោគឆាប់រហ័ស ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

៤- ប្រតិបត្តិងាយ ត្រាស់ដឹងឆាប់ ព្រោះកិលេសទន់ឥន្ទ្រីយ៍ក្លៀវក្លា ឧបមាដូចជាអ្នកមានជម្ងឺស្រាល ដើរទៅរកផ្ទះ

ពេទ្យឆាប់ដល់ រក្សារោគក៏ឆាប់សះជា ព្រោះមានថ្នាំច្រើន យ៉ាងណាមិញ សុខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

តួកិលេសទុកដូចជារោគ ឥន្ទ្រីយ៍ទាំង ៥ ទុកដូចជាថ្នាំសម្រាប់កែរោគ ។ ម្យ៉ាងទៀត ឧបមាដូចបុរស ៤ នាក់ ស្វែងរកគោ, បុរសទី១ ដើរទៅក្នុងព្រៃដល់វេលាឃើញគោ ក៏ឃើញក្នុងព្រៃ យ៉ាងណាមិញ ទុក្ខាបដិបទាទន្ធាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី២ ដើរទៅរកគោតាមផ្លូវធ្លាស្រួល ដល់ឃើញគោបែរជាឃើញក្នុងព្រៃវិញ យ៉ាងណាមិញ សុខាបដិបទាទន្ធា-ភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី៣ ស្វែងរកគោដើរកាត់ព្រៃ ដល់ឃើញគោ បែរទៅជាឃើញក្នុងទីវាលវិញ យ៉ាងណាមិញ ទុក្ខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។ បុរសទី៤ ដើរទៅរកគោតាមផ្លូងធ្លា ដល់ឃើញគោក៏ឃើញក្នុងទីវាល យ៉ាងណាមិញ សុខាបដិបទាខិប្បាភិញ្ញាបុគ្គល ក៏យ៉ាងនោះដែរ ។

បុរស គឺ យោគាវចរកុលបុត្រ ដែលស្វែងរកអរិយមគ្គ, គោគឺអរិយមគ្គ, ព្រៃគឺកិលេស ផ្លូវធ្លាគឺ កិលេសដ៏ស្តើង ។ បុគ្គលដែលបានមគ្គផលផ្សេងគ្នាព្រោះប្រតិបត្តិខុសគ្នា ដូចសម្តែងមកនេះ ។

កែបទ " ឯស ភគវតោ សាវកសង្ឃោ "

បទនេះប្រែថា ព្រះសង្ឃដែលបានពណ៌នាមកទាំងអម្បាលនេះនុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ។

កែបទ " អាហុណេយ្យោ "

បទថា " អាហុណេយ្យោ " ប្រែថា លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលនាំមកបូជា ។

អធិប្បាយថាបច្ច័យទាំង ៤ ប្រការ មានចីវរប្បច្ច័យជាដើម ដែលបុគ្គលនាំមកអំពីទីជិតក្តី ឆ្ងាយក្តីដើម្បីបូជាដល់បុគ្គលមានសីលទាំងឡាយ ។ បច្ច័យទាំងនោះព្រះសង្ឃជាសាវកលោកគួរទទួលបាន ព្រោះលោកអាចធ្វើនូវបច្ច័យទាំងនោះឲ្យមានផលច្រើនដោយគុណរបស់លោក បានជាឈ្មោះថា " អាហុណេយ្យោ " ។

កែបទ " បាហុណេយ្យោ "

បទថា " បាហុណេយ្យោ " ប្រែថា លោកគួរទទួលនូវអាគន្តុកទាន ។

អធិប្បាយថា ទានដែលបុគ្គលចាត់ចែងដោយគ្រឿងសក្ការៈ ដើម្បីនឹងទទួលញាតិមិត្តជាទីស្រលាញ់ពេញចិត្តដែល

មកអំពីទិសានុទិសហៅថា " អាគន្តុកទាន " អាគន្តុកទាន នោះឯង គួរនឹងរៀរនូវញាតិនិងមិត្ត និង មនុស្សដែលមកជាភ្ញៀវ នោះហើយថ្វាយដល់សង្ឃតែម្យ៉ាង ។ ព្រះសង្ឃគួរនឹងទទួល នូវអាគន្តុកទាននោះមែនពិត មនុស្សដែលមកជាភ្ញៀវនោះមិន ប្រាកដដូចព្រះសង្ឃទេ ព្រោះព្រះសង្ឃដែលមកជាភ្ញៀវនោះ រមែងមានតែក្នុងកាលដែលមានព្រះពុទ្ធត្រាស់ដឹងប៉ុណ្ណោះ មិន ដែលមានក្នុងកាលដទៃឡើយ ហើយលោករមែងប្រកបដោយ ធម៌ជាគ្រឿងធ្វើនូវភាវៈនៃមុខគួរឲ្យអ្នកផងស្រលាញ់ គួរឲ្យគេ ចាប់ចិត្ត មានសីលគុណជាដើម ព្រោះហេតុនោះ របស់ដែល សម្រាប់ទទួលភ្ញៀវនោះ គួរតែលើកមកថ្វាយដល់ព្រះសង្ឃនុ៎ះ មែនពិត ដូច្នេះទើបឈ្មោះថា " បាហុណេយ្យោ " ។

កែបទ " ទក្ខិណេយ្យោ "

បទថា " ទក្ខិណេយ្យោ " ប្រែថា " លោកគួរទទួលនូវ ទក្ខិណាទាន " ។

អធិប្បាយថា ទានដែលបុគ្គលជឿនូវកម្ម និង ផលនៃកម្ម ហើយធ្វើ ហៅថា " ទក្ខិណាទាន " ព្រះសង្ឃជាសាវកលោកគួរ

ទទួលនូវទក្ខិណាទាននោះ ព្រោះលោករមែងជម្រះទានរបស់ទាយកឲ្យបរិសុទ្ធិបាន ឲ្យមានផលច្រើន ទើបបានឈ្មោះថា " ទក្ខិណេយ្យោ " ។

កែបទ " អញ្ជលិករណីយោ "

បទនេះប្រែថា លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ។

អធិប្បាយថា ព្រះសង្ឃជាសាវកលោកគួរដល់អញ្ជលិកម្ម គឺគួរសត្វថ្វាយបង្គំ បើនិយាយដោយហោចទៅសូម្បីសត្វលោកគ្រាន់តែរមិលមើលព្រះសង្ឃដោយចក្ខុ ប្រកបដោយមេត្តាប៉ុណ្ណោះ ចក្ខុនោះក៏រមែងប្រាសចាកទោសមានឡើងបានជាដើម ក្នុងអនេកជាតិបាន ។

កែបទ " អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស "

បទនេះ ប្រែថា លោកជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

អធិប្បាយថា ព្រះសង្ឃជាសាវកជាស្រែកើតបុណ្យនៃសត្វលោកមិនមានស្រែដទៃ ប្រសើរស្មើឬជាងឡើយ ទីសាបព្រោះបណ្ដុះពូជស្រូវសាលីស្រូវដំណើប នៃស្ដេចឬអាមាត្យ

ឈ្មោះថា ស្រែស្រូវសាលីស្រូវដំណើបនៃស្តេចឬអាមាត្យយ៉ាងណា, ព្រះសង្ឃដែលជាទីដុះចម្រើនបុណ្យនៃសព្វសត្វក៏ដូច្នោះដែរ, បានជាថាព្រះសង្ឃជាទីកើតបុណ្យនៃសត្វលោក ព្រោះបុណ្យកុសលដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខមានប្រការផ្សេង ៗ របស់សត្វលោករមែងមានពន្លកល្អលូតលាស់ចម្រើនឡើងបាន ព្រោះតែអាស្រ័យនិងព្រះសង្ឃ ដ្បិតព្រះសង្ឃជាស្រែបរិសុទ្ធិប្រាសចាកទោស គឺ កិលេសដែលជាគ្រឿងប្រទូស្តក្នុងសន្តាននៃខ្លួន នឹងប្រទូស្តចំពោះទាននិងការបូជានៃសត្វលោក ជាស្រែដ៏បរិសុទ្ធិប្រាសចាកទោសគឺ ស្មៅនិងក្រួសខ្សាច់ជាដើម ដែលជារបស់ប្រទូស្តដល់សន្ទូង ទើបបានឈ្មោះថា ស្រែបុណ្យដ៏ឧត្តមនៃសត្វលោក ។

ន័យមួយទៀតថា ពូជដែលបុគ្គលព្រោះសាប ឬដាំបណ្តុះក្នុងស្រែប្រកបដោយអង្គ ៨ ប្រការទើបមានផលច្រើន, អង្គ ៨ ប្រការនោះដូច្នេះគឺ៖

១- អនុន្នមិនិន្នាមិ ច ហោតិ មិនទួលពេក មិនទាបពេក,

២- អបាសាណសក្ខរិញ្ច ហោតិ មិនមានថ្មនិងក្រួស,

៣- អនូសរញ្ច ហោតិ មិនប្រកបដោយដីប្រៃ,

៤- គម្ភីរសិតំ ហោតិ មានជម្រៅនិងត្រជាក់,

៥- អាយសម្បន្នំ ហោតិ បរិបូណ៌ដោយសេចក្តីចម្រើន គឺមានជីវជាតិច្រើន,

៦- អបាយសម្បន្នំ ហោតិ មិនមានសេចក្តីវិនាស,

៧- មាតិកាសម្បន្នំ ហោតិ មានប្រឡាយ,

៨- មរិយាទសម្បន្នំ ហោតិ មានភ្លឺ,

ពូជដែលបុគ្គលសាបព្រោះក្នុងស្រែប្រកបដោយអង្គ ៨នេះ រមែងមានផលយ៉ាងច្រើនយ៉ាងណា ទានដែលបុគ្គលឲ្យដល់ព្រះសង្ឃដែលជាបុញ្ញក្ខេតប្រកបដោយអង្គ ៨ នេះ ក៏មានផលច្រើនដូច្នោះដែរ ។

អង្គ ៨ ប្រការនោះដូច្នេះគឺ៖

១- សម្មាទិដ្ឋិកា ជាអ្នកយល់ត្រូវ,

២- សម្មាសង្កប្បា មានដម្រិះត្រូវ,

៣- សម្មាវាចា មានវាចាត្រូវ,

៤- សម្មាកម្មន្តា មានការងារត្រូវ,

៥- សម្មាអាជីវា មានការចិញ្ចឹមជីវិតត្រូវ,

៦- សម្មាវាយាមា ព្យាយាមត្រូវ,

៧- សម្មាសតិនោ មានសេចក្ដីរឭកត្រូវ,

៨- សម្មាសមាធិ មានចិត្តដម្កល់ត្រូវ,

ទានដែលបុគ្គលឲ្យដល់ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ប្រកបដោយអង្គ ៨ ដូចរាប់មកនេះ រមែងមានផលានិសង្សច្រើន, សមដូចព្រះពុទ្ធភាសិតថា៖

តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសោ អយំ បជា
តស្មា ហិ វីតគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានរាគៈជាទោស ហេតុនេះ ទានដែលបុគ្គលឲ្យដល់

Websites: WatKhemaraRatanaram.org or WatKhmers.org


លោកដែលមិនមានរាគៈ រមែងមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានទោសៈ ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យដល់លោកដែលអស់ទោសៈ រមែងមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យដល់លោកដែលអស់មោហៈ រមែងមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វនេះមានឥច្ឆាគឺ សេចក្តិប្រណែនជាទោស ព្រោះហេតុនោះទានដែលបុគ្គលឲ្យដល់លោកអស់ឥច្ឆាហើយរមែងមានផលច្រើន ។

ក៏ព្រះសង្ឃសាវកដែលមាននាមតាំងពី អាហុណេយ្យោ រហូតដល់បុញ្ញក្ខេត្តំលោកស្សនេះ លោករមែងប្រកបដោយអង្គ ៥ យ៉ាងដទៃទៀត ប្រៀបដោយអង្គនៃដំរីជាព្រះរាជទីនាំង ។

ដំរីប្រកបដោយអង្គ ៥ នេះគឺៈ

១- សោតា ជាសត្វស្តាប់បង្គាប់ហ្ម

២- ហន្តា ជាសត្វតែងសម្លាប់នូវខ្មាំងសត្រូវដែលមកតទល់គ្នាពេលចូលកាន់សង្គ្រាម

៣- រក្ខិតា ជាសត្វចេះរក្សាអវៈយវៈតូចធំរបស់ខ្លួនក្នុង
ពេលចូលកាន់សង្គ្រាម

៤- ខន្តា ជាសត្វអត់ទ្រាំនឹងលំពែងជាដើមបាន
ក្នុងពេលចូលកាន់សង្គ្រាម

៥- គន្តា ជាសត្វចេះតែទៅតាមបំណងហ្ម

ដំរីដែលគួរដល់មហាក្សត្រីយ៍ ស្ដេចប្រើប្រាសរមែងប្រកប ដោយអង្គ៥ ប្រការនេះ យ៉ាងណាមិញ ព្រះសង្ឃសាវកដែល មាននាមថា អាហុណេយ្យោជាដើម ក៏ប្រកបដោយអង្គ ៥ ដូច្នោះដែរគឺ៖

១- សោតា ជាអ្នកស្ដាប់នូវធម៌ដែលព្រះតថាគតសម្ដែង

២- ហន្តា ជាអ្នកសម្លាប់នូវអកុសលវិត្តក ទាំង៣

៣- រក្ខិតា ជាអ្នករក្សានូវឥន្ទ្រីយ៍ទាំង ៦

៤- ខន្តា ជាអ្នកអត់ធ្មត់នឹងក្ដៅត្រជាក់ជាដើមបាន

៥- គន្តា ជាអ្នកទៅកាន់ទិសដែលគេមិនដែលទៅ
គឺព្រះនិព្វាន

ព្រះសង្ឃជាសាវកប្រកបដោយអង្គ ៥ យ៉ាងនេះឯង ទើប ឈ្មោះថា អាហុណេយ្យោ ។ល។ បុញ្ញក្ខេត្តំ លោកស្ស ។

Websites: WatKhemaraRatanaram.org or WatKhmers.org


ម្យ៉ាងទៀត គុណព្រះសង្ឃទាំងអម្បាលនេះ បើបំព្រួញចុះមកនៅត្រឹម ២ យ៉ាងគឺ អត្តហិតគុណ ១ បរហិតគុណ ១ ។

ត្រង់បទថា សុបដិបន្នោ ឧជុបដិបន្នោ ញាយបដិបន្នោ សាមីចិបដិបន្នោ ទាំងអស់នេះឈ្មោះថា " អត្តហិតគុណ " ព្រោះជាគុណទំនុកបម្រុងដល់ខ្លួន ។ អាហុណេយ្យោ បាហុណេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ទាំងអម្បាលនេះ ឈ្មោះថា " បរហិតគុណ " ព្រោះគុណទំនុកបម្រុងដល់អ្នកដទៃ ។

ពណ៌នាអំពីសង្ឃរតនៈចប់ដោយសង្ខេបប៉ុណ្ណេះ

ត្រៃគុណកថា និដ្ឋិតា